GLOBAL CITIZENSHIP EDUCATION • A GUIDE FOR TRAINERS

# ការអប់រំពលរដ្ឋសកល

## សេចក្តីណែនាំសម្រាប់គ្រូឧទ្ទេស

បកប្រែជាភាសាខ្មែរ

ដោយមជ្ឈមណ្ឌលសហប្រតិបត្តិការនៃការអប់រំភាពជាពលរដ្ឋសកល

GCC - Cambodia

Asia-Pacific Centre of Education for International Understanding

# ការអប់រំ ពលរដ្ឋសកល
# សេចក្តីណែនាំ សម្រាប់គ្រូឧទ្ទេស

ផលិតដោយ

ការិយាល័យអប់រំ និងបណ្តុះប ណ្តាល, APCEIU(2018)

©APCEIU 2018

សូមរ ក្សាសិទ្ធិ

អាស័យដ្ឋានទាក់ទង
ការិយាល័យអប់រំ និងបណ្តុះបណ្តាលនៃអង្គការ, APCEIU
120, Saemal-ro, Guro-gu, សេអ៊ូល សាធារណៈរដ្ឋកូរ៉េ, 08289
Tel: (+82-2) 774-3933 Fax: (+82-2) 774-3958
www.unescoapceiu.org

រៀបរៀងនិងបោះពុម្ពដោយ៖
tone & tone

# ការអប់រំពលរដ្ឋសកល

GLOBAL CITIZENSHIP EDUCATION • A GUIDE FOR TRAINERS •

## សេចក្ដីណែនាំសម្រាប់គ្រូឧទ្ទេស

Asia-Pacific Centre of Education for International Understanding

## APCEIU

## (មជ្ឈមណ្ឌលអប់រំអាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ការយល់ដឹងសកល)

មជ្ឈមណ្ឌលអប់រំអាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ការយល់ដឹងសកលដែលហៅជាអក្សរកាត់ថា (APCEIU) ក្រោមការឧបត្ថម្ភរបស់អង្គការ UNESCO គឺជាមជ្ឈមណ្ឌលប្រភេទទី២ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០០តាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋកូរ៉េ និងអង្គការUNESCO ដើម្បីជំរុញ និងលើកកម្ពស់ការអប់រំសម្រាប់ការយល់ដឹងសកល (EIU) និងការអប់រំភាពជាពលរដ្ឋសកល (GCED) ក្នុងចំណោមរដ្ឋជាសមាជិកនៃអង្គការយូណេស្កូ( UNESCO )។

ការអប់រំពលរដ្ឋសកល (GCED) មានគោលបំណងផ្តល់ជូនអ្នកសិក្សាគ្រប់វ័យនូវគុណតម្លៃ ចំណេះដឹង និងជំនាញ ដោយផ្តោតទៅលើការគោរពសិទ្ធិមនុស្សយុត្តិធម៌សង្គម ភាពចម្រុះនៃជាតិសាស្រ្ត សមភាពយេនឌ័រ និងនិរន្តរភាព នៃបរិស្ថានតាមរយៈការផ្តល់សិទ្ធិអំណាចឱ្យអ្នកសិក្សា ក្លាយជាពលរដ្ឋសកល និងមានការទទួលខុសត្រូវ។ ការអប់រំភាពជាពលរដ្ឋសកលផ្តល់ឱ្យអ្នកសិក្សា នូវសមត្ថភាព និងឱកាស ដើម្បីដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ក្នុងការលើកកម្ពស់ពិភពលោក និងអនាគតដ៏ល្អប្រសើរសម្រាប់ទាំងអស់គ្នា។

## អំពីការណែនាំ

សៀវភៅណែនាំនេះ គឺជាឯកសារបណ្តុះបណ្តាលមួយ សម្រាប់គ្រូឧទ្ទេស ដែលនឹងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលអ្នកអប់រំ អំពីភាពជាពលរដ្ឋសកល ក្នុងគោលបំណងដូចខាងក្រោម៖

- ណែនាំព័ត៌មាននិងគោលគំនិតជាមូលដ្ឋាននៃការអប់រំភាពជាពលរដ្ឋសកល ដល់អ្នកចូលរួមសិក្ខាសាលា
- ជួយដល់សិក្ខាកាមទទួលបាននូវបទពិសោធន៍នៃសញ្ញាណគ្រឹះក្នុងការអប់រំភាពជាពលរដ្ឋសកល និងការរៀននិងបង្រៀនតាមបែបស្ថាបនានិយម
- លើកទឹកចិត្តអ្នកចូលរួមឱ្យស្វែងរកវិធីសាស្រ្តនិងឱកាសដែលអាចអនុវត្តការអប់រំភាពជាពលរដ្ឋសកល នៅក្នុងសាលារៀន និងកន្លែងអប់រំផ្សេងទៀត។

សិក្ខាសាលាស្តីអំពីការអប់រំភាពជាពលរដ្ឋសកលទាមទារឱ្យសិក្ខាកាមចូលរួមយ៉ាងសកម្ម ក្នុងអំឡុងពេលសិក្ខាសាលា។ អាស្រ័យហេតុនេះ រាល់ម៉ោងសិក្ខាសាលានីមួយៗ ត្រូវមានការបង្រៀន ការពិភាក្សា ការធ្វើសកម្មភាព ការឆ្លុះបញ្ចាំង និងការសន្ទនាជាប្រចាំ ជាមួយអ្នកសម្របសម្រួល និងអ្នកចូលរួម។ គ្រូឧទ្ទេសអាចពិគ្រោះគ្នានូវឯកសារសិក្ខាសាលានេះ ដើម្បីធ្វើការកែប្រែទម្រង់កម្មវិធីសិក្សាឬខ្លឹមសារបមេរៀនប្រសិនបើចាំបាច់។

### កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

សៀវភៅណែនាំនេះ រំពឹងថាគ្រូឧទ្ទេសនៃសិក្ខាសាលា នឹងដើរតួនាទីជាអ្នកសម្របសម្រួល។ អ្នកសម្របសម្រួលមិនត្រូវ 'ផ្ទេរ' ចំណេះដឹងនោះទេ។ ផ្ទុយទៅវិញ ពួកគេគួរតែលើកទឹកចិត្តសិក្ខាកាមឱ្យចែករំលែកគំនិតយោបល់ និងចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពសិក្ខាសាលា។

ខាងក្រោមនេះជាគម្រុយជួយដល់គ្រូឧទ្ទេសក្នុងការរៀបចំនិងអនុវត្តក្នុងពេលសិក្ខាសាលា៖

### ការធ្វើផែនការ និងការរៀបចំសិក្ខាសាលា

**បង្កើតគោលដៅសិក្ខាសាលា៖** សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងណែនាំពីការអប់រំភាពជាពលរដ្ឋសកល ទៅដល់អ្នកអប់រំទាំងឡាយណា ដែលមិនទាន់បានស៊ាំនឹងការអប់រំបែបនេះ តាមរយៈសិក្ខាសាលាតម្រង់ទិស។ ដូច្នេះ វាមានប្រសិទ្ធភាពក្នុងការរៀបចំនិងអនុវត្តសិក្ខាសាលា ដែលស្របតាមគោលបំណងនៃសៀវភៅណែនាំ។

**ការឆ្លុះបញ្ចាំងលើបុគ្គលិកលក្ខណៈរបស់សិក្ខាកាម៖** សូមរៀបចំសិក្ខាសាលា ដោយផ្តោតគំនិតទៅលើការរៀបចំបុគ្គលិកលក្ខណៈរបស់សិក្ខាកាម (ឧ.សមាសភាពក្រុមចូលរួម គោលបំណងនៃការចូលរួម បទពិសោធន៍និងជំនាញរបស់អ្នកចូលរួម)។ ជាឧទាហរណ៍ ប្រសិនបើអ្នកចូលរួមមិនធ្លាប់ស្គាល់គ្នាទេ វាជារឿងសំខាន់ក្នុងការបង្កើតទំនាក់ទំនង តាមរយៈសកម្មភាពណែនាំខ្លួននៅដើមសិក្ខាសាលា។ ដូច្នេះសូមរៀបចំផែនការសកម្មភាពសាមញ្ញមួយសម្រាប់ការណែនាំនេះ។

ការយល់ដឹងអំពីខ្លឹមសារនៃសៀវភៅលំហាត់៖ មុនពេលចាប់ផ្តើមសិក្ខាសាលា អ្នកសម្របសម្រួលគួរតែស្គាល់សៀវភៅណែនាំ និងឯកសារបណ្តុះបណ្តាល ក៏ដូចជាសកម្មភាពសិក្ខាសាលា ការបែងចែកពេលវេលា និងសំណួរពិភាក្សាដែលសិក្ខាកាមនឹងត្រូវចូលរួម។ ការអនុវត្តគ្រប់គ្រាន់នឹងជួយដល់អ្នកដោះស្រាយស្ថានភាពដែលនឹកស្មានមិនដល់ ថានឹងអាចកើតឡើងនៅក្នុងអំឡុងពេលសិក្ខាសាលាជាក់ស្តែង។ លើសពីនេះទៅទៀត វាមានប្រយោជន៍ក្នុងការរៀបចំសម្ភារៈចាំបាច់ជាមុនខណៈពេលកំពុងអាននិងសិក្សាឯកសារយោងដែលបានបង្ហាញនៅក្នុងសៀវភៅណែនាំនេះ។

ពេលដំណើរការសិក្ខាសាលា៖

ការបង្កើតបរិយាកាសសិក្ខាសាលា៖ សិក្ខាសាលាគឺពឹងផ្អែកទៅលើការចូលរួម ការប្រាស្រ័យទាក់ទង និងការសហការគ្នាយ៉ាងសកម្ម ពីសិក្ខាកាម ដូច្នេះវាជាការសំខាន់ណាស់ ក្នុងការបង្កើតបរិយាកាសសមរម្យ សម្រាប់សិក្ខាសាលា។

-នៅពេលចាប់ផ្តើមសិក្ខាសាលា វាចាំបាច់ណាស់ ដែលត្រូវរំលឹកអ្នកចូលរួមថា ពួកគេគឺជាផ្នែកនៃសហគមន៍អ្នកសិក្សា និងលើកទឹកចិត្តឱ្យពួកគេចូលរួមយ៉ាងសកម្ម។

- ដើម្បីជួយសម្រួលដល់ការប្រាស្រ័យទាក់ទងមានភាពរស់រវើក សិក្ខាកាមទាំងអស់ត្រូវបានណែនាំឱ្យបង្កើតបរិយាកាសអញ្ជើញចូលរួម ដូចជាការរៀបចំកៅអីជារង្វង់ ដើម្បីជំរុញឱ្យពួកគេចូលរួមនៅក្នុងការពិភាក្សាដោយចំហរ។

-វាត្រូវបានផ្តល់អនុសាសន៍ឱ្យប្រាស្រ័យ ទាក់ទងយ៉ាងច្បាស់ទៅកាន់អ្នកចូលរួមអំពីគោលដៅនៃសិក្ខាសាលា និងបង្ហោះការរំពឹងទុកឬគោលការណ៍ណែនាំទាំងនោះទៅក្នុងទីតាំងដែលងាយមើលឃើញដើម្បីជាការរំលឹក

- ការបង្ហាញស្នាដៃរបស់សិក្ខាកាម (ការសរសេរ ឬការគូរតាមរយៈការងារក្រុមឬសកម្មភាពសិក្ខាសាលា) ជួយបង្កើតនូវបរិយាកាសនៃការសិក្សា។

ការកសាងទំនាក់ទំនងសិក្ខាកាម៖ ដើម្បីឱ្យសិក្ខាកាមមានប្រាស្រ័យទាក់ទង និងចូលរួមសកម្ម វាជាការចាំបាច់ណាស់ដែលគ្រូឧទ្ទេសត្រូវតែបង្កើតនូវបទពិសោធន៍នៃការរៀនសូត្ររួមគ្នាជាមួយនឹងសិក្ខាកាម។ គ្រូឧទ្ទេសគួរទាក់ទងឱ្យបានជិតស្និទ្ធជាមួយសិក្ខាកាមដោយចាត់ទុកពួកគេជាជនស្លូតត្រង់ហើយត្រូវធ្វើសកម្មឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ លើសពីនេះគ្រូឧទ្ទេសត្រូវតែច្បាស់លាស់នៅពេលពន្យល់ ឬលម្អិតនូវអ្វីដែលចង់បញ្ចុះបញ្ចូលចង់ធ្វើការឆ្លើយតប និងចង់ផ្សារភ្ជាប់ទៅនឹងពេលវេលា។

**ការកំណត់លំហូរសិក្ខាសាលានិងការត្រៀមសម្រាប់ការផ្លាស់ប្តូរ៖** គ្រូឧទ្ទេសគួរតែមានស្មារតីទទួលខុសត្រូវលើលំហូរសិក្ខាសាលានិងឆ្លើយតបឱ្យបានត្រឹមត្រូវនៅពេលចាំបាច់។ ប្រសិនបើសិក្ខាសាលាប្រព្រឹត្តទៅតាមទិសដៅដែលមិនបានគ្រោងទុក (ឧ. វត្តមានសិក្ខាកាមតិច កិច្ចពិភាក្សាមានភាពក្តៅគគុក ម៉ោងសិក្ខាសាលានីមួយៗ មានការពន្យារពេល ឬក៏ត្រូវលុបចោលជាដើម ត្រូវតែសួរហេតុផលពីមូលហេតុ និងរកវិធីផ្សេងដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ។

**ការលើកកម្ពស់ការចូលរួមឱ្យមានភាពសកម្ម៖** ការចូលរួមយ៉ាងសកម្មពីសិក្ខាកាមគឺមានសារសំខាននៅក្នុងដំណើរការនៃសិក្ខាសាលា។

- វាមានសារៈសំខាន់ណាស់ដែលអ្នកចូលរួមបង្កើតទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនិងបង្កើត បរិយាកាសសហគមន៍ប្រកបដោយការទទួលខុសត្រូវនិងមានលក្ខណៈជាវិជ្ជមាន។ គ្រូឧទ្ទេសគួរលើកសិក្ខាកាមឱ្យបានញឹកញាប់ដើម្បីទទួលយកនូវគំនិត និងទស្សនៈផ្សេងៗ ដោយរក្សាអាកប្បកិរិយាប្រកបដោយការគោរព។

- គ្រូឧទ្ទេសគួរតែឆ្លើយតបជាវិជ្ជមានចំពោះយោបល់សិក្ខាកាម ហើយបើកចំហចំពោះឆន្ទៈក្នុងការចូលរួម។ លើកទឹកចិត្តសិក្ខាកាមទាំងអស់ឱ្យចូលរួមដោយមិនចាំបាច់ផ្ទាល់ ឬបង្ខំពេកនោះទេ។ វាមានសារៈសំខាន់ណាស់ដែលសិក្ខាកាមស្ម័គ្រចិត្តចូលរួមនៅក្នុងបរិយាកាសសុខស្រួល។

-ប្រសិនបើសិក្ខាកាមមានការលំបាកក្នុងការចូលរួមដោយសារតែអស់កម្លាំងត្រូវណែនាំពួកគេឱ្យសម្រាកដើម្បីជួយបន្ធូរភាពតានតឹងនិងអស់កម្លាំង។ លើសពីនេះ ការបញ្ចូលល្បែងសីក្សា ឬសកម្មភាពសំខាន់ៗអាចជួយជំរុញឱ្យមានការសប្បាយនិងការចាប់អារម្មណ៍។

**ការធានាពេលវេលាសម្រាប់ការចែករំលែក៖** នៅពេលដំណើរការសិក្ខាសាលា សកម្មភាព ឬការពន្យល់អាចចំណាយពេលយូរជាងការគ្រោងទុក ដែលនាំឱ្យមានការពន្យារពេលនៃកម្មវិធី។ ក្នុងកាលៈទេសៈបែបនេះ អាចមានការលំបាកក្នុងការកំណត់ពេលវេលាសម្រាប់សិក្ខាកាមក្នុងការឆ្លុះបញ្ចាំង និងចែករំលែកនូវអ្វីនូវអ្វីដែលពួកគេបានរៀន ឬបទពិសោធន៍ក្នុងអំឡុងពេលនៃវគ្គសិក្ខាសាលា។ ទោះជាយ៉ាងនេះក៏ដោយ វាជាការចាំបាច់ណាស់ត្រូវសិក្ខាកាមចែករំលែកគំនិតនិងបទពិសោធន៍របស់ពួកគេដើម្បីជួយឱ្យទទួលបាននូវចំណេះដឹងថ្មីៗ នឹងការយល់ដឹងកាន់តែស៊ីជម្រៅ។ ដូច្នេះនៅពេលប្រឈមនឹងការខ្វះខាតពេលពេលវេលាត្រូវផ្តល់ពេលវេលាចែករំលែកឱ្យខ្លី ប៉ុន្តែមានប្រសិទ្ធភាព។ អ្នកអាចឱ្យសិក្ខាកាមកត់ត្រាលើក្រដាសនូវគំនិតឆ្លុះបញ្ចាំងរបស់ពួកគេ ហើយដាក់បង្ហាញនូវកំណត់ត្រាទាំងនោះនៅលើជញ្ជាំង។

-

### សកម្មភាពតាមដានសិក្ខាសាលា

**ការចែករំលែកលទ្ធផលសិក្ខាសាលា៖** នៅចុងបញ្ចប់នៃសិក្ខាសាលា សម្ភារៈដូចជាឯកសារធ្វើបទបង្ហាញ និងរបាយការណ៍ត្រូវចែករំលែកដល់សិក្ខាកាម។ ការធ្វើដូច្នេះ វានឹងជួយដល់សិក្ខាកាមចងចាំនូវអ្វីដែលពួកគេបានរៀន និងបន្តសកម្មភាពតាមដានដល់ពួកគេ។

**ការបន្តបណ្តាញ៖** វាមានសារៈសំខាន់ណាស់ក្នុងការកសាងបណ្តាញដែលអ្នកចូលរួមសិក្ខាសាលាអាចបន្តធ្វើការជាមួយគ្នាបន្ទាប់ពីបញ្ចប់សិក្ខាសាលា។ សិក្ខាកាមជាច្រើន នឹងចាប់អារម្មណ៍ ក្នុងការប្រើប្រាស់នូវអ្វី ដែលពួកគេបានរៀន បន្ទាប់ពីសិក្ខាសាលា ហើយការចែករំលែកព័ត៌មាន និងបទពិសោធន៍របស់ពួកគេជាមួយសិក្ខាកាមផ្សេងទៀតនឹងបង្កើតឥទ្ធិពលរួមមួយ។ ជាពិសេស ផ្តល់ដល់សិក្ខាកាម នូវគម្រូសកម្មភាព និងសម្ភារៈរបស់សិក្ខាកាមដ៏ទៃជាច្រើន ដែលអាចឱ្យពួកគេកំណត់រចនាសម្ព័ន្ធឡើងវិញ និងប្រើប្រាស់វាឱ្យស្របនឹងតម្រូវការ ក៏ដូចជាស្ថានភាព។ការចែករំលែកដំបូន្មាន នឹងការលំបាករបស់ពួកគេនឹងជួយលើកកម្ពស់ការអនុវត្តសហគមន៍នៅក្នុងជំនាញរបស់គេ។

# តារាងមាតិកា

ជំពូក 1- ហេតុអ្វីបានមាន GCED ឥឡូវនេះ?..........09
ជំពូក 2- តើអ្វីជា GCED?..........19
ជំពូក 3- GCED តើបង្រៀនពីអ្វី?..........35
ជំពូក 4- តើត្រូវបង្រៀន GCED ដូចម្តេច?..........47
ជំពូក 5- ការរៀបចំសកម្មភាព..........47
ឧបសម្ព័ន្ធ..........47

-

# ជំពូកទី១៖

## ហេតុអ្វីបានជាមានGCED ឥឡូវនេះ?

# ជំពូកទី ១

## ហេតុអ្វីបានជាមាន GCED ឥឡូវនេះ?

**ទិដ្ឋភាពទូទៅ**

ជំពូកនេះណែនាំពីការកើនឡើងនៃការអភិវឌ្ឍការអប់រំភាពជាពលរដ្ឋសកល (GCED) ដែលជានិន្នាការចុងក្រោយបំផុតនៃការអប់រំ។ វាជារបៀបវារៈនៃការអភិវឌ្ឍសកល។ សិក្ខាកាមនឹងត្រូវរៀនពីបញ្ញត្តិគ្រឹះនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) និងការអប់រំភាពជាពលរដ្ឋសកល (GCED) ដែលជាសមាសធាតុសំខាន់ក្នុងរបៀបវារៈនៃការអប់រំសកល តាមបែបថ្មី។

**មេរៀន**

1. ការអប់រំភាពជាពលរដ្ឋសកលជាចក្ខុវិស័យថ្មីមួយនៃការអប់រំ
2. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) & GCED

**លទ្ធផលរំពឹងទុក**

1. យល់ពី GCED ក្នុងការផ្លាស់ប្តូរចុងក្រោយបំផុតនៃការអប់រំសកល និងរបៀបវារៈនៃការអភិវឌ្ឍសកល
2. ស្វែងយល់អំពី GCED នៅក្នុងបរិបទនៃ SDGs

**ដំណើរការបង្រៀន**

1. ចាប់ផ្តើម (៣០ នាទី)
   - [សកម្មភាព] បញ្ហាប្រឈមទូទៅដែលយើងជួបប្រទះ
2. រៀនពីខ្លឹមសារ (៦០ នាទី)
   - ការអប់រំភាពជាពលរដ្ឋសកលៈ ការអប់រំតាមការផ្លាស់ប្តូរដែលយើងត្រូវការ
   - របៀបវារៈនៃការអប់រំ និងការអភិវឌ្ឍសកល
   - ការយល់ដឹងអំពី GCED នៅក្នុង SDG 4
3. ការឆ្លុះបញ្ចាំង/សង្ខេប (៣០ នាទី)
   - [សកម្មភាព] ការពិភាក្សាក្រុម Buzz

**ឯកសារយោង**


- អង្គការសហប្រជាជាតិ។ "ការផ្លាស់ប្តូរពិភពលោករបស់យើង៖ របៀបវារៈឆ្នាំ 2030សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព " សេចក្តីសម្រេចចិត្តដែលអនុម័តដោយមហាសន្និបាតឆ្នាំ 2015 ។
- អង្គការយូណេស្កូការអប់រំឆ្នាំ 2030៖ សេចក្តីប្រកាស Incheon និងក្របខ័ណ្ឌសកម្មភាពសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព 4. 2015
- អង្គការយូណេស្កូ។ "ការគិតឡើងវិញពីការអប់រំ៖ ឆ្ពោះទៅរកផលប្រយោជន៍រួមសកល?" ឆ្នាំ 2015 ។

**ជំពូកទី១**

**ហេតុអ្វីបានជាត្រូវមាន GCEDនៅពេលនេះ?**

## ជាកិច្ចចាប់ផ្ដើម

រយៈពេល៖ ៤០ នាទី

វត្ថុបំណង៖ - លើកកម្ពស់ការដឹង និងយល់ពីពិភពលោកដែលយើងកំពុងរស់នៅ ហើយកាន់តែចម្លែក និងមានភាពស្មុគស្មាញ

-យល់ពីតម្រូវការសម្រាប់ការអប់រំឱ្យមានការផ្លាស់ប្តូរ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ពិភពលោកដែលកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។

ក្នុងនាមជាពលរដ្ឋនៃពិភពលោកម្នាក់ យើងមានសិទ្ធិ និងទំនួលខុសត្រូវក្នុងការដឹង និងស្វែងយល់អំពីពិភពលោកដែលយើងរស់នៅ។ ខណៈពេលដែលមានឱកាសកាន់តែច្រើនឡើងសម្រាប់យើងក្នុងការធ្វើឱ្យពិភពលោកកាន់តែប្រសើរឡើង បញ្ហាប្រឈមជាច្រើនដែលយើងជួបប្រទះក៏កាន់តែមានស្មុគស្មាញ និងលំបាកទៅៗផងដែរ។

សកម្មភាព៖ បញ្ហាប្រឈមដែលយើងជួបប្រទះជាទូទៅ

### តើត្រូវធ្វើអ្វីបន្តទៀត?

1. ឱ្យសិក្ខាកាមគិតអំពីអត្ថបទព័ត៌មានមួយចំនួនដែលពួកគេបានអាន ឬតាមរយៈទម្រង់ប្រព័ន្ធផ្សព្វផ្សាយថ្មីៗផ្សេងទៀត។ ប្រាប់ពួកគេឱ្យលើកយកបញ្ហាចំនួនបីដែលអាចដោះស្រាយក្នុងកម្រិតតំបន់ ឬសកល ហើយសរសេរវានៅលើក្រដាសផុសអ៊ិត។

**បញ្ហាចំនួនបី៖**

i.…………………………………………………………………………………………

ii.…………………………………………………………………………………………

iii.…………………………………………………………………………………………

**ឧទាហរណ៍៖**

- ការកើនឡើងជនចំណាកស្រុក និងជម្លោះនៅក្នុងសហគមន៍
- ការបំផ្លិចបំផ្លាញអេកូឡូស៊ី៖ទឹកជំនន់ ការកាប់បំផ្លាញព្រៃឈើ ការកើនឡើងនីវ៉ូទឹកសមុទ្រ ។ល។

-អត្រាយុវជនអត់ការងារធ្វើខ្ពស់

2. ឱ្យសិក្ខាកាមបិទក្រដាសផុសអ៊ីតចម្លើយនៅលើក្ដារខៀន ឬជញ្ជាំង ដើម្បីឱ្យសិក្ខាកាមដទៃទៀតបានឃើញគ្រប់ៗគ្នា។
3. ឱ្យសិក្ខាកាមចែករំលែកក្នុងក្រុមនូវអ្វីដែលពួកគេគិត/ឬមានអារម្មណ៍អំពីបញ្ហាទាំងនោះ រួមទាំង បទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងបញ្ហា និងអ្វីដែលពួកគេបានកត់សម្គាល់ថាមានលក្ខណៈទូទៅដូចគ្នាក្នុងចំណោមបញ្ហាទាំងនោះ។
4. ទុកពេលឱ្យសិក្ខាកាមគិតពីរបៀបដោះស្រាយបញ្ហាដែលសហគមន៍មូលដ្ឋាន និងសហគមន៍ពិភពលោករបស់ពួកគេកំពុងជួបប្រទះ។ សួរពួកគេថាតើបញ្ហាក្នុងតំបន់ (ឬបញ្ហាមូលដ្ឋាន) វាទាក់ទងនឹងបញ្ហាសកលលោករបៀបណា ហើយថាតើវាប៉ះពាល់ដល់គ្នាទៅវិញទៅមកយ៉ាងដូចម្តេច? (ឧទាហរណ៍៖ ការកើនឡើងនៃជម្លោះរវាងជនភៀសខ្លួន និងសមាជិកសហគមន៍ក្នុងមូលដ្ឋាន - តើជម្លោះនេះវាទាក់ទងនឹងជម្លោះកម្លាំងប្រដាប់អាវុធនិងវិបត្តិពិភពលោកយ៉ាងដូចម្តេច?)
5. សួរសិក្ខាកាម ថាតើពួកគេគិតថាប្រព័ន្ធអប់រំបច្ចុប្បន្ននៅក្នុងសហគមន៍ ឬប្រទេសរបស់ពួកគេ គ្រប់គ្រាន់ ដើម្បីបណ្តុះយុវជនជំនាន់ក្រោយ អំពីរបៀបទប់ទល់នឹងបញ្ហាប្រឈមរបស់ពិភពលោកដែលពួកគេរស់នៅ។

**កំណត់ចំណាំរបស់គ្រូឧទ្ទេស**

មេរៀននេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់ឱ្យសិក្ខាកាម នូវពេលវេលា ដើម្បីគិតអំពីពិភពលោកដែលពួកគេរស់នៅ ដឹងពីភាពស្មុគស្មាញនិងភាពចម្លែកនៃពិភពលោក និងគិតអំពីតួនាទីនៃការអប់រំក្នុងការណែនាំយុវជនជំនាន់ក្រោយ អំពីរបៀបរស់នៅក្នុងពិភពលោកដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងពោរពេញទៅដោយបញ្ហាប្រឈម។ សូមកុំប្រាប់គំនិតខ្លួនឯងដល់សិក្ខាកាម! ហើយជំនួសមកវិញដោយការព្យាយាមទាញគំនិតពួកគេភ្ជាប់វាទៅនឹងដំណោះស្រាយលក្ខខណ្ឌពិភពលោក ដើម្បីឱ្យសិក្ខាកាមអាចដឹងពីតម្រូវការសម្រាប់គំនិតផ្តួចផ្តើមការអប់រំឱ្យមានការផ្លាស់ប្តូរទាំងនេះ។

វាអាចជួយបានច្រើនប្រសិនជាទុកពេលគ្រប់គ្រាន់ឱ្យសិក្ខាកាមធ្វើការពិភាក្សាគ្នា និងពិនិត្យមើលពីអន្តរកម្មបញ្ហា 'ក្នុងតំបន់ និងសកលលោក' តាមរយៈឧទាហរណ៍ ឬបញ្ហាជាក់ស្តែង ដែលសិក្ខាកាមជួបប្រទះនិងមានបទពិសោធន៍ដោយផ្ទាល់។ បន្ទាប់មក ដឹកនាំការពិភាក្សាទៅកាន់តួនាទីនៃការអប់រំក្នុងបរិបទសកលដែលមានទំនាក់ទំនងគ្នាខ្ពស់ក្នុងពិភពដែលយើងរស់នៅ។

**ជំពូកទី១**
**ហេតុអ្វីបានជាត្រូវមាន GCED នៅពេលនេះ?**

## ខ្លឹមសារមេរៀន

រយៈពេល៖ ៨០ នាទី

វត្ថុបំណង៖ - ដើម្បីយល់ពីរបៀបដែល GCED ក្លាយជាផ្នែកមួយនៃរបៀបវារៈការអប់រំសកល
-ដើម្បីយល់ពីរបៀបដែល GCED ទាក់ទងទៅនឹងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)

ការអប់រំតាពជាពលរដ្ឋសកល៖ ការអប់រំឱ្យមានការផ្លាស់ប្តូរដែលយើងត្រូវការ

តើអ្វីដែលយើងត្រូវធ្វើ?៖ សូមប្រើឧបករណ៍ជំនួយដែលអាចមើលបាន(ឧ.ស្លាយ power point ឬវីដេអូ) ដើម្បីជួយក្នុងការពន្យល់ ថាហេតុអ្វីបានជាយើងត្រូវការការអប់រំ ដែលនាំឱ្យមានការផ្លាស់ប្តូរបែបថ្មី។

ដោយសារយើងដឹងកាន់តែច្បាស់អំពីភាពស្មុគស្មាញ និងភាពផ្ទុយគ្នាកាន់តែខ្លាំងឡើងនៅក្នុងពិភពលោករបស់យើងសព្វថ្ងៃ យើងត្រូវតែគិតឡើងវិញអំពីតួនាទី និងភាពឆ្លើយតបនៃប្រព័ន្ធអប់រំរបស់យើង។ យើងត្រូវការ ការអប់រំដែលនាំឱ្យមានការផ្លាស់ប្តូរហើយអាចជួយមនុស្សឱ្យធ្វើជាម្ចាស់នៃការពិត និងធ្វើជាម្ចាស់នូវការទាមទាររបស់សង្គមដែលកំពុងតែមានការផ្លាស់ប្តូរយ៉ាងលឿន។ យើងត្រូវការ ការអប់រំដែលមិនត្រឹមតែទទួលបានចំណេះដឹងនិងជំនាញថ្មីប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានគុណតម្លៃជីវិត និងភាពសុខដុមរមនាក្នុងសង្គមដែលមានពិភពចម្រុះផងដែរ។

> *“ការអប់រំល្អគឺច្រើនជាងចំណុចចូលទៅក្នុងទីផ្សារការងារ។ ការអប់រំគឺមានថាមពលដើម្បីផ្លាស់ប្តូរមនុស្ស និងនាំមកនូវតម្លៃរួមដល់ជីវិត។ នៅពេលប្រឈមមុខនឹង ជំងឺរាតត្បាតសកល ជម្លោះ ការប្រែប្រួលអាកាសធាតុ និងភាពចលាចលសេដ្ឋកិច្ច វាច្បាស់ណាស់ថាយើងត្រូវរួមសុខរួមទុក្ខ ឬហែលឆ្លងជាមួយគ្នា។ យើងត្រូវបង្កើតវិធីថ្មីក្នុងការទាក់ទងគ្នាទៅវិញទៅមក - ជាលក្ខណៈបុគ្គលក្តី ជាលក្ខណៈសហគមន៍ក្តី និងជាលក្ខណៈប្រទេស។ ការអប់រំអាចបណ្តុះបណ្តាលយើងឱ្យមើលឃើញនូវចក្ខុវិស័យមួយដែលលើសពីការគិតភ្លាមៗ”*

*(អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន (គំនិតផ្តួចផ្តើមដំបូងនៃការអប់រំសកល ឆ្នាំ២០១២)។*

## ការអប់រំភាពជាពលរដ្ឋសកល (GCED)៖ ការអប់រំនាំឱ្យមានការផ្លាស់ប្តូរដែលពិភពលោកត្រូវការ

ការអប់រំភាពជាពលរដ្ឋសកល (GCED) គឺជាការឆ្លើយតបទៅនឹងការអំពាវនាវឱ្យមានការអប់រំដែលមានភាពឆ្លើយតបបន្ថែមទៀត។ GCED គឺជាការអប់រំដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងគោលបំណងអភិវឌ្ឍចំណេះដឹង ជំនាញ គុណតម្លៃ និងអាកប្បកិរិយាដែលអ្នកសិក្សាត្រូវការដើម្បីធ្វើឱ្យពិភពលោកកាន់តែយុត្តិធម៌ សន្តិភាព និងនិរន្តរភាព។

## ការអប់រំដែលយើងត្រូវការ

- ***ការបង្រៀនឱ្យមានការគោរពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្ស***

ដើម្បីទប់ទល់នឹងបញ្ហាប្រឈមដ៏ស្មុគស្មាញនៃពិភពលោកនាពេលបច្ចុប្បន្ននេះ ការអប់រំមិនគួរត្រូវបានគេកំណត់ត្រឹមតែការបង្រៀនសិស្សឱ្យចេះអាន ចេះសរសេរ និងចេះគណនានោះទេ។ ជាមួយនឹងការកើនឡើងនូវភាពអយុត្តិធម៌ដែលប្រព្រឹត្តចំពោះខ្លួនឯង អ្នកដទៃ និងធម្មជាតិ ចាំបាច់ត្រូវបង្រៀនក្មេងៗជំនាន់ក្រោយឱ្យទទួលបាននូវការគោរពជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

- ***ការលើកតម្កើងតម្លៃជាសកល និងអបអរសាទរភាពចម្រុះ***

ថ្ងៃនេះ មនុស្សកាន់តែច្រើនឡើងៗដែលមានទស្សនៈពិភពលោកផ្សេងគ្នា កំពុងរស់នៅជាមួយគ្នាពាសពេញពិភពលោក។ យើងត្រូវការប្រភេទនៃការអប់រំមួយ ដែលបង្រៀនមនុស្សឱ្យចេះរស់នៅជាមួយគ្នា។ បំផុសគំនិតពួកគេ ឱ្យទទួលយកតម្លៃជាសកលនៃសិទ្ធិមនុស្ស យុត្តិធម៌សង្គម ការគោរព ការលើកកម្ពស់វប្បធម៌ចម្រុះគ្នា និងការចែករំលែកអារម្មណ៍សាមគ្គីភាព។ អ្នកសិក្សា គួរត្រូវបានបង្រៀនពីរបៀបគិតត្រិះរិះពិចារណា ច្រានចោលការលំអៀង និងភាពមិនច្បាស់លាស់ ហើយដឹងថា ភាពចម្រុះ បង្រៀនយើងពីវិធីជាច្រើននៃការយល់ដឹងអំពីពិភពលោក។ អាស្រ័យហេតុនេះ នៅពេលដែលពួកគេយល់ពីអត្តសញ្ញាណច្រើនកម្រិត ក៏ដូចជាអ្នកដែលនៅជុំវិញខ្លួន ពួកគេនឹងអាចដឹងពីអត្តសញ្ញាណរួមរបស់មនុស្សជាតិ។ មនុស្សជាតិដែលបានចែករំលែកនេះ លុបបំបាត់បាននូវភាពខុសគ្នាទាក់ទងនឹងបុគ្គល វប្បធម៌ សាសនា ជនជាតិ និងអ្វីៗជាច្រើនទៀត។

- ***ការលើកកម្ពស់ភាពទទួលខុសត្រូវចំពោះសហគមន៍សកល***

នៅពេលយើងយល់ដឹងពីមនុស្សជាតិរួមរបស់យើង យើងត្រូវការការអប់រំមួយប្រភេទដែលលើកកម្ពស់ការទទួលខុសត្រូវរួមសម្រាប់អនាគតរួមរបស់យើង។ យើងមិនគួរបង្រៀនមនុស្សឱ្យប្រាថ្នាចង់បានតែ 'ជីវិតល្អ' ក្នុងនាមជាបុគ្គលនោះទេ ប៉ុន្តែយើងគួរបង្រៀនមនុស្សឱ្យធ្វើអំពើល្អ និងមានភាពយុត្តិធម៌សម្រាប់មនុស្សជាតិ និងភពផែនដីទាំងមូលផងដែរ។ នៅពេលយើងចាប់ផ្តើមយល់ពីរបៀបដែលការពឹងពាក់គ្នាទៅវិញទៅមកនៃកម្លាំងក្នុងតំបន់ និងពិភពលោកមានឥទ្ធិពលលើអនាគតរួមគ្នារបស់យើង ការប្តេជ្ញាចិត្តរបស់យើង ក្នុងការធ្វើសកម្មភាពប្រកបដោយទំនួលខុសត្រូវនៅគ្រប់កម្រិត នឹងមានការកើនឡើង។ ការធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ មានន័យថា ក្រោកឈរឡើងប្រឆាំងនឹងអំពើហឹង្សា ការគាបសង្កត់ ការមិនអត់ឱន ការរើសអើង និងការមិនរាប់បញ្ចូល។ អភិវឌ្ឍជំនាញសម្រាប់ជីវិតដ៏មានន័យ និងថ្លៃថ្នូរ; និងបង្កើតនូវមធ្យោបាយប្រកបដោយនិរន្តរភាព ក្នុងការលើកកម្ពស់ស្តង់ដារស់នៅដោយមិនបំផ្លាញបរិស្ថាន។ ដោយសារតែភាពស្មុគស្មាញនៃបញ្ហាដែលប៉ះពាល់ដល់ពិភពលោករបស់យើង អារម្មណ៍នៃទំនួលខុសត្រូវរួមគ្នានេះក៏គួរតែជំរុញមនុស្ស និងស្ថាប័នឱ្យបង្កើតភាពជាដៃគូ ឬពង្រឹងអ្នកដែលមានស្រាប់ផងដែរ។ ភាគីពាក់ព័ន្ធទាំងអស់ - រួមទាំងរដ្ឋាភិបាល ធុរកិច្ច សង្គមស៊ីវិល អ្នកអប់រំ និងសិស្ស ត្រូវតែពិភាក្សាអំពីរបៀបដែលពួកគេអាចធ្វើការជាមួយគ្នា និងដើរតួនាទីយ៉ាងសកម្មក្នុងការយកឈ្នះលើបញ្ហាប្រឈមនៅក្នុងសង្គម និងពិភពលោករបស់យើងនាពេលបច្ចុប្បន្ន។

*- ការផ្សារភ្ជាប់ជាមួយព្រំដែននៃចំណេះដឹងថ្មី*

ព្រំដែនចំណេះដឹងថ្មីៗកំពុងលេចឡើងឥតឈប់ឈរ។ ជាឧទាហរណ៍ ការអភិវឌ្ឍន៍អ៊ីនធឺណែត និងបច្ចេកវិទ្យាឌីជីថលពង្រីកលទ្ធភាពនៃការរៀនសូត្ររបស់យើង។ ភាពជឿនលឿនក្នុងវិទ្យាសាស្ត្រសរសៃប្រសាទក៏ផ្តល់ឱ្យយើងនូវការយល់ដឹងអំពីដំណើរការខួរក្បាលដ៏ល្អប្រសើរផងដែរ។ ប្រភពថាមពលជំនួសកាន់តែច្រើនកំពុងត្រូវបានរកឃើញ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។ អ្វីដែលសំខាន់ជាងរបកគំហើញបច្ចេកវិទ្យាទាំងនេះគឺមនុស្សជំនាន់ក្រោយស្ថិតនៅជួរមុខនៃការបង្កើតថ្មីទាំងនេះ។ យុវជនសម័យឥឡូវលែងស្រូបយកព័ត៌មានដែលពួកគេទទួលបាននៅសាលាទៀតហើយ។ ពួកគេជាអ្នកកាន់ព្រំដែនចំណេះដឹង ចូលរួមយ៉ាងសកម្មក្នុងការបង្កើតចំណេះដឹងថ្មីៗតាមរបៀបដែលយើងមិនធ្លាប់មានពីមុនមក។ ចំណេះដឹងកាន់តែមានសម្រាប់មនុស្សគ្រប់គ្នា ជាជាងសម្រាប់តែមនុស្សមួយចំនួន។

ជំពូកទី១
ហេតុអ្វីបានជាត្រូវមាន GCED នៅពេលនេះ?

*ខ្លឹមសារដែលត្រូវរៀន*

## ការអប់រំសាកល និងរបៀបវារៈអភិវឌ្ឍន៍

**អ្វីដែលត្រូវធ្វើ៖** ប្រើឧបករណ៍ជំនួយ (ឧ. ស្លាយ PowerPoint វីដេអូ) ដើម្បីជួយណែនាំរបៀបវារៈនៃការអប់រំសាកលទៅដល់សិក្ខាកាម។

ទទួលស្គាល់តួនាទីសំខាន់នៃការអប់រំក្នុងការផ្លាស់ប្តូរពិភពលោក អ្នកពាក់ព័ន្ធសំខាន់ៗដែលមកពីវិស័យផ្សេងៗគ្នា រួមមាន៖ រដ្ឋាភិបាល សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល មកពីជុំវិញពិភពលោក ដែលប្រមូលផ្តុំគ្នាក្នុងក្នុងកិច្ចប្រជុំពិភពលោកជាទៀងទាត់។ ពួកគេរួមគ្នាបង្កើតរបៀបវារៈនៃការអប់រំសកលដ៏សាមញ្ញ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់អនាគត។

របៀបវារៈនៃការអប់រំជាសាកលបានផ្លាស់ប្តូរក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ដោយចាប់ផ្តើមពីការអប់រំសម្រាប់ទាំងអស់គ្នា (EFA) (1990-2015) ដែលត្រូវបានដាក់ឱ្យដំណើរការនៅទីក្រុង Jomtien ប្រទេសថៃ និងថ្មីៗនេះ ត្រូវបានដាក់ទៅក្នុងការអប់រំឆ្នាំ 2030 (2015-2030) ដែលត្រូវបានអនុម័តនៅទីក្រុង Incheon សាធារណៈរដ្ឋកូរ៉េ។ តើរបៀបវារៈនៃការអប់រំជាសាកលទាំងនេះផ្តោតលើអ្វី? តើ GCED បានក្លាយជាផ្នែកមួយនៃរបៀបវារៈនេះដោយរបៀបណា? សូមតាមដានដោយលម្អិតអំពីរបៀបដែល GCED បានក្លាយជារបៀបវារៈដ៏សំខាន់នៅក្នុងសហគមន៍អប់រំពិភពលោក។

**កាលបរិច្ឆេទនៃរបៀបវារៈការអប់រំសកល**

| ទីតាំង/ឆ្នាំ | 1990 Jomtien ប្រទេសថៃ | 2000 Dakar ប្រទេសសេណេហ្គាល់ | កញ្ញា 2000 ញូយ៉ក សហរដ្ឋអាមេរិក | 2012 | 2015 Incheon សាធារណៈរដ្ឋកូរ៉េ | កញ្ញា 2015 Incheon ញូយ៉កសហរដ្ឋអាមេរិក | កក្កដា 2017 |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| លើកពីរបៀបវារៈ | ការអប់រំសម្រាប់ទាំងអស់គ្នា (EFA) ប្រកាសជាផ្លូវការក្នុងសន្និសិទ្ធអប់រំពិភពលោក | រង្វាយតម្លៃការអប់រំសម្រាប់ទាំងអស់គ្នានិងការកែលម្អគោលដៅប្រារព្ធធ្វើនៅក្នុងវេទិកាអប់រំពិភពលោក | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) ប្រកាសជាផ្លូវការនៅក្នុងវេទិកាសន្និសិទ្ធសហសវត្សរ៍របស់អង្គការពិភពលោក | គំនិតផ្តួចផ្តើមការអប់រំជាសាកលជាលើកដំបូងបានចាប់ផ្តើម | ការអប់រំឆ្នាំ2030 បានចាប់ផ្តើមនៅក្នុងវេទិកាអប់រំពិភពលោក | របៀបវារៈឆ្នាំ 2030 សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបានបើកដំណើរការនៅក្នុងកិច្ចប្រជុំកំពូលស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ | ក្របខ័ណ្ឌសូចនាករសកលសម្រាប់ SDGs និងគោលដៅនៃរបៀបវារៈឆ្នាំ 20230 បានអនុម័តនៅមហាសន្និបាតអង្គការសហប្រជាជាតិ |
| GCED ជារបៀបវារៈសកល | | | | GCED ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំងបី | GCED ជាផ្នែកមួយនៃរបៀបវារៈក្រោយឆ្នាំ 2025 | GCED មានចែងក្នុងគោលដៅ SDG 4.7 | សូចនាករជោគជ័យនៃGCED ត្រូវបានអនុម័ត |

**សម្គាល់៖ ពណ៌ស្វាយតំណាងឱ្យរបៀបវារៈនៃការអប់រំសកល ហើយពណ៌លឿងតំណាងឱ្យរបៀបវារៈនៃការអភិវឌ្ឍសកល។ របៀបវារៈនៃការអប់រំសកល មានឥទ្ធិពលលើវិមាត្រអប់រំនៃរបៀបវារៈការអភិវឌ្ឍសកលនីមួយៗ។*

*សូមមើលឧបសម្ព័ន្ធទី 1 សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ជីរបៀបវារៈនៃការអប់រំសកល។*

## កំណាត់សម្គាល់សម្រាប់គ្រូឧទ្ទេស

មេរៀននេះមានគោលបំណងជួយដល់សិក្ខាកាមឱ្យយល់ពីមូលដ្ឋានគ្រឹះ និងសារៈសំខាន់នៃការអប់រំភាពជាពលរដ្ឋសកល (GCED)។ ដូច្នេះ គ្រូឧទ្ទេសគួរតែអាចពន្យល់ពីគោលគំនិតជាមូលដ្ឋាន និងព្រឹត្តិការណ៍សំខាន់ៗក្នុងការអប់រំជាសាកល ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាដើម។

យើងសូមណែនាំដល់គ្រូឧទ្ទេស សូមបង្ហាញសិក្ខាកាមនូវលំហូររួម តាមរយៈការប្រើប្រាស់ដ្យាក្រាម និងពាក្យគន្លឹះប្រកបដោយប្រសិទ្ធភាព ជាជាងការពន្យល់លម្អិតគ្រប់យ៉ាង។ នេះ គឺដោយសារសិក្ខាកាមត្រូវបានសន្មត់ថាមិនទាន់ស៊ាំនឹងខ្លឹមសារមេរៀន ហើយក៏មិនត្រូវនិយាយថា វាអាចត្រូវការពេលវេលាសម្រាប់ពួកគេ ដើម្បីយល់ពីទិដ្ឋភាពរួមនៃនិន្នាការថ្មីៗនៅក្នុងការអប់រំជាលក្ខណៈសកល ដែរ។

ចុងក្រោយ វាមានសារៈសំខាន់ណាស់សម្រាប់គ្រូឧទ្ទេសក្នុងការកែលម្អខ្លឹមសារ ដើម្បីឱ្យវាស៊ីគ្នានឹងបរិបទរបស់សិក្ខាកាមដោយការណែនាំនូវផ្នែកទាំងឡាយដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធបំផុតចំពោះពួកគេ។ នៅក្នុងប្រទេសភាគច្រើន មានគោលនយោបាយអប់រំដែលឆ្លុះបញ្ចាំង និងភ្ជាប់ទៅនឹង SDGs។ គ្រូឧទ្ទេសត្រូវបានណែនាំឱ្យមានការចូលរួមពីសិក្ខាកាមក្នុងការកំណត់អត្តសញ្ញាណ និងការអនុវត្តគោលនយោបាយជាតិ ឬគោលនយោបាយមូលដ្ឋានរបស់ពួកគេទៅលើ SDGs ។

## ការយល់ដឹងអំពី GCED នៅក្នុង SDG4

អ្វីដែលត្រូវធ្វើ៖ ប្រើឧបករណ៍ជំនួយដែលអាចមើលឃើញ (ឧ. ស្លាយ PowerPoint វីដេអូ) ដើម្បីជួយណែនាំពីរបៀបវារៈនៃការអប់រំសាកលដល់សិក្ខាកាម។

មុនពេលពិភាក្សាអំពីស្លាយ អ្នកអាចចាប់ផ្តើមមេរៀនដោយឱ្យសិក្ខាកាមមើលវីដេអូខាងក្រោម។

1. SDG 4 និងគោលដៅទាំង10

(https://www.youtube.com/watch?v=V24JzUPlR44)

2. អ្វីទៅជា SDG 4 និងអ្វីដែលអ្នកអាចធ្វើវាបាន?

https://www.youtube.com/ watch?v=tJ8CMUIjcLc&t=29s

3. GCED និងការរៀនរស់នៅជាមួយគ្នា

https://www.youtube.com/watch?v=KuKzq9EDt-0

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ប្រទេសនានាបានអនុម័តនូវគោលដៅមួយដើម្បីបញ្ចប់ភាពក្រីក្រ ការពារភពផែនដី និងធានាភាពរុងរឿងសម្រាប់ទាំងអស់គ្នា ដែលជាផ្នែកមួយនៃរបៀបវារៈក្នុងការអភិវឌ្ឍនិរន្តរភាពបែបថ្មី (ការផ្លាស់ប្តូរតាមបែបវិជ្ជមានសម្រាប់ពិភពលោកយើង: របៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០)។ ។ របៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មាន17 មានចំណុចដៅចំនួន១៦៩ គោលដៅ ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០៣០ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់សហគមន៍ពិភពលោកមូល។



**ជំពូកទី១**
**ហេតុអ្វីបានជាត្រូវមាន GCED នៅពេលនេះ?**

ខ្លឹមសារមេរៀន

**SDG 4: ការអប់រំប្រកបដោយគុណភាព**




SDG 4: ធានាឱ្យការអប់រំមានគុណភាព សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ក្នុងចំណោម របៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទាំង17 ការអប់រំគឺជាគោលដៅដែលឈរតែឯង (SDG4) - ការអប់រំប្រកបដោយគុណភាព។ គោលបំណងសំខាន់នៃ SDG4 គឺដើម្បី "ធានាបាននូវការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព 4.7 និងការអប់រំភាពជាពលរដ្ឋសកល**

ការអប់រំភាពជាពលរដ្ឋសកល (GCED) ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុង SDG4 ជាគោលដៅទី 4.7 ។ បើទោះបីជា GCED មានរួចហើយក្នុងទម្រង់ និងការអនុវត្តផ្សេងៗគ្នាអស់រយៈពេលជាយូរក៏ដោយ ក៏សំណើ GCED ដែលជាផ្នែកមួយនៃ SDGs គឺមានការទទួលស្គាល់យ៉ាងច្បាស់ និងជាសមូហភាពនៃការអប់រំដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

ចំណុចដៅ4.7



នៅត្រឹមឆ្នាំ 2030 ត្រូវធានាឱ្យបានថា អ្នកសិក្សាទាំងអស់ ទទួលបានចំណេះដឹងនិងជំនាញដែលត្រូវការ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយរួមបញ្ចូលទាំងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព របៀបរស់នៅប្រកបដោយនិរន្តរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាពនិងអហិង្សាជាសកល

ភាពជាពលរដ្ឋសកល ការដឹងគុណចំពោះភាពចម្រុះនៃវប្បធម៌ និងការរួមចំណែករបស់វប្បធម៌គ្រប់ជាតិសាសន៍ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។

ចំណុចដៅ 4.7 ទទួលស្គាល់ពីសារសំខាន់នៃការអប់រំឱ្យមានការផ្លាស់ប្តូរឆ្ពោះទៅរកការទទួលបានការអប់រំប្រកបដោយគុណភាព។ វារួមបញ្ចូលវិធីសាស្ត្រផ្សេងៗក្នុងការអប់រំឱ្យមានការផ្លាស់ប្តូរ រួមទាំងការអប់រំភាពជាពលរដ្ឋសកល (GCED) ដែលបង្រៀនមនុស្សពីរបៀបក្លាយជាពលរដ្ឋដែលមានទំនួលខុសត្រូវលើពិភពលោក។ ភាពប្លែកនៃវិធីសាស្ត្ររបស់ GCED អាចជួយឱ្យអ្នកសិក្សាមានចំណេះដឹង គុណតម្លៃ និងជំនាញដែលពាក់ព័ន្ធ ដើម្បីក្លាយជាពលរដ្ឋដែលមានទំនួលខុសត្រូវ អាចយល់ពីបញ្ហាសកល និងតំបន់ ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង និងដោះស្រាយបញ្ហាប្រឈមជាសកល។

## ការកត់ចំណាំរបស់គ្រូឧទ្ទេស

ជំពូកនេះផ្តល់នូវព័ត៌មានជាមូលដ្ឋាននៃ GCED ដែលជាផ្នែកមួយក្នុងរបៀបវារៈនៃការអប់រំសកល។ គ្រូឧទ្ទេសត្រូវតែមានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់អំពី GCED និងរបៀបវារៈពាក់ព័ន្ធរបស់វា។ សូមមើលឧបសម្ព័ន្ធទី 2 សម្រាប់អត្ថបទសង្ខេប ហើយនៅពេលចាំបាច់ អ្នកអាចចែករំលែកវាជាមួយសិក្ខាកាម។

### ការឆ្លុះបញ្ចាំង និងបូកសរុប

| | |
|---|---|
| **រយៈពេល** | ៨០នាទី |
| **វត្ថុបំណង** | -ដើម្បីស្វែងយល់ពីមូលហេតុដែល GCED ក្លាយជាផ្នែកមួយនៃរបៀបវារៈក្នុងការអប់រំសកល<br>- -ដើម្បីស្វែងយល់ពីមូលហេតុដែល GCED មានទំនាក់ទំនងទៅនឹងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) |

### សកម្មភាព៖ ការពិភាក្សាក្រុមតូចៗ

### ជំហានទី១៖

1. បែងចែកសិក្ខាកាមជាក្រុមតូចៗពី៣ទៅ៤ក្រុមអាស្រ័យលើប្រធានបទពិភាក្សាផ្សេងៗគ្នា។ ប្រធានបទទាំងនោះរួមមាន "វិស័យដែលបន្ទាន់បំផុតសម្រាប់ការផ្លាស់ប្តូរនៅក្នុងអប់រំ", "អ្វីទៅជាការអប់រំដែលនាំឱ្យមានការផ្លាស់ប្តូរ?" "តើអ្វីដែលនៅខ្វះចន្លោះក្នុង SDGs?" និង "លក្ខណៈ

សំខាន់ៗនៃ SDG4"។ ទុកពេលឱ្យក្រុមនីមួយៗធ្វើការពិភាក្សាលើប្រធានបទដែលបានផ្តល់ឱ្យ។




2. ទុកឱ្យសិក្ខាកាមពិភាក្សាអំពីគំនិត និងការយល់ឃើញរបស់ពួកគេទៅលើប្រធានបទដែលបានផ្តល់ឱ្យ ហើយនៅពេក្នុងករណីចាំបាច់ ត្រូវធ្វើអន្តរាគមន៍ ឬផ្តល់គោលការណ៍ណែនាំជាក់ស្តែងបន្ថែមទៀតជាមួយនឹងព័ត៌មានដែលទាក់ទង (សូមមើលឯកសារស្តីពី SDGs និងឯកសារផ្សេងៗទៀត)។ សិក្ខាកាមមិនចាំបាច់ផ្តល់ចម្លើយត្រឹមត្រូវទេ ហើយមានសេរីភាពក្នុងការផ្តល់សំណួរបន្ថែម ឬចែករំលែកផ្នែកដែលត្រូវការការបញ្ជាក់បន្ថែមពីអ្នកសម្របសម្រួលឬអ្នកដែលមានស្នាដៃផ្តើម។
3. បន្ទាប់មកក្រុមនីមួយៗចែករំលែកលទ្ធផលនៃការពិភាក្សារបស់ពួកគេជាមួយអ្នកចូលរួមទាំងអស់

# ជំពូកទី២
# តើ GCED ជាអ្វី?

## ជំពូក ២៖ អ្វីទៅជា GCED?

| | |
|---|---|
| ទិដ្ឋភាពទូទៅ | នៅក្នុងជំពូកនេះ សិក្ខាកាមនឹងទទួលបានការយល់ដឹងអំពីអ្វីទៅជាការអប់រំពលរដ្ឋសកល (GCED)។ សញ្ញាណនៃពលរដ្ឋសកល និងភាពជាពលរដ្ឋសកលនឹងត្រូវបានពិនិត្យយ៉ាងខ្លី រួមជាមួយនឹងការណែនាំអំពីគោលគំនិត និងគោលការណ៍សំខាន់ៗរបស់ GCED ក្រោមក្របខណ្ឌនៃអង្គការUNESCO។ |
| មេរៀន | 1. បញ្ញត្តិនិងមូលដ្ឋានគ្រឹះនៃ GCED<br>2. ការយល់ដឹងអំពី GCED ក្រោមក្របខណ្ឌអង្គការ UNESCO |
| លទ្ធផលរំពឹងទុក | 1.ស្វែងយល់ពីសញ្ញាណផ្សេងៗនៃ 'ពលរដ្ឋសកល' និង 'ភាពជាពលរដ្ឋសកល'<br>2. ស្វែងយល់ពីគោលការណ៍ និងបញ្ញត្តិសំខាន់ៗរបស់GCED ក្រោមក្របខណ្ឌរបស់អង្គការUNESCO |
| ដំណើរការបង្រៀន | 1. ចាប់ផ្តើម /លំនឹងថ្នាក់ (30 នាទី)<br>•[សកម្មភាព] និទានរឿងពលរដ្ឋសកល<br>2. ខ្លឹមសារមេរៀន (120 នាទី)<br>• តើអ្នកណាជាពលរដ្ឋសកល?<br>• បញ្ញត្តិនៃ GCED<br>• សំណួរគេសួរញឹកញាប់នៅលើ GCED<br>3. ការឆ្លុះបញ្ចាំង/សង្ខេប (30 នាទី)<br>•[សកម្មភាព] ការចែករំលែកគំនិត និងការយល់ឃើញ |
| ឯកសារយោង | **អង្គការយូណេស្កូ**.ការអប់រំភាពជាពលរដ្ឋសកលៈរៀបចំអ្នកសិក្សាសម្រាប់ការប្រកួតប្រជែងសតវត្សទី 21 ។ អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) ឆ្នាំ ២០១៤។<br>**Pak, S.Y.** "ការអប់រំភាពជាពលរដ្ឋសកលៈ គោលដៅ និងបញ្ហាប្រឈមក្នុងសហសវត្សថ្មី" សេអ៊ូលៈ មជ្ឈមណ្ឌលអប់រំអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការយល់ដឹងអន្តរជាតិ (APCEIU) ឆ្នាំ ២០១៣។<br>**អង្គការយូណេស្កូ**. ការអប់រំជាពលរដ្ឋសកលៈ ប្រធានបទ និងការរៀនសូត្រ |

ជំពូកទី២
អ្វីទៅជាGCED ?

## ការចាប់ផ្តើម

| | |
|---|---|
| រយៈពេល | ៣០នាទី |
| វត្ថុបំណង | ដើម្បីពិនិត្យមើលអត្ថន័យនៃពលរដ្ឋសកលដោយការចែករំលែកឧទាហរណ៍នៃមនុស្សដែលបានចូលរួមចំណែកក្នុងការធ្វើឱ្យសង្គមកាន់តែប្រសើរ និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា។ |

**សកម្មភាព៖ រឿងរបស់ពលរដ្ឋសកល**

**ជំហាន៖**

1. ចែកអត្ថបទខាងក្រោមស្តីពីពលរដ្ឋពិភពលោកឱ្យសិក្ខាកាម។ ផ្តល់ពេលវេលាឱ្យពួកគេអាន។

ក្មេងស្រីដែលឈរទាមទារសិទ្ធិក្នុងការរៀនសូត្រ៖ រឿង របស់ ម៉ាឡាឡា (Malala)

Malala Yousafzai ជាសកម្មជនប៉ាគីស្ថានដែលឈ្នះពានរង្វាន់ការអប់រំជាស្ត្រី គឺជាមនុស្សដែលក្មេងជាងគេមិនធ្លាប់ទទួលបានរង្វាន់ណូបែលសន្តិភាពនៅអាយុ 17 ឆ្នាំ បន្ទាប់ពីបានរួចជីវិតពីការប៉ុនប៉ងធ្វើឃាតដោយពួកតាលីបង់នៅក្នុងប្រទេសប៉ាគីស្ថាន។ ចាប់តាំងពីពេលនោះមក ម៉ាឡាឡាបានបន្តជាអ្នកតស៊ូមតិយ៉ាងខ្លាំងក្លាអំពីសិទ្ធិស្ត្រី ដោយធ្វើដំណើរទៅក្រៅប្រទេសដើម្បីនិយាយជាមួយក្មេងស្រីអំពីឧបសគ្គដែលពួកគេត្រូវប្រឈម ដើម្បីទទួលបាននូវការអប់រំ៖ អំពើហិង្សា ភាពក្រីក្រ និងអាពាហ៍ពិពាហ៍កុមារ។ ជាមួយគ្នានេះ ម៉ាឡាឡាបាននិយាយអំពីបញ្ហាទាំងនេះជាមួយថ្នាក់ដឹកនាំពិភពលោក ដោយជំរុញឱ្យពួកគេចូលរួមក្នុងការពង្រឹងការអប់រំរបស់កុមារី។ បទពិសោធន៍ និងសមិទ្ធិផលរបស់នាងបានជំរុញទឹកចិត្តស្ត្រីនៅគ្រប់ទីកន្លែងឱ្យទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងការអប់រំ និងប្រកបដោយសមភាព។ លើសពីនេះ នាងបានបង្កើត 'មូលនិធិម៉ាឡាឡា' ទូទាំងពិភពលោក ជាអង្គការមិនរកប្រាក់កម្រៃដែលឧទ្ទិសដល់ការផ្តល់ឱ្យក្មេងស្រីទាំងអស់ទទួលបានការអប់រំ។ ការតស៊ូរបស់ម៉ាឡាឡាប្រឆាំងនឹងការគាបសង្កត់លើកុមារ និងប្រជាជនវ័យក្មេង និងការតស៊ូរបស់នាង ដើម្បីសិទ្ធិកុមារទាំងអស់ក្នុងការអប់រំ បានជួយជំរុញដល់ការពិភាក្សាជាសកល។ ទោះបីជាមានការគៀបសង្កត់ និងភាពអយុត្តិធម៌បានធ្វើឡើងប្រឆាំងនឹងនាងក៏ដោយ ម៉ាឡាឡាបានបន្តទាមទារទាំងការអប់រំ និងឱកាសសម្រាប់ទាំងអស់គ្នា។ ភាពខ្លាំងរបស់នាងក្នុងការជម្នះនឹងភាពកំសាកបានបំផុសយុវជន និងអ្នកដឹកនាំទូទាំងពិភពលោកឱ្យប្រកាន់ជំហរប្រឆាំងនឹងការរើសអើង។

## ការបញ្ចប់ពលកម្មកុមារម្តងហើយម្តងទៀត៖ រឿងមួយរបស់លោក កៃឡាសសត្យាធី(Mr. Kailash Satyarthi)

នៅពេលដែលលោក Kailash Satyarthi កាលពីនៅកុមារភាពរឿងដំបូងដែលលោកបានឃើញគឺក្មេងប្រុសម្នាក់នៅខាងក្រៅទ្វារសាលារបស់គាត់ ជួសជុលស្បែកជើងជំនួសឱ្យការចូលសាលា កំហឹងតូចមួយនៅក្នុងចិត្តរបស់គាត់បានកើតឡើង។ គាត់ចាប់ផ្តើមចោទជាសំណួរថា ហេតុអ្វីបានជាកុមារខ្លះកើតមក ធ្វើការដើម្បីតែថ្លៃសិក្សា ខណៈដែលខ្លះបានទទួលការសិក្សាត្រឹមត្រូវ ហើយបានឈានទៅមុខដើម្បីសម្រេចក្តីសុបិនរបស់ពួកគេ។ នេះនៅតែជាបញ្ហាប្រឈម និងជាបញ្ហាដែលគាត់បានតស៊ូពេញមួយជីវិតរបស់គាត់។ គាត់បានក្លាយជាសកម្មជនសិទ្ធិមនុស្សនៅក្នុងប្រទេសឥណ្ឌា ដែលតស៊ូមតិសម្រាប់ការបញ្ចប់ទាសភាព និងការកេងប្រវ័ញ្ចលើកុមារ។ គាត់បានបង្កើតគំរូមួយសម្រាប់ការអប់រំរបស់កុមារ ការស្តារនីតិសម្បទា និងសមាហរណកម្មទៅក្នុងសង្គម ជា 'ភូមិដែលងាយស្រួលសម្រាប់កុមារ' ឬ Bal Mitra Grams (BMGs) នៅក្នុងប្រទេសឥណ្ឌា និងនេប៉ាល់។ ភូមិនានាប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងនូវគោលការណ៍ប្រជាធិបតេយ្យ ហើយទស្សនៈរបស់កុមារត្រូវបានចាត់ទុកដោយការគោរពបំផុតនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ ភូមិនានាអនុញ្ញាតឱ្យកុមាររៀនពីគុណសម្បត្តិនៃភាពជាអ្នកដឹកនាំតាំងពីក្មេង ព្រមទាំងការយល់ដឹងយ៉ាងច្បាស់អំពីសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ លោក Kailash Satyarthi ជឿថា កំហឹងផ្តល់ឱ្យគាត់នូវថាមពល និងជាថាមពលវិជ្ជមាន ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌។ តាមរយៈការបំប្លែងកំហឹងរបស់គាត់ទៅជាគំនិត និងពីគំនិតរបស់គាត់ទៅជាសកម្មភាព គាត់ជឿថាពិភពលោកនឹងក្លាយទៅជាកន្លែងរស់នៅដ៏ប្រសើរ។

## ការស៊ើបអង្កេត "អាហារសមុទ្រពីទាសករ"៖ រឿងរបស់អ្នកកាសែត

អ្នកកាសែត Esther Htusan, Margie Mason, Robin McDowell និង Martha Mendoza នៃសារព័ត៌មាន Associated Press បានទទួលរង្វាន់ Pulitzer សម្រាប់សេវាសាធារណៈក្នុងការស៊ើបអង្កេតរបស់ពួកគេលើការប្រើប្រាស់ទាសករក្នុងឧស្សាហកម្មនេសាទនៅតំបន់អាស៊ីអាគ្នេយ៍។ អ្នកយកព័ត៌មានមិនត្រឹមតែបានចងក្រងជាឯកសារអំពីទង្វើដ៏ឃោរឃៅរបស់អ្នកនេសាទដែលជាប់ជាឈ្លើយ ដែលជារឿយៗត្រូវបានល្បួងឱ្យទៅជាឈ្លើយ វាយដំ និងបង្ខំឱ្យធ្វើការក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏បានតាមដានផងដែរ ថាតើទំនិញដែលផលិតដោយទាសករ និងមានតម្លៃថោកដូចនេះកំពុងត្រូវបានប្រើប្រាស់នៅឯណា ជាពិសេស នៅក្នុងសហរដ្ឋអាមេរិច? អាស្រ័យហេតុនេះ របាយការណ៍របស់ពួកគេនាំទៅដល់ការដាក់ឱ្យប្រើប្រាស់ច្បាប់នៅក្នុងសភាសហរដ្ឋអាមេរិក ដើម្បីជួយពង្រឹងតម្លាភាពកាន់តែច្រើនពីអ្នកផ្គត់ផ្គង់អាហារ។ ការងាររបស់អ្នកយកព័ត៌មានក៏បានជួយដោះលែងទាសករជាង

2,000 នាក់ក្នុងរយៈពេលប្រាំមួយខែ ដែលភាគច្រើននៃទាសករនេសាទ នៅទីបំផុតត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញបន្ទាប់ពីពលកម្មជាច្រើនឆ្នាំ។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេបានអង្រួនឧស្សាហកម្មនេសាទ និងអ្នកប្រើប្រាស់របស់ខ្លួន សង្គ្រោះទាសករជុំថ្មីដែលកើតឡើងជាបន្តបន្ទាប់។ នៅពេលដែលត្រូវបានរំដោះកាន់តែច្រើនឡើង កិច្ចខិតខំប្រឹងប្រែងនៅតែបន្តជួយសង្គ្រោះអ្នកដែលនៅជាប់ក្នុងសមុទ្រ។ ការស៊ើបអង្កេតទាំងនេះ បានជួយស្វែងរកការរំលោភសិទ្ធិមនុស្ស ដែលមិនបានមើលឃើញទុកជាមុន។ ការងារនេះមានបំណងរៀបចំដំណាក់កាលសម្រាប់កំណែទម្រង់ចាំបាច់ និងបន្ថែម ដោយនាំការយកចិត្តទុកដាក់ច្រើនលើបញ្ហានេះតាមដែលអាចធ្វើទៅបាន។

## ក្រុមអ្នកផលិតសូកូឡាវ័យក្មេងមួយក្រុម៖ រឿងរ៉ាវរបស់ Choco Togo

ក្រុមសហគ្រិនវ័យក្មេងចំនួន 6 នាក់ក្នុងប្រទេស Togo បានចាប់ផ្តើមបង្កើតក្រុមហ៊ុនកែច្នៃកាកាវដំបូងគេ និងតែមួយគត់របស់ប្រទេសពួកគេ។ បន្ទាប់ពីបានធ្វើដំណើរទៅក្រៅប្រទេសតាមរយៈកម្មវិធីរបស់សហភាពអឺរ៉ុបដែលបង្កើតឡើងដើម្បីផ្តល់សិទ្ធិអំណាចដល់សហគ្រិនអាហ្វ្រិក ជនជាតិ Togolese វ័យក្មេងទាំងនេះបានរកឃើញថា ទោះបីជាប្រទេសនេះមានការរីកចម្រើននៃការផលិតកាកាវក៏ដោយ ក៏តូហ្គោមិនបានកែច្នៃ និងផលិតសូកូឡាផ្ទាល់ខ្លួនរបស់ពួកគេដែរ។ ដើម្បីនាំមកនូវការងារបន្ថែមតម្លៃដែលផលិតកម្មសូកូឡារួមបញ្ចូល ពួកគេបានសម្រេចចិត្តបង្កើតសហករណ៍ផ្ទាល់ខ្លួនរបស់ពួកគេមួយសម្រាប់ផលិតសូកូឡាដែលផ្តល់អត្ថប្រយោជន៍ក៏ដូចជាការបង្កើតការងារនៅក្នុងតំបន់។ អាជីវកម្មតែមួយគត់គ្រប់គ្រងដំណើរការផលិតសូកូឡាទាំងមូល ចាប់ពីការធានាការផ្គត់ផ្គង់គ្រាប់កាកាវឆៅ និងការដកសែលចេញ រហូតការបង្កើតផលិតផលសូកូឡាផ្ទាល់ខ្លួនរបស់ពួកគេ។ ផលិតផលរបស់ពួកគេមានប្រភពក្នុងស្រុក និងផលិតប្រកបដោយនិរន្តរភាព។ អ្នកផលិតសូកូឡាធ្វើការជាមួយកាកាវសុទ្ធ ហើយមិនដែលដកសារធាតុចិញ្ចឹមណាមួយរបស់វាចេញឡើយ។ ដោយប្រើធនធានក្នុងស្រុក អាជីវកម្មដែលមិនប៉ះពាល់ដល់បរិស្ថានកំពុងបោះជំហានទៅមុខ ក្នុងការទាញយកអត្ថប្រយោជន៍ពីការបង្កើតផលិតផលផ្ទាល់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានៃភាពអត់ការងារធ្វើរបស់យុវជន និងភាពក្រីក្ររបស់ប្រទេសក្នុងទម្រង់ប្រកបដោយនិរន្តរភាព។ នៅក្នុងការប៉ុនប៉ងរបស់ពួកគេដើម្បីធ្វើបដិវត្តន៍ឧស្សាហកម្មសូកូឡានៅក្នុងទ្វីបអាហ្វ្រិក សហគ្រិនតូហ្គោលបានផ្តល់នូវផ្លូវថ្មីមួយសម្រាប់អ្នកក្នុងស្រុកតូហ្គោ ដើម្បីមានដៃគូនៅក្នុងដំណើរការរបស់ពួកគេផ្ទាល់ក្នុងការដាំដុះ ហើយរីករាយនឹងការនាំចេញដែលមានអាយុកាល 120 ឆ្នាំនៅក្នុងតំបន់។ អ្នកប្រើប្រាស់ Togolese ត្រូវបានផ្តល់ឱកាសថ្មីមួយដើម្បីរីករាយជាមួយផលិតផលដែលបានបញ្ចប់ដោយខ្លួនវា ខណៈពេលដែលពួកគេក៏ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ

របស់ពួកគេដោយការចូលរួមក្នុងដំណើរការផលិតសូកូឡាផងដែរ។  អាជីវកម្មនេះបាននាំមកនូវផលប៉ះពាល់សង្គមជាវិជ្ជមានសម្រាប់តំបន់ នៅពេលដែលវាបន្តរីកចម្រើន។

2. អនុញ្ញាតឱ្យអ្នកចូលរួមមើលវីដេអូដែលបានរាយបញ្ជី (ខ្លះ បើមិនទាំងអស់)៖រឿងរ៉ាវរបស់ A. Malala – BBC News

https://www.youtube.com/watch?v=FnloKzEAX7o

B. ជ័យលាភីណូបែល Satyarthi លើពលកម្មកុមារ – CNN News

https://edition.cnn.com/videos/tv/2015/08/04/exp-gps-0802-satyarthi-child-labor.cnn

គ. របៀបដែល AP រកឃើញទាសភាពសម្ងាត់នៅពីក្រោយអាហារសមុទ្រ ក្នុងផ្សារទំនើបរបស់អ្នក។

https://www.youtube.com/watch?v=JQroCVs01SI

D. ជួបជាមួយពលរដ្ឋសកល៖ បទសម្ភាសន៍ជាមួយ Choco Togo

www.gcedonlinecampus.org

3. ផ្តួចផ្តើមការពិភាក្សាដោយផ្តល់សំណួរខាងក្រោមដល់សិក្ខាកាម៖

A. តើអ្នកគិតថាទាំងនេះជាពលរដ្ឋសកលទេ? បើមែន តើអ្វីធ្វើឱ្យអ្នកគិតបែបនេះ? បើមិនដូច្នេះទេ តើអ្នកមានហេតុផលអ្វី?

ខ. ឆ្លុះបញ្ចាំងពីរឿងរ៉ាវដែលបានចែករំលែក តើអ្វីជាលក្ខណៈពិសេស ឬតម្លៃរបស់ពលរដ្ឋសកល?

ជំពូកទី២

អ្វីទៅជាGCED ?

## ខ្លឹមសារមេរៀន

| រយៈពេល | ១២០នាទី |
|---|---|
| វត្ថុបំណង | · ដើម្បីយល់ពីពាក្យដែលទាក់ទងនឹង GCED<br>· ដើម្បីយល់ពីគោលដៅរបស់ GCED ហើយគិតអំពីមូលហេតុដែលអ្នកសិក្សាត្រូវដឹងអំពី GCED<br>·ដើម្បីពិនិត្យមើលសំណួរដែលលើកឡើងជាញឹកញាប់ដោយអ្នកអប់រំជាច្រើនទាក់ទងនឹង GCED និងចម្លើយចំពោះសំណួរទាំងនេះ |

### តើនរណាជាពលរដ្ឋសកល?

អ្វីដែលត្រូវធ្វើ៖ ប្រើឧបករណ៍ជំនួយដែលមើលឃើញ (ឧ. ស្លាយ PowerPoint និងវីដេអូ) ដើម្បីជួយពន្យល់អំពីបញ្ញត្តិ។

ពាក្យ 'ពលរដ្ឋសកល' និង 'ភាពជាពលរដ្ឋសកល' នៅតែជាប្រធានបទដែលត្រូវពិភាក្សា។ អ្នកប្រាជ្ញ និងអ្នកអនុវត្តក្នុងវិស័យផ្សេងៗបានពិភាក្សាយ៉ាងទូលំទូលាយ និងរិះគន់លក្ខខណ្ឌទាំងនេះ។ ជាញឹកញាប់សញ្ញាណនៃ'ភាពជាពលរដ្ឋសកល' មានភាពខុសប្លែកគ្នាក្នុងចំណោមបុគ្គល និងស្ថាប័ននានា ដោយសារប្រវត្តិសង្គម វប្បធម៌ និងនយោបាយចម្រុះរបស់ពួកគេ ព្រមទាំងអាទិភាពផ្សេងៗគ្នារបស់ពួកគេ។ ការរួមបញ្ចូលគ្នារវាងពាក្យ 'សកល' និង 'ភាពជាពលរដ្ឋ' មើលពីដំបូងហាក់ដូចជាផ្ទុយគ្នា។ នៅពេលដែលគេនិយាយថា "សញ្ជាតិ" វាជាធម្មតាមានន័យថាជាពលរដ្ឋនៃប្រទេសមួយ។ម្យ៉ាងវិញទៀត 'សកល' បង្ហាញថាគ្មានព្រំដែនទឹកដីទេ។ ដូច្នេះ តើភាពជាពលរដ្ឋសកលមានន័យថាសមាជិកភាពចំពោះរដ្ឋាភិបាលពិភពលោកជាក់លាក់មួយ ហើយផ្តល់សិទ្ធិឱ្យបុគ្គលដែលមានឋានៈស្របច្បាប់ដែរឬទេ? ឬជំនួសសញ្ជាតិ?

### ភាពជាពលរដ្ឋសកលជាមនុស្សជាតិទូទៅ

គំនិតនៃសញ្ជាតិបានផ្លាស់ប្តូរតាមពេលវេលា។ មានពេលមួយក្នុងអតីតកាលដែលមានតែបុរសប៉ុណ្ណោះត្រូវបានគេចាត់ទុកជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការអភិវឌ្ឍន៍នៃសិទ្ធិស៊ីវិល

នយោបាយ និងសង្គម គំនិតដែលរួមបញ្ចូលកាន់តែច្រើននៃសញ្ជាតិបានលេចឡើង និងត្រូវបានទទួលយក។ ជាងនេះទៅទៀត នៅក្នុងពិភពលោកដែលមានទំនាក់ទំនងគ្នា និងទាក់ទងគ្នាយ៉ាងខ្លាំងនេះ សហគមន៍សកលលោកអំពាវនាវឱ្យមានសញ្ជាតិដែលហួសពីព្រំដែនជាតិ។ ដូច្នេះតើអ្វីទៅជា 'ភាពជាពលរដ្ឋសកល'? តើវាផ្តល់អ្វីមួយដល់អ្នករាល់គ្នាដែលរស់នៅក្នុងពិភពសាកលភាវូបនីយកម្មនេះទេ? ឬវាជាអ្វីដែលយើងទទួលបានតាមរយៈបទពិសោធន៍?

រហូតមកដល់បច្ចុប្បន្ន វាត្រូវបានគេយល់យ៉ាងទូលំទូលាយថា ភាពជាពលរដ្ឋសកល គឺមានន័យថាជាកម្មសិទ្ធិរបស់សហគមន៍សកលលោក និងមនុស្សជាតិទូទៅ ជាជាងស្ថានភាពផ្លូវច្បាប់។ នេះមានន័យថា ភាពជាពលរដ្ឋសកលមិនបោះបង់ ឬធ្វើឱ្យខូចដល់សញ្ជាតិជាតិនោះទេគឺគ្រាន់តែជាការពង្រីកការទទួលខុសត្រូវរបស់ពលរដ្ឋលើសពីព្រំដែនជាតិទៅដល់សហគមន៍ពិភពលោកប៉ុណ្ណោះ។ វាបន្ថែមតម្លៃដល់ភាពជាពលរដ្ឋរបស់ខ្លួនឯង ព្រោះវាពង្រីកការចូលរួមរបស់ពួកគេនៅក្នុងសង្គមកាន់តែធំ ដោយធ្វើសកម្មភាពលើសពីសហគមន៍តូចៗ។

**ពលរដ្ឋសកល៖ ទស្សនៈផ្សេងៗ**

អង្គការជាច្រើនក៏ផ្សព្វផ្សាយពីបញ្ញត្តិនៃ 'ពលរដ្ឋសកល' តាមវិធីផ្សេងៗ។ ទោះបីជាមិនមានការឯកភាពជាសកលលើនិយមន័យនៃ 'ពលរដ្ឋសកល' ក៏ដោយ វាមានលក្ខណៈពិសេសសំខាន់ៗមួយចំនួននៃអត្ថន័យនៃការក្លាយជាពលរដ្ឋសកល។ នេះគឺជានិយមន័យមួយចំនួននៃ 'ពលរដ្ឋសកល' ដែលបង្ហាញដោយស្ថាប័នអន្តរជាតិផ្សេងៗ៖

ពលរដ្ឋសកល...

| Oxfam 3 | U.S. Fund for UNICEF 4 |
|---|---|
| · យល់ដឹងអំពីពិភពលោកកាន់តែទូលំទូលាយ និងដឹងពីតួនាទីរបស់គាត់ក្នុងនាមជាពលរដ្ឋពិភពលោក<br>· គោរព និងឲ្យតម្លៃលើភាពចម្រុះ | · គឺជាមនុស្សម្នាក់ដែលយល់ពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃពិភពលោក<br>· គោរព និងឲ្យតម្លៃលើភាពចម្រុះ |

| | |
|---|---|
| · មានការយល់ដឹងអំពីរបៀបដែលពិភពលោកដំណើរការ<br>· ប្តេជ្ញាចិត្តយ៉ាងខ្លាំងចំពោះយុត្តិធម៌សង្គម<br>·ចូលរួមក្នុងសហគមន៍នៅកម្រិតជាច្រើនពីមូលដ្ឋានដល់ពិភពលោក<br>· ធ្វើការជាមួយអ្នកដទៃដើម្បីធ្វើឱ្យពិភពលោកកាន់តែមានសមធម៌ និងនិរន្តរភាព<br>· ទទួលខុសត្រូវចំពោះសកម្មភាពរបស់គាត់។ | ·មានសមត្ថភាពក្នុងការប្រឈមមុខនឹងភាពអយុត្តិធម៌<br>· ធ្វើសកម្មភាពតាមមធ្យោបាយដែលខ្លួនយល់ឃើញថាមានភាពត្រឹមត្រូវ |

| The Brookings Institution[5] | គំនិតផ្តួចផ្តើមរបស់ពលរដ្ឋសកល[6] |
|---|---|
| [ជាភ្នាក់ងារ] នៃការផ្លាស់ប្តូរជាវិជ្ជមានរយៈពេលវែងនៅក្នុងជីវិតរបស់ពួកគេផ្ទាល់ និងនៅក្នុងជីវិតរបស់មនុស្សក្នុងសហគមន៍តូចធំជាងសហគមន៍របស់ពួកគេ (ជាមួយសហគមន៍បរិស្ថានផងដែរ) | គឺជាមនុស្សម្នាក់ដែលកំណត់ថាជាផ្នែកមួយនៃសហគមន៍ពិភពលោកកំពុងរីកចម្រើន ហើយសកម្មភាពរបស់ពួកគេរួមចំណែកដល់ការកសាងតម្លៃ និងការអនុវត្តរបស់សហគមន៍នេះ |

[3] កម្មវិធីអភិវឌ្ឍន៍អប់រំអុកស្វាម៖ ការអប់រំសម្រាប់ភាពជាពលរដ្ឋសកល: ការណែនាំសម្រាប់សាលារៀន។ Oxfam GB ឆ្នាំ ២០០៦។

[4]បង្រៀន UNICEF ។ ភាពជាពលរដ្ឋសកល៖ ការណែនាំរបស់អ្នកអប់រំនៅវិទ្យាល័យ (ថ្នាក់ទី ៩-១២)។ ឆ្នាំ ២០១៣ ។

[5]មជ្ឈមណ្ឌលសម្រាប់ការអប់រំសកលនៅ Brookings។ ការវាស់វែងការអប់រំភាពជាពលរដ្ឋសកល។ ការប្រមូលផ្តុំការអនុវត្ត និងឧបករណ៍។ PDF ឆ្នាំ ២០១៧។

Center for Universal Education at Brookings. Measuring Global Citizenship Education A Collection of Practices and Tools. PDF. ២០១៧.

6 គំនិតផ្តួចផ្តើមភាពជាពលរដ្ឋសកល។ "ការកសាងសហគមន៍ពិភពលោកប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា "http://www.theglobalcitizensinitiative។ org/

ប្រសិនបើយើងសង្ខេបពាក្យគន្លឹះពីមនុស្ស និងស្ថាប័នផ្សេងៗគ្នា វានឹងមើលទៅដូចនេះ៖

| ការគិត | ការធ្វើសកម្មភាព | គោលបំណង |
|---|---|---|
| ·ចំណេះដឹងអំពីពិភពលោកកាន់តែទូលំទូលាយ<br>·ស្វែងយល់ពីរបៀបដែលពិភពលោកដំណើរការ<br>·ស្វែងយល់ពីការទំនាក់ទំនងគ្នាទៅវិញទៅមក<br>·កំណត់អត្តសញ្ញាណជាមួយសហគមន៍ពិភពលោក | · ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។<br>· ចូលរួមក្នុងសហគមន៍ | · ប្រកួតប្រជែងភាពអយុត្តិធម៌/ងប់ងល់នឹងយុត្តិធម៌សង្គម<br>· ការគោរព និងឱ្យតម្លៃភាពចម្រុះ<br>· ធ្វើឱ្យពិភពលោកកាន់តែមានសមធម៌ និងនិរន្តរភាព |

អង្គការយូណេស្កូចាត់ទុកពលរដ្ឋសកលថាជាមនុស្សម្នាក់ដែល "គិត និងធ្វើសកម្មភាពដើម្បីពិភពលោកកាន់តែយុត្តិធម៌ សន្តិភាព និងនិរន្តរភាព"។

## តើភាពជាពលរដ្ឋសកលជាអ្វី?

រហូតមកដល់ពេលនេះ ការឯកភាពគ្នាទាក់ទងនឹងនិយមន័យនៃភាពជាពលរដ្ឋសកល និងពលរដ្ឋសកលមិនទាន់ត្រូវបានសម្រេចនៅឡើយទេ។ បើទោះបីជាវាជាប្រធានបទដែលមានការបកស្រាយយ៉ាងទូលំទូលាយដោយផ្អែកលើបរិបទក៏ដោយ ក៏ភាពជាពលរដ្ឋសកល ត្រូវបានគេសង្ខេបដូចខាងក្រោម៖

ភាពជាពលរដ្ឋសកលគឺជាអារម្មណ៍នៃកម្មសិទ្ធិ និងការទទួលខុសត្រូវចំពោះសហគមន៍ពិភពលោកលើភាពយុត្តិធម៌ សន្តិភាព និងនិរន្តរភាព។ វាគឺជាវិធីនៃការយល់ដឹងមួយ ជាការធ្វើសកម្មភាព និងជាទំនាក់ទំនងរវាងអ្នកណាម្នាក់ទៅអ្នកណាម្នាក់ទៀតដោយឈរលើគុណតម្លៃសកលនិងការគោរពភាពផ្សេងៗគ្នា។

ជំពូកទី២

អ្វីទៅជាGCED ?

## ខ្លឹមសារមេរៀន

### បញ្ញត្តិនៃGCED

**អ្វីដែលត្រូវធ្វើ៖** ប្រើឧបករណ៍ជំនួយដែលអាចមើលឃើញ (ឧ. ស្លាយ PowerPoint វីដេអូ) ដើម្បីជួយពន្យល់ពីបញ្ញត្តិ។

តើការអប់រំភាពជាពលរដ្ឋសកល (GCED) ជាអ្វី?

ដូចដែលយើងបានសិក្សារួចហើយនៅក្នុងម៉ូឌុលមុន ការអប់រំភាពជាពលរដ្ឋសកល (GCED) គឺជាការអប់រំនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន អាចអភិវឌ្ឍចំណេះដឹង ជំនាញ គុណតម្លៃ និងអាកប្បកិរិយាដែលសិស្សត្រូវការដើម្បីបង្កើតពិភពលោកមួយកាន់តែមានភាពយុត្តិធម៌ សន្តិភាព និងនិរន្តរភាព។ វាផ្អែកលើគោលការណ៍សកលនៃសិទ្ធិមនុស្ស សមភាពយេនឌ័រ ការមិនរើសអើង អហិង្សា និងការគោរពគ្នា។

### វិមាត្របញ្ញត្តិគន្លឹះនៃGCED

GCED មានវិមាត្របញ្ញត្តិគន្លឹះចំនួនបីដែលវាសមញ្ញទៅនឹងនិយមន័យផ្សេងៗ និងបកស្រាយពីការអប់រំភាពជាពលរដ្ឋសកល។ វិមាត្របញ្ញត្តិទាំងនោះផ្អែកលើទិដ្ឋភាពនៃដែនទាំងបីក្នុងការរៀនសូត្ររួមមាន៖ ទិដ្ឋភាពចំណេះដឹង ទិដ្ឋភាពចិត្តសង្គម និងទិដ្ឋភាពអាកប្បកិរិយា។

### វិមាត្រនៃGCED



ទិដ្ឋភាពចំណេះដឹង ទិដ្ឋភាពចិត្តសង្គម ទិដ្ឋភាពអាកប្បកិរិយា

ទិដ្ឋភាពមិនមែនជាចំណេះដឹង ដូចជាទិដ្ឋភាពចិត្តសង្គម និងទិដ្ឋភាពអាកប្បកិរិយា មានសារៈសំខាន់ដូចគ្នាទៅនឹងទិដ្ឋភាពចំណេះដឹង ដែលរួមបញ្ចូលទាំងការទទួលបានចំណេះដឹងអំពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃបញ្ហាក្នុងស្រុក ជាតិ តំបន់ និងសកលលោក និងជំនាញការគិតស៊ីជម្រៅផងដែរ។ តួនាទីនៃការអប់រំគឺលែងនិយាយតែពីការរៀនសូត្រអំពីចំណេះដឹងហើយ ប៉ុន្តែនិយាយអំពីការរៀនសូត្រអំពីអ្វីដែលមិនមែនជាចំណេះដឹងដូចជាគុណតម្លៃ អាកប្បកិរិយា ទិដ្ឋភាពសង្គម និងសមត្ថភាពចិត្តចលករ និងសកម្មភាពសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន។ តាមរយៈការសិក្សាដែលមិនមែនផ្អែកតែទៅលើចំណេះដឹង អ្នកសិក្សាអាចផ្លាស់ប្តូរសង្គម និងរស់នៅជាមួយអ្នកដទៃដោយការគោរព និងការយល់ដឹងគ្នាទៅវិញទៅមក។

GCED រួមបញ្ចូលវិមាត្របញ្ញត្តិគន្លឹះទាំងបី

| | | |
|---|---|---|
|  | ចំណេះដឹង | ដើម្បីទទួលបានចំណេះដឹង យល់ និងគិតបានស៊ីជម្រៅអំពីបញ្ហាសកលតំបន់ ប្រទេស មូលដ្ឋាន និងអំពីទំនាក់ទំនងគ្នាទៅវិញទៅមក ភាពអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេស និងប្រជាជនផ្សេងៗគ្នា។ |
|  | ចិត្តចលករសង្គម | ដើម្បីឱ្យមានការគិតថាមនុស្សម្នាក់ៗជាកម្មសិទ្ធិរបស់មនុស្សទូទៅ ដែលត្រូវចែករំលែកគុណតម្លៃ ការទទួលខុសត្រូវ សមានចិត្ត សាមគ្គីភាព និងគោរពចំពោះភាពខុសគ្នា និងចម្រុះគ្នា។ |
|  | អកប្បកិរិយា | ដើម្បីធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវនៅកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ ដើម្បីពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព។ |

GCED គឺរៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីស្គាល់ខ្លួនឯង និងរៀនដើម្បីរស់នៅជាមួយគ្នា

វិមាត្របីមានទំនាក់ទំនងគ្នានៅក្នុងលំនាំនៃការរៀនហើយគួរតែត្រូវបានយល់ថាជាដំណើរការសិក្សាដ៏ល្អមួយ។ វាត្រូវគ្នាទៅនឹងសសរស្តម្ភទាំងបួននៃការរៀនដែលបានពិពណ៌នានៅក្នុងអង្គការយូណេស្កូឆ្នាំ ១៩៩៨ ដែលមាន៖(១) រៀនដើម្បីមានចំណេះដឹង (២) រៀនដើម្បីមានចំណេះធ្វើ (៣) ដើម្បីស្គាល់ខ្លួនឯង (៤) រៀនដើម្បីរស់នៅជាមួយគ្នា។ ទោះបីជាគោលការណ៍ទាំងអស់មានសារៈសំខាន់ក្នុងការសម្រេច

បាននូវគោលដៅជាមូលដ្ឋាននៃការអប់រំក៏ដោយ ក៏'ការរៀនរស់នៅជាមួយគ្នា' គឺមានសារៈសំខាន់និងពាក់ព័ន្ធខ្លាំងណាស់នៅក្នុងយុគសម័យសកលភាវូបនីយកម្មបច្ចុប្បន្ន។



ជំពូកទី២

អ្វីទៅជាGCED ?

## ខ្លឹមសារមេរៀន

- រៀនដើម្បីមានចំណេះដឹង៖ ផ្តល់ឧបករណ៍ចំណេះដឹងដែលត្រូវការ ដើម្បីយល់កាន់តែច្បាស់អំពីពិភពលោក និងភាពស្មុគស្មាញរបស់វា ព្រមទាំងផ្តល់នូវមូលដ្ឋានគ្រឹះសមស្រប និងគ្រប់គ្រាន់សម្រាប់ការរៀនសូត្រនាពេលអនាគត។
- រៀនដើម្បីមានចំណេះធ្វើ៖ ផ្តល់ជំនាញដែលអាចឱ្យបុគ្គលម្នាក់ៗចូលរួមក្នុងសេដ្ឋកិច្ច និងសង្គមពិភពលោកប្រកបដោយប្រសិទ្ធភាព
- រៀនដើម្បីស្គាល់ខ្លួនឯង៖ ផ្តល់នូវជំនាញវិភាគខ្លួនឯង និងសង្គម ដើម្បីឱ្យបុគ្គលម្នាក់ៗអាចអភិវឌ្ឍសមត្ថភាពពេញលេញរបស់ពួកគេ ដើម្បីក្លាយជាមនុស្សសកល។
- រៀនដើម្បីរស់នៅជាមួយគ្នា៖បង្ហាញបុគ្គលម្នាក់ៗអំពីគុណតម្លៃដែលបង្កប់ក្នុងសិទ្ធិមនុស្ស គោលការណ៍ប្រជាធិបតេយ្យ ការយល់ដឹង និងការគោរពវប្បធម៌ចម្រុះ និងសន្តិភាពនៅគ្រប់កម្រិតនៃសង្គម និងទំនាក់ទំនងមនុស្ស ដើម្បីឱ្យបុគ្គល និងសង្គមរស់នៅដោយសន្តិភាព និងសុខដុមរមនា។

## តើអ្វីជាគោលបំណងរបស់ GCED សម្រាប់អ្នកសិក្សា?

| ចំណេះដឹង | ចិត្តចលករសង្គម | អកប្បកិរិយា |
|---|---|---|
| ·អភិវឌ្ឍការយល់ដឹងអំពីរចនាសម្ព័ន្ធអភិបាលកិច្ចសកល សិទ្ធិ ទំនួលខុសត្រូវ បញ្ហាសកល ការតភ្ជាប់រវាងប្រព័ន្ធ ដំណើរការ សកល ជាតិ និងមូលដ្ឋាន។<br>· អភិវឌ្ឍ និងអនុវត្តជំនាញសំខាន់ៗសម្រាប់អក្ខរកម្មពលរដ ដូចជាការសើប | · ទទួលស្គាល់ និងពេញចិត្តចំពោះអត្តសញ្ញាណជាច្រើនផ្សេងៗគ្នា ឧ. វប្បធម៌ ភាសា សាសនា យេនឌ័រ និងមនុស្សទូទៅ។ អភិវឌ្ឍជំនាញសម្រាប់ការរស់នៅក្នុងពិភពលោកដែលកាន់តែសម្បូរបែប<br>·អភិវឌ្ឍឥរិយាបទថៃទាំនិង | · ចូលរួម និងរួមចំណែកដល់បញ្ហាសកលសហសម័យនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតសកលលោក ក្នុងនាមជាអ្នកជូនដំណឹង ចូលរួម ទទួលខុសត្រូវ និងភាពឆ្លើយតបដល់ពលរដ្ឋពិភពលោក។ |

| | | |
|---|---|---|
| ពលរដ្ឋ ដូចជាការអង្កេតបច្ចេកវិទ្យាព័ត៌មាន ចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយ ការគិតបែបស៊ីជម្រៅ ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចរចា ការកសាងសន្តិភាព និងការទទួលខុសត្រូវផ្ទាល់ខ្លួន និងសង្គម។<br>·ទទួលស្គាល់ និងពិនិត្យមើលជំនឿ និងគុណតម្លៃ និងរបៀបដែលវាមានឥទ្ធិពលលើការសម្រេចចិត្តខាងនយោបាយ និងសង្គម ការយល់ឃើញអំពីយុត្តិធម៌សង្គម និងការចូលរួមរបស់ប្រជាពលរដ្ឋ។ | មានសមានចិត្តចំពោះអ្នកដទៃនិងបរិស្ថាន។ គោរពភាពចម្រុះ អភិវឌ្ឍគុណតម្លៃនៃភាពថ្លៃថ្នូរ យុត្តិធម៌សង្គម និងជំនាញក្នុងការវិភាគស៊ីជម្រៅទៅលើវិសមភាពយេនឌ័រ ស្ថានភាពសេដ្ឋកិច្ចសង្គម វប្បធម៌ សាសនា អាយុនិងបញ្ហាផ្សេងៗទៀត | |

## សកម្មភាព៖ FAQ ស្តីពី GCED

### អ្វីដែលត្រូវធ្វើ៖

1. មុនពេលធ្វើសកម្មភាព សូមសរសេរសំណួរ GCED ខាងក្រោមនៅលើក្រដាសផ្ទាំងធំនីមួយៗ (ទំហំផ្ទាំងរូបភាព) ហើយភ្ជាប់វាទៅនឹងជញ្ជាំង។ ផ្តល់សន្លឹកផុសអ៊ីតគ្រប់គ្រាន់សម្រាប់បិទលើក្រដាសផ្ទាំងធំនីមួយៗ។

| Q1. | Q2. | Q3. |
| --- | --- | --- |
| តើGCEDបង្រៀនតែអំពីពិភពលោកឬ? | ដើម្បីបង្រៀន GCED តើគ្រូបង្រៀនត្រូវមានចំណេះដឹងអំពីប្រធានបទពាក់ព័ន្ធទាំងអស់ ដូចជាសកលភាវូបនីយកម្ម សិទ្ធិមនុស្ស និងសន្តិភាពដែរឬទេ? | តើ GCED មានប្រយោជន៍ដល់ប្រជាជនមកពីប្រទេសកំពុងអភិវឌ្ឍន៍ដែរឬទេ? |

| Q4. | Q5. | Q6. | Q7. |
| --- | --- | --- | --- |
| តើ GCED ពិបាកពេកសម្រាប់សិស្សវ័យក្មេងដែរឬទេ? តើ GCED អាចត្រូវបានបង្រៀននៅគ្រប់កម្រិតសិស្សដែរឬទេ? | តើ GCED មានការប្រកួតប្រជែងជាមួយចលនាអប់រំផ្សេងទៀត ដូចជាការអប់រំពហុវប្បធម៌ ការអប់រំសិទ្ធិមនុស្ស និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែរឬទេ? | តើសកម្មភាពផ្លាស់ប្តូរអន្តរជាតិជាផ្នែកសំខាន់នៃ GCED ដែរឬទេ? | តើកម្មវិធីសិក្សាត្រូវបានរៀបចំរួចហើយនៅក្នុងសាលារៀន ដូច្នេះមិនមានពេលសម្រាប់បង្រៀន GCED ទេ។ ទោះជាយ៉ាងនេះក៏ដោយ តើយើងនៅតែអាចបង្រៀន GCED យ៉ាងដូចម្តេច? |

2. ឲ្យសិក្ខាកាមដើរជុំវិញថ្នាក់រៀន ហើយផ្តល់ពេលគ្រប់គ្រាន់ដើម្បីគិតអំពីសំណួរទាំងនេះ។
3. ឱ្យសិក្ខាកាមសរសេរចម្លើយនៃសំណួរ និងគំនិតរបស់ពួកគេដោយសេរីនៅលើក្រដាស់សន្លឹកផុសអ៊ីត ហើយបិទវានៅលើផ្ទាំងរូបភាពនីមួយៗ។ ឱ្យពួកគេដឹងថាពួកគេមិនចាំបាច់ឆ្លើយសំណួរទាំងអស់នោះទេ។ ពួកគេអាចជ្រើសរើសសំណួរ 3-4 ដែលពួកគេចាប់អារម្មណ៍។
4. បន្ទាប់ពីអ្នកចូលរួមបានបញ្ចប់ការបិទក្រដាស់ផុសអ៊ីត នៅលើផ្ទាំងរូបភាពហើយ ឱ្យពួកគេទៅកាន់ទីតាំងរូបភាពនោះ ហើយអានសំណួរ និងពិភាក្សាអំពីចម្លើយជាមួយសិក្ខាកាមផ្សេងទៀត។

លំដាប់នៃការពិនិត្យផ្ទាំងផុសស្ទ័រមិនជាបញ្ហានោះទេ ប្រសិនបើសិក្ខាកាមអាចផ្លាស់ទីដោយស្រួលនៅជុំវិញការតាំងផុសស្ទ័រនោះ។ ឱ្យសិក្ខាកាមពិភាក្សាចម្លើយ និងការយល់ឃើញរបស់គេតាមសំណួរដែលគេចាប់អារម្មណ៍។ ក្នុងអំឡុងពេលធ្វើសកម្មភាពនេះ គ្រូឧទ្ទេសគួរតែបដិសេធមិនផ្តល់ចម្លើយត្រឹមត្រូវដល់សិក្ខាកាម។ ប៉ុន្តែឱ្យពួកគេចែករំលែកគំនិត និងយោបល់របស់ពួកគេដោយសេរី។

5. បន្ទាប់ពីសិក្ខាកាមបានបញ្ចប់សំណួរទាំងអស់រួចហើយ ប្រាប់ពួកគេឱ្យត្រឡប់ទៅរកកន្លែងអង្គុយរបស់ពួកគេ។ ចែកឯកសារដល់ពួកគេអំពីការឆ្លើយតបខាងក្រោម ហើយផ្តល់ពេលគ្រប់គ្រាន់ដល់ពួកគេដើម្បីអានឯកសារនោះ។ បន្ទាប់ពីពួកគេអានចប់ហើយ ប្រសិនបើនរណាម្នាក់ចង់ចែករំលែកអ្វីមួយជាមួយក្រុម សូមឱ្យគាត់ចែករំលែក។ បន្ទាប់មក អនុញ្ញាតឱ្យអ្នកដទៃសួរសំណួរគាត់ និងចែករំលែកគំនិតរបស់ពួកគេអំពីអ្វីដែលបានចែករំលែកនោះ។

ជំពូកទី២

អ្វីទៅជាGCED

## ខ្លឹមសារមេរៀន

សំណួរទី ១

តើGCED បង្រៀន តែអំពីពិភព

GCED មិនពាក់ព័ន្ធតែនឹងចំណេះដឹងពិភពលោកនោះទេ។ ប៉ុន្តែតាមពិតវាមានសារសំខាន់ដែលត្រូវដឹងអំពីពិភពលោក និងបញ្ហាដែលយើងកំពុងជួបប្រទះ។ ការចាប់អារម្មណ៍ និងការសិក្សាអំពីអ្វីដែលនឹងកើតឡើងជុំវិញពិភពលោក ជុំវិញប្រទេស ជុំវិញសហគមន៍ និងជុំវិញវប្បធម៌ចម្រុះនានាគឺមានសារៈសំខាន់ណាស់ ព្រោះវាជំរុញឱ្យអ្នកសិក្សាមានសមត្ថភាពវិភាគបានស៊ីជម្រៅលើបាតុភូតសកល ហើយនាំពួកគេឱ្យមានការយល់ដឹងទូលំទូលាយអំពីភាពអាស្រ័យគ្នា និងភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ GCED មិនគ្រាន់តែជាការទទួលបានចំណេះដឹង (សមត្ថភាពចំណេះដឹង) ប៉ុណ្ណោះទេ។ ប៉ុន្តែចិត្តចលករសង្គមក៏មានសារៈសំខាន់ដូចគ្នាដែរ ដែលអ្នកសិក្សាគួរតែអាចបញ្ចូលឱ្យមានគុណតម្លៃសកលមានចិត្តសាមគ្គីភាពជាមួយអ្នកដទៃទាំងក្នុងមូលដ្ឋាននិងក្នុងប្រទេស ។ ជាងនេះទៅទៀត សមត្ថភាពនៃអាកប្បកិរិយាដែលអាចឱ្យអ្នកសិក្សាមានទំនួលខុសត្រូវ និងចូលរួមកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការដោះស្រាយបញ្ហាគួរតែត្រូវបានគូសបញ្ជាក់។

លើសពីនេះ GCED មិនត្រឹមតែដោះស្រាយបញ្ហាសកលប៉ុណ្ណោះទេ។ តែវាមានសារៈសំខាន់សម្រាប់អ្នកសិក្សាដើម្បីយល់ថាសង្គមរបស់យើងមានទំនាក់ទំនងគ្នាទៅវិញទៅមកនៅលើកម្រិតជាច្រើន។ ជីវិតប្រចាំថ្ងៃរបស់យើងប៉ះពាល់ដល់ពិភពលោកទាំងមូលព្រោះបញ្ហានៃប្រទេសមួយវាមិនមែនមានផលប៉ះពាល់តែក្នុងដែនសមត្ថកិច្ចរបស់ប្រទេសនោះតែឯងនោះទេ។ ដូច្នេះ GCED ត្រូវលើកទឹកចិត្តឱ្យអ្នកសិក្សាគិតដោយឯករាជ្យ សម្របខ្លួនទៅនឹងជីវិតរស់នៅរបស់ពួកគេ និងលើកទឹកចិត្តឱ្យចូលរួមដោយផ្ទាល់។ វាក៏គួរតែជំរុញឱ្យពួកគេដោះស្រាយបញ្ហាដែលប៉ះពាល់ដល់សហគមន៍រៀងៗខ្លួន ដែលផលប៉ះពាល់នេះក៏អាចប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

សំណួរទី ២

ដើម្បីបង្រៀនGCED តើគ្រូបង្រៀនត្រូវមានចំណេះដឹងអំពីប្រធានបទពាក់ព័ន្ធទាំងអស់ ដូចជាសកលភាវូបនីយកម្ម សិទ្ធិមនុស្ស និងសន្តិភាពដែរឬទេ?

វាមិនអាចទៅរួចទេដែលគ្រូបង្រៀនត្រូវមានចំណេះដឹងអំពីមេរៀន និងប្រធានបទទាំងអស់ដែលទាក់ទងនឹង GCED។ តែទោះជាយ៉ាងណាក៏ដោយ គ្រូម្នាក់យ៉ាងហោចណាស់គួរមានការយល់ដឹងអំពីបញ្ញត្តិនេះដែរដើម្បីបង្រៀនGCEDទៅមានអត្ថន័យត្រឹមត្រូវ។

វាជាការល្អដែលគ្រូបង្រៀនត្រូវដឹង និងមានកង្វល់អំពីបញ្ហានៅក្នុងសហគមន៍ និងពិភពលោក ហើយស្វែងយល់ពីបញ្ហាទាំងនោះរួមគ្នាជាមួយសិស្ស ជាជាងការចែកចាយចំណេះដឹងទៅដល់សិស្ស។ ដោយសារគោលការណ៍សិក្សា GCED គឺជាការសន្ទនា និងការស្រាវជ្រាវ ដូច្នេះគ្រូបង្រៀនត្រូវតែក្លាយទៅជាអ្នកសម្របសម្រួល និង ជាអ្នកផ្តល់ចំណេះដឹងតិចជាង តាមរយៈការរៀបចំសកម្មភាពលើកទឹកចិត្តដល់ការសិក្សាបែបសិស្សមជ្ឈមណ្ឌល និងការសិក្សាបែបសហការ។ តាមទស្សនៈនៃការរៀនពេញមួយជីវិត គ្រូបង្រៀនក៏ត្រូវខិតខំប្រឹងប្រែងឱ្យបានល្អក្នុងការរៀន និងលើកកម្ពស់សមត្ថភាពសិក្សារបស់សិស្សផងដែរ។

**សំណួរទី ៣**

តើ GCED មានគោលបំណងជួយប្រជាជនក្នុងភាពក្រីក្រទេ?

GCED លើកទឹកចិត្តអ្នកសិក្សាចាត់ទុកខ្លួនឯង និងអ្នកដទៃជាសមាជិកនៃគ្រួសារមនុស្សជាតិតែមួយ ដោយបំផុសគំនិតពួកគេឱ្យមានអារម្មណ៍សាមគ្គីភាពជាមួយសហគមន៍ពិភពលោកទាំងមូល។ អារម្មណ៍នៃកម្មសិទ្ធិសហគមន៍នេះគួរតែជំរុញអ្នកសិក្សាឱ្យផ្ដោតទៅលើបញ្ហាប្រឈម និងឧបសគ្គទាំងឡាយ ចំពោះគុណតម្លៃសកលដូចជាសិទ្ធិមនុស្ស យុត្តិធម៌សង្គម សមភាព ការគោរពភាពចម្រុះជាតិសាសន៍និងវប្បធម៌ និងសន្តិភាព មិនត្រឹមតែនៅក្នុងសហគមន៍និងប្រទេសរៀងៗខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅក្នុងផ្នែកផ្សេងទៀតនៃពិភពលោកផងដែរ។

ជាឧទាហរណ៍ សាលារៀននៅក្នុងប្រទេសអភិវឌ្ឍន៍បង្កើតឱកាសសម្រាប់សិស្សឱ្យចូលរួមសកម្មភាពសប្បុរសធម៌ និងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះដើម្បីជួយប្រជាជនដែលជួបការលំបាកក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ប្រភេទនៃការចូលរួមដែលផ្ដោតលើសិស្សអាចជំរុញអាកប្បកិរិយាជំរុញពួកគេឱ្យចូលរួមក្នុងការដោះស្រាយបញ្ហាសកល។ ទោះជាយ៉ាងណាក៏ដោយ យើងគួរតែប្រុងប្រយ័ត្នចំពោះការឱ្យសិស្សអនុវត្តសកម្មភាពសប្បុរសធម៌បែបនេះ ព្រោះវាអាចពង្រឹងភាពមិនច្បាស់លាស់របស់ពួកគេចំពោះមនុស្សមកពីផ្នែកផ្សេងៗនៃពិភពលោកដោយអចេតនា។ ជាឧទាហរណ៍ ការបរិច្ចាគនាំឱ្យមានការយល់ខុសអំពីអ្នកទទួល ហើយប្រហែលជាធ្វើឱ្យអ្នកសិក្សាមានអារម្មណ៍ខ្លួនគេជាអ្នកអស្ចារ្យ។ ដូច្នេះ សកម្មភាពសប្បុរសធម៌គួរតែត្រូវបានរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ជាមួយនឹងសារច្បាស់លាស់ថា សកម្មភាពទាំងនេះកើតចេញពីទំនួលខុសត្រូវរួម និងក្នុងនាមជាមនុស្សជាតិ ជាជាងការអាណិតអាសូរធម្មតាចំពោះប្រជាជនក្នុងភាពក្រីក្រ ឬក្នុងស្ថានភាពលំបាក។

យើងក៏ត្រូវដឹងដែរថា ជំនាញត្រិះរិះពិចារណារបស់អ្នកសិក្សានៅមានកម្រិត នៅពេលដែលពួកគេមានបញ្ហាស្មុគស្មាញខ្លាំងពេក។ ឧទាហរណ៍ មនុស្សមួយចំនួនសម្រួលបញ្ហានៃភាពក្រីក្រដោយចាត់ទុកវាជាបញ្ហាបុគ្គល ឬជាបញ្ហាប្រទេសជាជាងបញ្ហាសង្គម នយោបាយ ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលទាក់ទងគ្នាទៅវិញទៅមក។ ម្យ៉ាងទៀត យើងមិនគួរមើលរំលងការពិតដែលថាបញ្ហាសមភាព និងភាពក្រីក្រ ជាពិសេសបញ្ហាដែលកើតឡើងដោយសាកលភាវូបនីយកម្ម ដែលមានមិនត្រឹមតែនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងប្រទេសអភិវឌ្ឍន៍ក៏មានផងដែរ។ ម្យ៉ាងវិញទៀត និស្សិតត្រូវបានលើកទឹកចិត្តឱ្យចងចាំថា ប្រជាជនមកពីប្រទេសមិនទាន់អភិវឌ្ឍន៍ ក៏ដូចគ្នានឹងពលរដ្ឋពិភពលោកដែលមានសិទ្ធិ និងកាតព្វកិច្ចដូចគ្នាទៅនឹងមនុស្សគ្រប់រូបដែរ។

សំណួរទី ៤

GCED គឺពិបាកពេក សម្រាប់សិស្សវ័យក្មេង។ តើ GCED អាចត្រូវបាន បង្រៀននៅគ្រប់កម្រិត នៃអ្នកសិក្សាដែរឬទេ?

ការបង្រៀនចំណេះដឹងលំបាក និងស្មុគ្រស្មាញរបស់ពិភពលោកមិនមែនជាគោលដៅ GCED នោះទេ។ គោលដៅចម្បងរបស់ GCED គឺលើកកម្ពស់សមត្ថភាពចំណេះដឹង ចិត្តចលករសង្គម និងអាកប្បកិរិយា ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការបង្រៀន GCED ដល់សិស្សានុសិស្សហើយវាជាពេលវេលាដ៏សំខាន់មួយ ក្នុងការលត់ដំអាកប្បកិរិយា និងលើកកម្ពស់គុណតម្លៃរបស់ពួកគេ។ គ្រូបង្រៀនគួរជ្រើសរើសប្រធានបទ និងមុខវិជ្ជា ដោយកំណត់គោលបំណងសិក្សាដែលសមស្របទៅនឹងអាយុរបស់សិស្ស។ វិធីនេះ GCED នៅតែអាចត្រូវបានបង្រៀនដល់អ្នកសិក្សាវ័យក្មេង។

មធ្យោបាយមួយគឺត្រូវរកប្រធានបទដែលត្រូវទៅនឹងអាយុរបស់សិស្ស។ ឧទាហរណ៍ ប្រសិនបើប្រធានបទនិយាយអំពីការគោរពវប្បធម៌ចម្រុះ សិស្សសាលាបឋមសិក្សាកម្រិតទាបក៏អាចទទួលស្គាល់ភាពខុសគ្នានោះបានដែរ។ ទោះជាយ៉ាងណាក្តី ពួកគេគួរតែត្រូវបានបង្រៀនថាមនុស្សទាំងអស់មានសិទ្ធិ និងទំនួលខុសត្រូវដូចៗគ្នា។ ប្រធានបទនេះដែរ សិស្សសាលាបឋមសិក្សាកម្រិតខ្ពស់ហើយមានបទពិសោធន៍អាចមានការរើសអើង។ សិស្សអនុវិទ្យាល័យអាចបង្រៀនអំពីជម្លោះ (នៅកម្រិតមូលដ្ឋាន និងសកល) ក្នុងស្ថានភាពចម្រុះ និងពហុនិយមបាន ហើយអ្វីដែលសំខាន់គឺបង្រៀនពួកគេឱ្យចេះដោះស្រាយបញ្ហា ឬកាត់បន្ថយបញ្ហាបាន។ សម្រាប់សិស្សវិទ្យាល័យ ពួកគេអាចត្រូវបានបង្រៀនឱ្យយល់ផ្សេងៗគ្នា និងមានទស្សនៈផ្សេងៗគ្នាអំពីបញ្ហាសកលដ៏ស្មុគស្មាញ ដែលឆ្លងកាត់ព្រំដែននៃសហគមន៍មូលដ្ឋានរៀងៗខ្លួន ក៏ដូចជាវិធីដោះស្រាយបញ្ហាទាំងនោះ។

**សំណួរទី ៥**

តើ GCED មានការប្រកួតប្រជែងជាមួយចលនាអប់រំផ្សេងទៀត ដូចជាការអប់រំពហុវប្បធម៌ ការអប់រំសិទ្ធិមនុស្ស និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែរឬទេ?

គ្មានចលនាអប់រំដូចជាការអប់រំសិទ្ធិមនុស្ស ការអប់រំសន្តិភាព ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំពហុវប្បធម៌ ត្រូវបានផ្សព្វផ្សាយនៅក្នុងរង្វង់ស្ថាប័នអប់រំផ្សេងៗតាមតម្រូវការនៃពេលវេលាដែលពួកគេបានលើកឡើងនោះទេ។ ទោះបីជាពួកគេទាំងអស់មានឈ្មោះផ្សេងគ្នាក៏ដោយ ក៏តម្លៃ និងបញ្ហាដែលត្រូវបានគូសបញ្ជាក់ដោយចលនាអប់រំទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។

ពួកគេក៏មានគោលដៅរួមគ្នាក្នុងការធ្វើឱ្យសង្គមមានសន្តិភាព យុត្តិធម៌ និងអធ្យាស្រ័យគ្នាជាងមុន។ ម៉្យាងវិញទៀត បើទោះបីជាពួកគេមានចំណងជើងខុសគ្នាក៏ដោយ គោលបំណង ខ្លឹមសារ និងគុណតម្លៃដែលពួកគេបានគូសបញ្ជាក់គឺស្រដៀងគ្នាខ្លាំងណាស់។ ដូច្នេះ វាមិនត្រូវបានផ្ដល់អនុសាសន៍ឱ្យមើលចលនាអប់រំទាំងនេះ និង GCED ថាមានលក្ខណៈផ្ដាច់មុខ ឬផ្ទុយគ្នានោះទេ។ GCED ត្រូវបានគេមើលឃើញយ៉ាងល្អបំផុតថាជាគោលគំនិតរួមដែលទទួលយកចលនាអប់រំទាំងអស់នេះ។

**សំណួរទី ៦**

តើសកម្មភាពផ្លាស់ប្ដូរអន្តរជាតិជាផ្នែកសំខាន់នៃ GCED ដែរឬទេ?

ការផ្លាស់ប្ដូរអន្តរជាតិ និងសកម្មភាពស្រដៀងគ្នាគឺជាឧបករណ៍អប់រំដ៏ល្អដើម្បីបង្រៀន GCED ។ សិស្សអាចស្វែងយល់អំពីប្រទេស និងសង្គមផ្សេងទៀត រៀនពីរបៀបគោរពវប្បធម៌ផ្សេងទៀតតាមរយៈបទពិសោធន៍ និងដឹងថាមនុស្សមកពីប្រទេសផ្សេងទៀតគឺជាសមាជិកនៃមនុស្សជាតិទូទៅមួយ។ ទោះជាយ៉ាងណាក៏ដោយ GCED មិនត្រឹមតែជាការទទួលបានបទពិសោធន៍នៅបរទេស ឬបង្កើតទំនាក់ទំនងជាមួយប្រទេសផ្សេងទៀត និងប្រជាជនរបស់ពួកគេប៉ុណ្ណោះទេ។

ផ្ទុយទៅវិញ GCED ក៏លើកទឹកចិត្តសិស្សឱ្យរៀនពីរបៀបមើលហួសពីព្រំដែនជាតិ និងរបៀបប្រាស្រ័យទាក់ទងគ្នាដោយសន្តិវិធី និងរស់នៅជាមួយមនុស្សផ្សេងទៀត។ ដូច្នេះ ការឱបក្រសោប និងគោរពភាពចម្រុះនៅក្នុងសហគមន៍ និងប្រទេសផ្ទាល់ខ្លួនក៏ជាធាតុសំខាន់នៃ GCED ផងដែរ។ ដើម្បីឱ្យសកម្មភាពផ្លាស់ប្តូរអន្តរជាតិក្លាយជា GCED ក្រៅពីការរៀនវិធីដើម្បីទទួលបានបទពិសោធន៍ពីវប្បធម៌ផ្សេងទៀត និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ការជួបជាមួយ "អ្នកដទៃ" គួរតែជាឱកាសសម្រាប់អ្នកសិក្សាដើម្បីឆ្លុះបញ្ចាំងពីខ្លួនឯង។ ដូច្នេះ វាមានសារៈសំខាន់ជាពិសេសក្នុងការលុបចោលទស្សនៈផ្ទាល់ខ្លួនរបស់បុគ្គល ចំពោះវប្បធម៌ផ្សេងទៀត តាមរយៈបទពិសោធន៍នេះ។ បើមិនដូច្នោះទេ ការជួបជាមួយ "អ្នកដទៃ" អាចពង្រឹងទស្សនៈទាំងនោះ ឬខ្វះការទទួលស្គាល់អត្តិភាព "អ្នកដទៃ" ដែលផ្ទុយពីគោលបំណង និងគុណតម្លៃរបស់ GCED ។



GCED នៅក្នុងប្រទេសជាច្រើនត្រូវបានបញ្ជ្រាបចូលទៅក្នុងមុខវិជ្ជាដែលពាក់ព័ន្ធ ឬត្រូវបានគេចាត់ទុកថាជាមេរៀនមួយជាជាងចាត់ទុកថាជាមុខវិជ្ជាមួយ។ ជាញឹកញយមេរៀន GCED ត្រូវបានបង្កប់នៅក្នុងមុខវិជ្ជាការសិក្សាសង្គម ដើម្បីពង្រីកចំណេះដឹងសិស្សអំពីបាតុភូតសង្គម និងបញ្ហាសកល។ ទោះជាយ៉ាងណាក៏ដោយ GCED អាចត្រូវបានបញ្ចូលទៅក្នុងមុខវិជ្ជាជាច្រើនដូចជា មុខវិជ្ជាភាសា គណិតវិទ្យា សិល្បៈ វិទ្យាសាស្ត្រ និងមុខវិជ្ជាជាច្រើនទៀត។ តាមរយៈការយល់ដឹងពីស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈចម្រុះ សិស្សអាចរៀនពីគុណតម្លៃសកល និងរបៀបគោរពចំពោះភាពចម្រុះទាំងនោះ។ លើសពីនេះ តាមរយៈការស្វែងរកការពិតតាមបែបវិទ្យាសាស្ត្រ និងច្បាប់ជាលេខ អ្នកសិក្សាអាចយល់យ៉ាងទូលំទូលាយអំពីពិភពលោកដ៏ស្មុគស្មាញ និងពិនិត្យមើលការពិតរបស់វា។

GCED អាច និងគួរតែត្រូវបានចែកចាយតាមរយៈវិធីសាស្ត្រ និងឧបករណ៍បង្រៀនភាគច្រើន។ ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃដំណើរការសិក្សាដែលជួយសម្រួលដល់ការចូលរួម និងការសន្ទនារបស់សិស្ស សកម្មភាពជាច្រើនអាចត្រូវបានរៀបចំឡើង។ សកម្មភាពក្លឹប សកម្មភាពក្រៅកម្មវិធីសិក្សា និងសូម្បីតែសេវាសហគមន៍ក៏អាចបម្រើជាកន្លែងដ៏អស្ចារ្យសម្រាប់ GCEDផងដែរ។ ជាងនេះទៅទៀត សូមក្រើនរំលឹកថា វិធីសាស្ត្រជាប្រព័ន្ធមានសារៈសំខាន់ណាស់ក្នុងទម្រង់នៃសកម្មភាព GCED ណាក៏ដោយ។

### កំណាត់ចំណាំរបស់គ្រូខ្ទេស

ចម្លើយដែលបង្ហាញក្នុងផ្នែកនេះផ្តល់តែចម្លើយនោះទេ។ យើងសូមណែនាំគ្រូឧទ្ទេសឱ្យជួយសម្រួលដល់ការពិភាក្សាក្នុងចំណោមសិក្ខាកាម ជាជាងការផ្តល់ 'ចម្លើយត្រឹមត្រូវ' ទៅដល់ពួកគេ។

### ការឆ្លុះបញ្ចាំងនិងការសង្ខេប

| | |
|---|---|
| រយៈពេល | ៣០នាទី |
| វត្ថុបំណង | ដើម្បីចែករំលែកនូវអ្វីដែលពួកគេបានរៀននៅក្នុងមេរៀននេះ និងអ្វីដែលពួកគេសង្ឃឹមថានឹងរៀននៅក្នុងមេរៀនបន្ទាប់ |

**សកម្មភាព៖** ចែករំលែកគំនិតនិងការយល់ឃើញ

### តើនរណាជាពលរដ្ឋសកល?

### ជំហាន៖

4. ឱ្យសិក្ខាកាមអង្គុយជារង្វង់មួយ (ប្រសិនបើវាមិនងាយស្រួលក្នុងការរៀបចំកៅអីឡើងវិញទេ សុំឱ្យសិក្ខាកាមផ្លាស់ប្តូរទីតាំងអង្គុយរបស់ពួកគេបន្តិចដើម្បីឱ្យពួកគេមើលឃើញគ្នាទៅវិញទៅមក)។
5. ឱ្យសិក្ខាកាមគិតអំពីអ្វីថ្មីដែលពួកគេបានរៀន អ្វីដែលពួកគេចាប់អារម្មណ៍បំផុត និងអ្វីដែលពួកគេចេះច្បាស់ហើយចង់រៀនបន្ថែម។ ណែនាំពួកគេ ដូចជាឱ្យមើលផ្ទាំងរូបភាពដែលពួកគេបានធ្វើពីមុនក្នុងអំឡុងពេលរៀន។
6. បន្ទាប់មក ឱ្យពួកគេចែករំលែកគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីសំណួរដែលចាប់ផ្តើមពីអ្នកដែលមានបំណងចង់ស្ម័គ្រចិត្ត។



## កំណាត់ចំណាំរបស់គ្រូឧទ្ទេស

ដោយសារសកម្មភាពនេះធ្វើបានល្អបំផុតហើយ ប្រសិនបើសិក្ខាកាមភាគច្រើន ឬទាំងអស់ចែករំលែកគំនិត និងការយល់ឃើញរបស់ពួកគេ យើងសូមផ្ដល់អនុសាសន៍ ឱ្យពួកគេអង្គុយជារង្វង់មួយតាមដែលអាចធ្វើបាន ហើយប្រាកដថាពួកគេមានអារម្មណ៍សុខស្រួល។ កៅអីដែលរៀបចំជារង្វង់អាចលើកកម្ពស់សហគមន៍ និងលើកទឹកចិត្តសិក្ខាកាមទាំងអស់ឱ្យចូលរួមក្នុងការសន្ទនា។ ការរៀបចំកន្លែងអង្គុយបែបនេះធ្វើឱ្យមនុស្សគ្រប់រូបចូលរួមនៅក្នុងក្រុម លើកទឹកចិត្តមនុស្សឱ្យនិយាយដោយស្រួលៗចំពោះគ្នាទៅវិញទៅមក ទំនាក់ទំនងភ្នែក និងបង្កើតអារម្មណ៍សមភាពក្នុងក្រុម។

ទិដ្ឋភាពសំខាន់នៃសិក្ខាសាលា GCED គឺការចូលរួមយ៉ាងសកម្មរបស់សិក្ខាកាម។ ដូច្នេះ វាមានសារៈសំខាន់ណាស់សម្រាប់សិក្ខាកាមចែករំលែកជាមួយមនុស្សគ្រប់គ្នានៅក្នុងក្រុមអំពីអ្វីដែលពួកគេគិត ឬមានអារម្មណ៍បន្ទាប់ពីវគ្គ។ ដោយសារសិក្ខាកាមមួយចំនួនប្រហែលជាស្ទាក់ស្ទើរក្នុងការនិយាយនៅចំពោះមុខមនុស្សជាច្រើន អ្នកសម្របសម្រួលគួរតែបង្កើតបរិយាកាសមួយដែលពួកគេអាចនិយាយ ឬបញ្ចេញមតិដោយសេរីក្នុងទម្រង់ផ្សេងៗបាន។ គ្រូឧទ្ទេសត្រូវបានផ្ដល់អនុសាសន៍ឱ្យទទួលយកមតិរបស់សិក្ខាកាម ហើយឆ្លើយតបទៅពួកគេក្នុងលក្ខណៈវិជ្ជមាន និងប្រកបដោយការគិត ដូច្នេះពួកគេអាចមានអារម្មណ៍ថាមតិរបស់ពួកគេត្រូវបានទទួលយក និងត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង។ ដូចគ្នានេះផងដែរ គ្រូឧទ្ទេសគួរតែព្យាយាមផ្ដល់ឱកាសឱ្យស្មើៗគ្នាក្នុងការចែករំលែក ក្នុងចំណោមអ្នកចូលរួម និងធ្វើអន្តរាគមន៍នៅពេលដែលការពិភាក្សាត្រូវបានគ្របដណ្ដប់ដោយអ្នកចូលរួមពីរបីនាក់។

# ជំពូក ៣

## GCED: បង្រៀនពីអ្វី?

# ជំពូក ៣

## អ្វីដែលត្រូវបង្រៀន GCED?

| | |
|---|---|
| ទិដ្ឋភាពរួម | ជំពូកនេះមានគោលបំណងជួយសិក្ខាកាមឱ្យយល់កាន់តែស៊ីជម្រៅទៅលើវិមាត្របញ្ញត្តិគោលរបស់GCED ដោយបង្ហាញពីមេរៀន និងប្រធានបទ។ ជំពូកនេះ ភាគច្រើនផ្អែកលើគោលការណ៍ណែនាំរបស់អង្គការយូណេស្កូលើការបង្រៀន GCED ដែលមានចំណងជើងថា 'GCED: មេរៀន និងគោលបំណងនៃការរៀន (TLOs)។ គោលបំណងនៃការរៀនបានចង្អុលបង្ហាញនូវមេរៀនចំនួនប្រាំបួន រួមជាមួយនឹងគោលបំណងសិក្សាដែលសមស្របតាមអាយុ និងប្រធានបទសំខាន់ៗដែលអ្នកអប់រំអាចយកធ្វើជាឯកសារយោងនៅពេលបញ្ចូល GCED ទៅក្នុងមុខវិជ្ជា និងសកម្មភាពសិក្សារបស់ពួកគេ។ |
| មេរៀន | 1. ប្រធានបទនៃ GCED<br>2. ខ្លឹមសារនៃការសិក្សា GCED ដោយផ្អែកលើគោលការណ៍ណែនាំរបស់អង្គការយូណេស្កូ |
| លទ្ធផលរំពឹងទុក | 1. មានការយល់ដឹងលើប្រធានបទស្នូលនៃ GCED<br>2. កំណត់ប្រធានបទសំខាន់ៗ និងគោលបំណងសិក្សាដែលសមស្របតាមអាយុរបស់ GCED<br>3. បកបកស្រាយពីបញ្ញត្តិ និងគុណតម្លៃរបស់ GCED ឱ្យទៅជាប្រធានបទជាក់លាក់ និងខ្លឹមសារមេរៀន |
| ដំណើរការបង្រៀន | 1. ការចាប់ផ្ដើម / លំនឹងថ្នាក់ (30 នាទី)<br>• [សកម្មភាព] "វប្បធម៌សន្តិភាព" និង GCED<br>2. ខ្លឹមសារមេរៀន (70 នាទី)<br>• ប្រធានបទមេរៀន GCED<br>• ខ្លឹមសារមេរៀន GCED<br>3. ការឆ្លុះបញ្ចាំង/សង្ខេប (20 នាទី)<br>• ផ្លាស់ប្ដូរការយល់ឃើញរបស់អ្នកសម្រាប់ GCED |
| ឯកសារយោង | អង្គការយូណេស្កូ៖ ការអប់រំជាពលរដ្ឋសកល៖ ចំណងជើងមេរៀន និងវត្ថុបំណងសិក្សា ឆ្នាំ 2015 ។ |

ជំពូកទី៣

GCED បង្រៀនពីអ្វី?

## សេចក្តីផ្តើម

| | |
|---|---|
| រយៈពេល | ៣០នាទី |
| វត្ថុបំណង | · បំផុសគំនិតទាក់ទងនឹងប្រធានបទ GCED<br>· យល់ថាប្រធានបទមានទំនាក់ទំនងគ្នាទៅវិញទៅមក |

សកម្មភាព៖ វប្បធម៌សន្តិភាព និងGCED

### ជំហាន

1. ចាប់ផ្តើមសកម្មភាពដោយសង្ខេបខ្លឹមសារដែលបានរៀននៅក្នុងជំពូកមុន។ អានបញ្ញត្តិGCED ដោយសង្ខេប រួចគូសបញ្ជាក់ថា GCED ផ្តល់នូវចំណេះដឹង ជំនាញ គុណតម្លៃ និងអាកប្បកិរិយាចាំបាច់ដល់អ្នកសិក្សា ដើម្បីឱ្យពិភពលោកកាន់តែមានយុត្តិធម៌ សន្តិភាព និរន្តរភាពជាមួយនឹង "វប្បធម៌សន្តិភាព"។
2. ឱ្យសិក្ខាកាមចូលរួមមតិយោបល់ស្តីពីយុត្តិធម៌ សន្តិភាព និងរបៀបជំរុញ "វប្បធម៌សន្តិភាព" នៅក្នុងសហគមន៍។
3. បង្ហាញមតិលើកឡើងមួយចំនួនអំពីសន្តិភាពនៅលើអេក្រង់ (អ្នកអាចយោងទៅលើសម្រង់ខាងក្រោមជាឧទាហរណ៍)៖

> ប្រសិនបើយើងគ្មានសន្តិភាពទេ គឺដោយសារតែយើងភ្លេចថាយើងពឹងអាស្រ័យគ្នាទៅវិញទៅមក» (Mother Teresa)។
>
> “យើងមិនអាចមានសន្តិភាពជាមួយពិភពខាងក្រៅបាននោះទេ ប្រសិនបើយើងមិនបង្កើតសន្តិភាពជាមួយគ្នាយើងបាននោះ” (ដាឡៃឡាម៉ា)។
>
> «បើអ្នកចង់បានសន្តិភាព អ្នកមិនត្រូវនិយាយជាមួយមិត្តភក្តិរបស់អ្នកទេ។ អ្នកត្រូវនិយាយជាមួយសត្រូវរបស់អ្នក” (Desmond Tutu)។

"សន្តិភាពមិនមែនជាទំនាក់ទំនងរបស់ប្រទេសជាតិនោះទេ។ វាជាលក្ខខណ្ឌដែលនាំមកនូវព្រលឹងស្ងប់ស្ងាត់។ សន្តិភាពមិនមែនគ្រាន់តែគ្មានសង្គ្រាមទេ។ វាក៏ជាស្ថានភាពនៃចិត្ត»ផងដែរ (Jawaharlal Nehru)

«សន្តិភាពសំខាន់ជាងយុត្តិធម៌ ហើយសន្តិភាពមិនត្រូវបានបង្កើតឡើងដើម្បីយុត្តិធម៌ទេ ប៉ុន្តែយុត្តិធម៌ដើម្បីសន្តិភាព» (ម៉ាទីន លូធើ)។

«មនុស្សជាតិត្រូវតែចាំថាសន្តិភាពមិនមែនជាអំណោយរបស់ព្រះដល់សត្វលោកនោះទេ វាគឺជាអំណោយរបស់យើងដល់គ្នាទៅវិញទៅមក» (Elie Wiesel)។

4. ទុកពេលឱ្យសិក្ខាកាមអាន និងគិតអំពីមតិយោបល់។ ឱ្យសិក្ខាកាមពិភាក្សាគំនិតសន្តិភាព របៀបដែលពួកគេយល់ឃើញ និងអ្វីដែលពួកគេអាចធ្វើឱ្យសម្រេចបាន។

5. ចែកជូនឯកសារ "Manifesto 2000 វប្បធម៌សន្តិភាពនិងគ្មានអំពើហឹង្សា" ដូចដែលបានបង្ហាញខាងក្រោម។ ទុកពេលបីនាទីដើម្បីអាន។ នៅពេលពួកគេអានតាមរយៈការដកស្រង់ សូមឱ្យពួកគេរកមើលប្រធានបទដែលទាក់ទងនឹង GCED ដូចជា ភាពចម្រុះនៃវប្បធម៌ សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។

### Manifesto 2000 សម្រាប់វប្បធម៌សន្តិភាព និងអហិង្សា

ឆ្នាំ 2000 ជាឆ្នាំនៃការចាប់ផ្តើមថ្មីសម្រាប់យើងទាំងអស់គ្នា។ បើយើងរួមគ្នា យើងអាចប្រែក្លាយវប្បធម៌សង្គ្រាម និងអំពើហិង្សាទៅជាវប្បធម៌សន្តិភាព និងអហិង្សា។ សម្រេចទិសដៅនេះបានទាមទារឱ្យមានការចូលរួមពីមនុស្សគ្រប់គ្នា ហើយផ្តល់ឱ្យយុវជន និងមនុស្សជំនាន់ក្រោយនូវគុណតម្លៃដែលអាចបំផុសគំនិតពួកគេឱ្យបង្កើតពិភពនៃសេចក្តីថ្លៃថ្នូរ និងភាពសុខដុមរមនា ពិភពនៃយុត្តិធម៌ សាមគ្គីភាព សេរីភាព និងវិបុលភាព។ វប្បធម៌សន្តិភាពធ្វើឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការការពារបរិស្ថាន និងការក្លាយខ្លួនជាមនុស្សជាតិម្នាក់ៗ។

ដោយទទួលស្គាល់នូវចំណែកនៃទំនួលខុសត្រូវរបស់ខ្ញុំសម្រាប់អនាគតរបស់មនុស្សជាតិ ជាពិសេសសម្រាប់កូនៗសព្វថ្ងៃ និងមនុស្សជំនាន់ក្រោយ ខ្ញុំសន្យា - ក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ក្នុងគ្រួសារខ្ញុំ ការងាររបស់ខ្ញុំ សហគមន៍របស់ខ្ញុំ ប្រទេសរបស់ខ្ញុំ និងតំបន់របស់ខ្ញុំ"ផងដែរ។

ជំពូកទី៣

GCED បង្រៀនពីអ្វី?

## សេចក្ដីផ្ដើម

1. គោរពជីវិត និងសេចក្ដីថ្លៃថ្នូររបស់មនុស្សគ្រប់រូបដោយគ្មានការរើសអើង។
2. អនុវត្តសកម្មភាពអហឹង្សា បដិសេធអំពើហឹង្សាគ្រប់ទម្រង់ទាំង៖ ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត សេដ្ឋកិច្ច និងសង្គម ជាពិសេសចំពោះជនក្រីក្រ និងងាយរងគ្រោះបំផុត ដូចជាកុមារ និងមនុស្សវ័យជំទង់។
3. ចែករំលែកពេលវេលា និងធនធានសម្ភារៈរបស់ខ្ញុំក្នុងស្មារតីសប្បុរសធម៌ ដើម្បីបញ្ចប់ការមិនរាប់បញ្ចូល ភាពអយុត្តិធម៌ និងការគៀបសង្កត់ផ្នែកនយោបាយ និងសេដ្ឋកិច្ច។
4. ការពារសេរីភាពនៃការបញ្ចេញមតិ និងភាពចម្រុះនៃវប្បធម៌ ដោយផ្ដល់ចំណូលចិត្តជានិច្ចចំពោះការសន្ទនា និងការស្ដាប់ ជាជាងការនិយមជ្រុល ការបរិហារកេរ្តិ៍ និងការបដិសេធរបស់អ្នកដទៃ។
5. លើកកម្ពស់អាកប្បកិរិយាអ្នកប្រើប្រាស់ដែលមានទំនួលខុសត្រូវ និងអនុវត្តការអភិវឌ្ឍដែលគោរពគ្រប់ទម្រង់នៃជីវិត និងរក្សាតុល្យភាពនៃធម្មជាតិនៅលើភពផែនដី។
6. ចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍របស់ខ្ញុំ ដោយមានការចូលរួមយ៉ាងពេញទំហឹងពីស្ត្រី និងការគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតនូវទម្រង់សាមគ្គីភាពថ្មី។
7. ខណៈពេលដែលអ្នកចូលរួមកំពុងអាន manifesto សូមគូរបណ្ដាញពីងពាងនៅលើក្ដារដូចបានបង្ហាញខាងក្រោម។
8. សុំឱ្យសិក្ខាកាមម្នាក់ៗចែករំលែកប្រធានបទដែលពួកគេបានរកឃើញនៅក្នុង manifesto ហើយឱ្យពួកគេសរសេរវានៅលើបណ្ដាញពីងពាង។ សូមមើលឧទាហរណ៍ខាងក្រោម។

### ការអប់រំនាពលរដ្ឋសកល



## ខ្លឹមសារមេរៀន

| រយៈពេល | ៦០-១២០ នាទី |
| --- | --- |
| វត្ថុបំណង | · ទទួលបានការយល់ដឹងអំពីប្រធានបទស្នូលនៃ GCED<br>· កំណត់ប្រធានបទសំខាន់ៗ និងគោលបំណងសិក្សាតាមអាយុរបស់ GCED<br>· យល់ពីរបៀបកំណត់វត្ថុបំណងជាក់លាក់ដែលទាក់ទងទៅនឹងប្រធានបទដែលត្រូវបង្រៀន និងអាយុរបស់អ្នករៀន |

### ប្រធានបទនៃ GCED

### អ្វីដែលត្រូវធ្វើ៖

1. ចាប់ផ្តើមមេរៀនដោយការពិភាក្សាទៅលើមេរៀនមុន។
2. បង្ហាញចំណងជើងដែលទាក់ទងនឹង GCED យ៉ាងលម្អិតដោយប្រើឧបករណ៍ជំនួយដែលមើលឃើញ (ឧ. ឯកសារបទបង្ហាញ វីដេអូ) ដើម្បីជួយពន្យល់ពីគោលគំនិត។

GCED ជាប់ទាក់ទងនឹងភាពស្មុគស្មាញ ភាពប្រទាក់ក្រឡាគ្នា និងភាពពឹងពាក់គ្នាទៅវិញទៅមកនៃបញ្ហាក្នុងស្រុក និងពិភពលោក ព្រមទាំងវិធីដោះស្រាយបញ្ហាទាំងនេះ តាមរយៈសកម្មភាពរួមនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតអន្តរជាតិ។ សំខាន់ជាងនេះទៅទៀត វាជាវិធីសាស្ត្រអប់រំមួយដែលនាំឱ្យមានការផ្លាស់ប្តូរ។ GCED លើកកម្ពស់គុណតម្លៃជាច្រើនដូចជា៖ យុត្តិធម៌ ការគោរពភាពចម្រុះ និងសាមគ្គីភាពសម្រាប់មនុស្សជាតិ។ លើកទឹកចិត្តអ្នកសិក្សាឱ្យក្លាយជាពលរដ្ឋសកម្មដើម្បីបង្កើតពិភពលោកកាន់តែមានភាពយុត្តិធម៌ សន្តិភាព និងនិរន្តរភាពសម្រាប់ទាំងអស់គ្នា។ ហេតុដូច្នេះហើយ ប្រធានបទខាងក្រោមត្រូវបានកំណត់ថាជាផ្នែកស្នូលនៃការបង្រៀន GCEDរួមមាន៖ សិទ្ធិមនុស្ស សន្តិភាព និងជម្លោះ ការគោរពភាពចម្រុះ សកលភាវូបនីយកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព។




### កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

សូមកត់ចំណាំថា គ្រូបង្រៀនមិនចាំបាច់តែអ្នកជំនាញលើប្រធានបទខ្លះឬទាំងអស់នោះទេ។ វាមិនអាចទៅរួចទេដែលគ្រូបង្រៀនមានចំណេះដឹងទាក់ទងទៅនឹងប្រធានបទការលើកកម្ពស់ភាពជាពលរដ្ឋសកល។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនត្រូវបានលើកទឹកចិត្តយ៉ាងហោចណាស់ត្រូវមានការយល់ដឹងពីបញ្ញត្តិទាំងនេះ ហើយមានចំណាប់អារម្មណ៍ខ្លាំងលើបញ្ហាដែលកំពុងកើតឡើងនៅកម្រិតមូលដ្ឋាន និងពិភពលោក។ អ្នកអប់រំមិនគួរគ្រាន់តែបញ្ជូនព័ត៌មានអំពីប្រធានបទ និងប្រធានបទទាក់ទងនឹង GCED ដល់សិស្សនោះទេ។ ផ្ទុយទៅវិញ ពួកគេត្រូវតែដើរតួនាទីជាអ្នកសម្របសម្រួលដោយស្មើភាពគ្នា តាមរយៈការលើកកម្ពស់ការចូលរួមរៀនក្នុងចំណោមអ្នកសិក្សា ដោយផ្អែកលើការសន្ទនា និងការសាកសួរឥតឈប់ឈរ។

ខ្លឹមសារមេរៀន

## ជំពូកទី៣
## GCED បង្រៀនពីអ្វី?

### សិទ្ធិមនុស្ស

អ្នកសិក្សាទាំងអស់យល់ថា សិទ្ធិមនុស្ស គឺជាសិទ្ធិសម្រាប់មនុស្សគ្រប់រូប មិនថាយើងជានរណា ជាតិសាសន៍អ្វី ភេទអ្វី ជនជាតិអ្វី ពណ៌សម្បុរ សាសនា ភាសា ឬស្ថានភាពផ្សេងទៀតរបស់យើងបែបណានោះទេ។ «យើងទាំងអស់គ្នាមានសិទ្ធិស្មើគ្នា ដោយគ្មានការរើសអើង។ សិទ្ធិទាំងនេះសុទ្ធតែមានទំនាក់ទំនងគ្នាទៅវិញទៅមក អាស្រ័យគ្នាទៅវិញទៅមក និងមិនអាចបំបែកបាន❼។ សិទ្ធិមនុស្សត្រូវបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ហើយត្រូវបានលើកឡើងនៅក្នុងអនុសញ្ញា សន្ធិសញ្ញា និងសេចក្តីប្រកាសអន្តរជាតិផ្សេងៗ លើកឡើងនៅក្នុងធម្មនុញ្ញតំបន់ ក៏ដូចជានៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ។ ក្រៅពីឧបករណ៍ច្បាប់ទាំងនេះ សិទ្ធិមនុស្ស បង្ហាញនូវអ្វីម្យ៉ាងអំពីលក្ខណៈបុគ្គល។ ពួកគេក៏ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការការពារសិទ្ធិជាមូលដ្ឋានបំផុតនៃសិទ្ធិទាំងអស់ដែរគឺសិទ្ធិក្នុងការធ្វើជាមនុស្ស។ តាមរយៈការបង្រៀនសិទ្ធិមនុស្ស សិស្សទទួលបានការយល់ដឹងអំពីសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ដែលធានាការគោរពសិទ្ធិរបស់មនុស្សគ្រប់រូប។

### ជម្លោះ និងការកសាងសន្តិភាព

អ្នកសិក្សាទទួលបានការយល់ដឹងអំពីទម្រង់ផ្សេងៗនៃវិសមភាព និងអំពើហិង្សានៅកម្រិតមូលដ្ឋាន និងសកលលោក រួមជាមួយនឹងមូលហេតុ ផលប៉ះពាល់ និងកត្តាអាស្រ័យគ្នាទៅវិញទៅមកផ្សេងទៀត។ គ្រូបង្រៀនអាចណែនាំពួកគេអំពីបញ្ហាផ្សេងៗ រួមមាន ភាពក្រីក្រ ការរើសអើង ការជិះជាន់ អសមភាពយេនឌ័រ ជម្លោះជនជាតិ/សាសនា វិបត្តិជនភៀសខ្លួន ការធ្វើចំណាកស្រុក ជម្លោះប្រដាប់អាវុធ ការរិចរិលបរិស្ថាន ការបដិសេធឬការរំលោភសិទ្ធិពលរដ្ឋ និងនយោបាយ។ ការបង្រៀនបញ្ហាទាំងនេះអាចលើកទឹកចិត្តអ្នកសិក្សាឱ្យគិតអំពីបញ្ហាក្នុងជីវិតពិតនៅក្នុងបរិបទរបស់គេ។ អ្នកសិក្សាគួរត្រូវបានណែនាំឱ្យទទួលស្គាល់ភាពជាប់ទាក់ទងគ្នានៃបញ្ហា យល់ដឹងពីផលប៉ះពាល់ និងមូលហេតុដែលនៅពីក្រោយពួកគេ និងឱ្យតម្លៃលើសារៈសំខាន់នៃសន្តិភាព។

### ការគោរពចំពោះនាពចម្រុះ

អ្នកសិក្សាទទួលបានការយល់ដឹងអំពីទម្រង់ផ្សេងៗនៃវិសមភាព និងអំពើហឹង្សានៅកម្រិតមូលដ្ឋាន និងសកលលោក រួមជាមួយនឹងបុព្វហេតុ ផលប៉ះពាល់ និងកត្តាដែលអាស្រ័យគ្នាទៅវិញទៅមក។ គ្រូបង្រៀនអាចណែនាំពួកគេអំពីបញ្ហាផ្សេងៗរួមមាន ភាពក្រីក្រ ការរើសអើង ការគៀបសង្កត់ វិសមភាពយេនឌ័រ ជម្លោះជនជាតិ/សាសនា វិបត្តិជនភៀសខ្លួន ការធ្វើចំណាកស្រុក ជម្លោះប្រដាប់អាវុធ ការរិចរិលបរិស្ថាន ការបដិសេធ/ការរំលោភសិទ្ធិពលរដ្ឋ និងនយោបាយ។ ការបង្រៀនបញ្ហាទាំងនេះអាចលើកទឹកចិត្តអ្នកសិក្សាឱ្យគិតអំពីបញ្ហាក្នុងជីវិតពិតនៅក្នុងបរិបទរបស់ពួកគេ។ អ្នកសិក្សាគួរត្រូវបានណែនាំឱ្យទទួលស្គាល់ភាពជាប់ទាក់ទងគ្នានៃបញ្ហា យល់ដឹងពីផលប៉ះពាល់ និងមូលហេតុដែលនៅពីក្រោយពួកគេ និងឱ្យតម្លៃលើសារៈសំខាន់នៃសន្តិភាព។

### សកលភាវូបនីយកម្ម និងយុត្តិធម៌សង្គម

អ្នកសិក្សាស្វែងយល់ពីទិដ្ឋភាពជាច្រើននៃ 'សកលភាវូបនីយកម្ម' រួមទាំងការបង្កើនការពឹងពាក់គ្នាទៅវិញទៅមកក្នុងចំណោមប្រទេស ប្រជាជននិងបញ្ហាអេកូឡូស៊ី ការកើនឡើងយ៉ាងឆាប់រហ័សនៃការផ្លាស់ប្តូរសង្គម វប្បធម៌និងបច្ចេកវិទ្យាឆ្លងដែន ការរីករាលដាលទូទាំងពិភពលោកនៃបទដ្ឋាននិងតម្លៃក្នុងស្រុក។ ពួកគេក៏ទទួលបានផងដែរនូវការយល់ដឹងអំពីបញ្ហា និងមូលហេតុដែលនាំឱ្យមានការគំរាមកំហែងពិភពលោករបស់យើងនាពេលបច្ចុប្បន្ន និងផលប៉ះពាល់របស់វាទៅលើសង្គម និងសហគមន៍មូលដ្ឋាន។ ការឆ្លើយតបផ្សេងៗទៅនឹងសកលភាវូបនីយកម្មក៏គួរតែសិក្សាផងដែរ ដោយរួមបញ្ចូលទាំងពីសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

### និរន្តរភាព

ក្រោមប្រធានបទនៃនិរន្តរភាពឬចីរភាព អ្នកសិក្សាត្រូវបានណែនាំអំពីបញ្ហាប្រឈមសកលក្នុងផ្នែកសេដ្ឋកិច្ច បរិស្ថាន ធនធានធម្មជាតិ ជីវចម្រុះ ការប្រែប្រួលអាកាសធាតុ វប្បធម៌ និងនយោបាយ។ តាមរយៈការសិក្សាអំពីបញ្ហាទាំងនេះ អ្នកសិក្សាអាចយល់បានកាន់តែច្រើនអំពីគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងឆ្លុះបញ្ចាំងពីបញ្ហានៅក្នុងជីវិតពិត ដោយបំផុសគំនិតខ្លួនឯងឱ្យស្វែងរកដំណោះស្រាយសម្រាប់បញ្ហាសេដ្ឋកិច្ច នយោបាយ បរិស្ថាន សង្គម និងវប្បធម៌។

ជំពូកទី៣

GCED បង្រៀនពីអ្វី?

ខ្លឹមសារមេរៀន

## ខ្លឹមសារមេរៀន GCED

### អ្វីដែលត្រូវធ្វើ៖

1. ទាញយកឯកសារ "ការអប់រំពលរដ្ឋសកលៈ មេរៀន និងវត្ថុបំណងនៃមេរៀន (TLOs)"។
2. ប្រើប្រាស់ឧបករណ៍មើលឃើញដែលពាក់ព័ន្ធ (ឧ. ឯកសារបទបង្ហាញ វីដេអូ ទំព័រពីការបោះពុម្ពផ្សាយ) ដើម្បីជួយពន្យល់ពីគោលគំនិត។

### មេរៀនរបស់អង្គការយូណេស្កូ (TLOs) និងវត្ថុបំណងនៃមេរៀន

យើងបានរៀនរួចមកហើយអំពីអ្វីដែលហៅថា GCED ហេតុអ្វី និងតាមរបៀបណាដែលវាអាចក្លាយជារបៀបវារៈសកល ហើយតើវាមានសញ្ញាណខុសគ្នាបែបណាក្នុងបរិបទផ្សេងគ្នា។ ផ្អែកលើចំណេះដឹងរបស់អ្នកអំពីអ្វីជា GCED ហើយអ្វីជាគោលបំណងរបស់វានោះ នៅក្នុងមេរៀននេះនឹងណែនាំអំពីមេរៀន និងចំណុចដែលត្រូវបង្រៀន GCED ទៅដល់អ្នកសិក្សា។ បញ្ជីមេរៀន និងវត្ថុបំណងមេរៀនដែលសមស្របទៅអាយុរបស់អ្នកសិក្សាត្រូវបានផ្ដល់ជូនដើម្បីជួយអ្នកអភិវឌ្ឍមេរៀនស្ដីពី GCED និងអាចយកទៅបង្រៀននៅក្នុងថ្នាក់បាន។

ក្នុងគោលដៅនេះ 'ការអប់រំពលរដ្ឋសកលរបស់អង្គការយូណេស្កូ៖ មេរៀន និងវត្ថុបំណងនៃការរៀន (TLOs)' ត្រូវបានប្រើយកមកប្រើប្រាស់ជាឯកសារយោងក្នុងគោលដៅចង្អុលបង្ហាញដល់អ្នកអប់រំ អ្នកអភិវឌ្ឍន៍កម្មវិធីសិក្សា គ្រូឧទ្ទេស ក៏ដូចជាអ្នកធ្វើគោលនយោបាយផងដែរ។ TLOs មានគោលបំណងផ្ដល់នូវក្របខ័ណ្ឌសម្រាប់ GCED ក្នុងការកំណត់ការងារអប់រំ និងក្នុងការកំណត់បរិបទផ្សេងៗនៃការអប់រំ។ TLOs ត្រូវបានបង្កើតឡើងដើម្បីណែនាំអ្នកអប់រំដោយស្នើឡើងដូចខាងក្រោម៖

• មេរៀនធំៗចំនួនប្រាំបួន ផ្អែកលើគុណតម្លៃគន្លឹះបីសម្រាប់អ្នករៀនរួមមាន៖ - ចំណេះដឹង ចិត្តចលករសង្គម និងអាកប្បកិរិយា

• វត្ថុបំណងនៃការសិក្សាផ្អែកលើអាយុរបស់សិស្ស និងប្រធានបទសំខាន់ៗ

### កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

អ្នកអាចទាញយកឯកសារស្ដីពី "ការអប់រំភាពជាពលរដ្ឋសកល៖ ចំណងជើងមេរៀន និងវត្ថុបំណង (TLOs)" ពីតំណខាងក្រោម៖

https://www.gcedclearinghouse.org/resources/global-citizenship-education-topics-and-learning-objectives?language=en

សូមអាននិងផ្សាំខ្លួនឯងចំពោះឯកសារបោះពុម្ពផ្សេងៗមុនពេលអ្នករៀបចំនិងធ្វើការបណ្ដុះបណ្ដាលនៅក្នុងសិក្ខាសាលា

| ការអប់រំនាពជាពលរដ្ឋសកល | | |
|---|---|---|
| វិមាត្រនៃការរៀនសូត្រ | | |
| ចំណេះដឹង | ចិត្តចលករសង្គម | អកប្បកិរិយា |
| លទ្ធផលសិក្សារំពឹងទុកសំខាន់ៗ | | |
| • អ្នកសិក្សាទទួលបានចំណេះដឹង និងយល់ដឹងអំពីបញ្ហាមូលដ្ឋាន បញ្ហាជាតិ បញ្ហាអន្តរជាតិ ភាពជាប់ទាក់ទងគ្នា ភាពអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេស និងប្រជាជនមកពីតំបន់ផ្សេងៗគ្នា<br>• សិស្សអភិវឌ្ឍជំនាញសម្រាប់ការគិត និងការវិភាគ | • អ្នកសិក្សាទទួលបានបទពិសោធន៍និងមានអារម្មណ៍ថាខ្លួនជាកម្មសិទ្ធិរបស់មនុស្សទូទៅដែលត្រូវតែចែករំលែកគុណតម្លៃ និងទំនួលខុសត្រូវ ដោយផ្អែកលើសិទ្ធិមនុស្ស<br>• សិស្សបង្កើតអាកប្បកិរិយានៃការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ | • អ្នកសិក្សាធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវនៅកម្រិតមូលដ្ឋាន ថ្នាក់ជាតិ និងពិភពលោក ដើម្បីពិភពលោកកាន់តែមានសន្តិភាព និងនិរន្តរភាព<br>• សិស្សបង្កើនការលើកទឹកចិត្ត និងមានឆន្ទៈក្នុងការធ្វើសកម្មភាពចាំបាច់ |

## គុណសម្បត្តិសំខាន់ៗរបស់អ្នកសិក្សា

### ចំណេះដឹងជ្រៅជ្រះ

• ដឹងបញ្ហាក្នុងស្រុក បញ្ហាប្រទេសជាតិ បញ្ហាសកល ប្រព័ន្ធអភិបាលកិច្ច និងរចនាសម្ព័ន្ធ
• យល់ដឹងពីភាពអាស្រ័យគ្នាទៅវិញទៅមក និងការតភ្ជាប់គ្នានៃកង្វល់សកល និងតំបន់
• អភិវឌ្ឍជំនាញសម្រាប់ការរុករក និងការវិភាគ

### ទំនាក់ទំនងសង្គមនិងគោលគំនិតរួម

• ដឹងបញ្ហាក្នុងស្រុក បញ្ហាប្រទេសជាតិ បញ្ហាសកល ប្រព័ន្ធអភិបាលកិច្ច និងរចនាសម្ព័ន្ធ
• យល់ដឹងពីភាពអាស្រ័យគ្នាទៅវិញទៅមក និងការតភ្ជាប់គ្នានៃកង្វល់សកល និងតំបន់
• អភិវឌ្ឍជំនាញសម្រាប់ការរុករក និងការវិភាគ

### មានទំនួលខុសត្រូវប្រកបដោយសីលធម៌ និងមានការចូលរួម

• បង្កើតជំនាញ គុណតម្លៃ ជំនឿ និងឥរិយាបទសមរម្យ
• បង្ហាញពីទំនួលខុសត្រូវសម្រាប់ខ្លួនឯងផ្ទាល់ សម្រាប់សង្គម និងពិភពលោកដែលមានសន្តិភាពនិងនិរន្តរភាព
• បង្កើនការលើកទឹកចិត្ត និងឆន្ទៈក្នុងការថែរក្សាប្រយោជន៍រួម

## មេរៀន

1. ប្រព័ន្ធ និងរចនាសម្ព័ន្ធថ្នាក់ស្រុក ថ្នាក់ជាតិ និងសកលលោក
2. បញ្ហាដែលប៉ះពាល់ដល់អន្តរកម្ម និងការតភ្ជាប់នៃសហគមន៍នៅកម្រិតមូលដ្ឋាន កម្រិតថ្នាក់ជាតិ និងពិភពលោក
3. ការសន្មត់មូលដ្ឋាន និង

4. កម្រិតផ្សេងគ្នានៃអត្តសញ្ញាណ
5. មនុស្សក្នុងសហគមន៍ផ្សេងគ្នានិងរបៀបដែលពួកគេទំនាក់ទំនងគ្នា។
6. ភាពខុសគ្នា និងការគោរពភាពផ្សេងគ្នា

7. សកម្មភាពដែលអាចធ្វើជាបុគ្គល និងធ្វើជាក្រុម
8. អាកប្បកិរិយាប្រកបដោយក្រមសីលធម៌
9. ការចូលរួម និងការធ្វើសកម្មភាព




*ប្រភព៖ http://unesdoc.unesco.org/images/0023/002329/232993e.pdf*

## ជំពូកទី៣

## GCED បង្រៀនពីអ្វី?

## ខ្លឹមសារមេរៀន

### វិមាត្ររបស់ GCED

GCED ផ្អែកលើវិមាត្រនៃការរៀនចំនួនបី - គឺចំណេះដឹង ចិត្តចលករសង្គម និងអាកប្បកិរិយា។



## មេរៀននៃ GCED

យោងតាម វត្ថុបំណងនៃការរៀន (TLOs) មេរៀន GCED ចំនួនប្រាំបួនត្រូវបានស្នើឡើងផ្អែកលើគុណសម្បត្តិរបស់អ្នកសិក្សាដែលឆ្លើយតបទៅនឹងវិមាត្រនៃការរៀនចំនួនបី។ មេរៀនទាំងប្រាំបួននោះមានបីសម្រាប់គុណសម្បត្តិរបស់អ្នកសិក្សាម្នាក់ៗដែលត្រូវបានបង្ហាញខាងក្រោម៖

| | | |
|---|---|---|
| | **ចំណេះដឹង** | ✓ ប្រព័ន្ធមូលដ្ឋាន ប្រព័ន្ធថ្នាក់ជាតិ និងប្រព័ន្ធអន្តរជាតិ<br>✓ បញ្ហាដែលប៉ះពាល់ដល់អន្តរកម្មនិងការផ្សារភ្ជាប់សហគមន៍នៅមូលដ្ឋាន នៅកម្រិតថ្នាក់ជាតិ និងកម្រិតអន្តរជាតិ<br>✓ ការសន្មត់ជាមូលដ្ឋាន និងសក្តានុពលប្រកបដោយថាមពល |
| | **ចិត្តចលករសង្គម** | ✓ កម្រិតខុសៗគ្នានៃអត្តសញ្ញាណ<br>✓ កម្មសិទ្ធិរបស់មនុស្សក្នុងសហគមន៍ផ្សេងៗគ្នា និងវិធីដែលសហគមន៍នេះមានទំនាក់ទំនងគ្នា<br>✓ ការទទួលស្គាល់ភាពខុសគ្នា និងការគោរពភាពចម្រុះនៃវប្បធម៌ |
| | **អកប្បកិរិយា** | ✓ សកម្មភាពដែលអាចធ្វើជាបុគ្គល និងធ្វើជាសមូហភាព<br>✓ អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយក្រមសីលធម៌<br>✓ គៀរគរឱ្យចូលរួមនិងធ្វើសកម្មភាព |

TLOs (មេរៀននិងវត្ថុបំណងនៃការរៀន) បង្ហាញពីរបៀបណែនាំដែលអាចប្រើសម្រាប់អ្នករៀនដែលក្រុមអាយុផ្សេងៗគ្នា។ អ្នកអាចមើលឯកសារយោងទស្សនាវដ្តីបោះពុម្ព ឬឧបសម្ព័ន្ធ៣។

## កំណត់ចំណាំសម្រាប់គ្រូខ្មែរ

អ្នកអប់រំអាចឆ្លុះពីរបៀបដែលមេរៀន GCED ត្រូវបានយកទៅបង្រៀនដល់អ្នករៀនដែលមានក្រុមអាយុផ្សេងៗគ្នា។ តាមពិត មេរៀនទាំងនេះ ហាក់ដូចជាមានការលំបាកក្នុងការបង្រៀនដល់សិស្សវ័យក្មេង ពោលគឺ សិស្សមត្តេយ្យសិក្សា ឬសិស្សបឋមសិក្សា។ ដូច្នេះ ត្រូវជួយពួកគេដោះស្រាយកង្វល់នេះតាមរយៈការលើកទឹកចិត្តឱ្យអាន TLOs ដែលបោះពុម្ពដោយអង្គការយូណេស្កូសម្រាប់វត្ថុបំណងនៃការរៀនដ៏ជាក់លាក់ ក៏ដូចជាអានអត្ថបទដែលពាក់ព័ន្ធទៅនឹងក្រុមអាយុ ឬកម្រិតនៃការអប់រំផ្សេងៗគ្នា។ សូមមើលឧបសម្ព័ន្ធសម្រាប់ព័ត៌មានបន្ថែមអំពីវត្ថុបំណងនៃការសិក្សាដែលពាក់ព័ន្ធនឹងប្រធានបទនីមួយៗនៃប្រធានបទទាំងប្រាំបួន។

## ការឆ្លុះបញ្ចាំងនិងការសង្ខេប

| | |
|---|---|
| រយៈពេល | ២០នាទី |
| វត្ថុបំណងនៃមេរៀន | · អនុញ្ញាតឱ្យសិក្ខាកាមរំលឹកឡើងវិញនូវការយល់ដឹងរបស់ពួកគេស្ដីអំពី GCED ពីមុនរហូតមកដល់ពេលនេះ<br>· កំណត់បញ្ហាប្រឈម និងយុទ្ធសាស្ត្រក្នុងការផ្ដល់ GCED នៅក្នុងបរិបទរបស់ពួកគេ។ |

**សកម្មភាព៖** ផ្លាស់ប្ដូរក្ដីស្រមៃរបស់អ្នកសម្រាប់ការអប់រំ GCED

**អ្វីដែលត្រូវធ្វើ៖**

1. រៀបចំសន្លឹកក្រដាសធំមួយ (ឬ flipchart) ដែលមានរូបភាពរង្វង់ពហុស្រទាប់ដូចខាងក្រោម ហើយបិទវានៅលើជញ្ជាំងដើម្បីឱ្យអ្នកគ្រប់គ្នាអាចមើលឃើញ។




2. ឱ្យសិក្ខាកាមឆ្លុះបញ្ចាំងអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀននេះពីរបីនាទី ហើយរាយចំណុចសំខាន់ៗពីមេរៀនដោយសរសេរវានៅលើសន្លឹកផុសអ៊ីត រួចបិទវានៅលើក្រដាស (ស្រទាប់ទី 1) ហើយឱ្យសិក្ខាកាមអានចំណុចផ្សេងដោយសង្ខេប។
3. បន្ទាប់មក ឱ្យពួកគេពិនិត្យមើលរបៀបបង្រៀនផ្ទាល់ខ្លួន (ឬបរិបទអប់រំផ្សេងទៀតដែលពួកគេមាន) និងកំណត់បញ្ហាឬចំណុចប្រឈមសម្រាប់ធ្វើការផ្លាស់ប្ដូរ ដើម្បីបង្រៀន GCED ។ សរសេរវានៅលើក្រដាស់ផុសអ៊ីត ហើយបិទវានៅលើក្រដាស (ស្រទាប់ទី 2)។

4. ចុងក្រោយ ឱ្យសិក្ខាកាមកំណត់យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ ឬអ្នកដទៃ ហើយសរសេរវានៅលើក្រដាសផុសអ៊ីតដែលនឹងត្រូវបិតនៅលើក្រដាស (ស្រទាប់ទី 3)។
5. ឱ្យសិក្ខាកាមដើរមើលចម្លើយអ្នកដទៃហើយឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលសិក្ខាកាមម្នាក់ៗស្រមៃឃើញសម្រាប់ការបង្រៀនរបស់គាត់ទៅលើមេរៀន GCED ។
6. ហៅអ្នកដែលចង់ចែករំលែកពីការឆ្លុះបញ្ចាំងរបស់ពួកគេជាមួយអ្នកដទៃ។

## កំណាត់ចំណាំរបស់គ្រូខ្ទេស

សកម្មភាពនេះមានគោលបំណងឱ្យសិក្ខាកាមឆ្លុះបញ្ចាំងពីមេរៀន និងធ្វើបរិបទនីកម្មទៅលើវា។ ប្រសិនបើអាចធ្វើបាន សូមផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សិក្ខាកាមគិត ធ្វើដូច្នេះពួកគេអាចភ្ជាប់មេរៀននៃវគ្គនេះជាមួយនឹងបរិបទនៃការបង្រៀនរបស់ពួកគេផ្ទាល់។ ការចែករំលែកការយល់ដឹង និងគំនិតតាមរយៈការកត់ត្រាជាលាយលក្ខណ៍អក្សរអាចជួយសម្រួលដល់ការចូលរួមជាក្រុមកាន់តែស្មើភាព និងទូលំទូលាយ ជាពិសេសសម្រាប់អ្នកដែលអាចមានអារម្មណ៍ស្រួលក្នុងការបញ្ចេញគំនិតរបស់ពួកគេតាមរយៈវិធីសាស្ត្រនេះ។ ក្នុងពេលជាមួយគ្នានេះ ការបិទស្ទិកឃ័រនៅលើក្រដាសផ្ទាំងធំ អាចអនុញ្ញាតឱ្យមានការចូលរួមរៀនយ៉ាងមានប្រសិទ្ធភាពអំពីគំនិតរបស់អ្នកដទៃ។ សិក្ខាកាមក៏អាចទទួលបានគំនិត និងការយល់ដឹងពីកំណត់ត្រានេះ ដែលនាំឱ្យពួកគេអាចពង្រឹងការយល់ដឹងកាន់តែស៊ីជម្រៅ និងទូលំទូលាយអំពីប្រធានបទ។ អ្នកសម្របសម្រួលអាចជ្រើសរើសកំណត់ត្រាមួយចំនួនដើម្បីរំលេច និងចែករំលែកដោយសង្ខេបដោយមិនបង្ហាញឱ្យឃើញថាតើនរណាជាអ្នកសរសេរវា។ ការធ្វើដូច្នេះ អាចជាច្រកដ៏មានប្រសិទ្ធភាពសម្រាប់កិច្ចពិភាក្សា។

# ជំពូកទី៤៖

# របៀបបង្រៀន ភាពជាពលរដ្ឋសកល
(GCED)

## របៀបបង្រៀន គោពជាពលរដ្ឋសកល (GCED)

| | |
|---|---|
| **ទិដ្ឋភាពរួម** | ជំពូកនេះពិភាក្សាអំពីគរុកោសល្យ និងយុទ្ធសាស្ត្រក្នុងការបង្រៀន GCED។ ផ្អែកលើការសិក្សាទ្រឹស្តីនៃការប្រែប្រួល (បរិវត្តកម្ម) និងគោលការណ៍គ្រឹះផ្អែកគរុកោសល្យនៃ GCED មានការបង្ហាញពីវិធីផ្សេងគ្នានៃការបង្រៀន និងការលើកឡើងពីសារសំខាន់នៃ GCED។ វិធីសាស្ត្រមួយចំនួនដែលបានបង្ហាញនៅទីនេះ រួមមានការណែនាំអំពីរបៀបអនុវត្តGCEDនៅក្នុងស្ថានភាពនៃការរៀនសូត្រផ្សេងៗ។ |
| **មេរៀន** | 1. ការបង្រៀន GCED ដើម្បីផ្លាស់ប្តូរ៖ គោលការណ៍គរុកោសល្យនៃ GCED<br>2. របៀបបង្រៀន GCED ប្រកបដោយប្រសិទ្ធភាព៖ យុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការបង្រៀន |
| **លទ្ធផលសិក្សា** | 1. ស្វែងយល់ពីគោលការណ៍គរុកោសល្យទាំងប្រាំមួយរបស់ GCED<br>2. កំណត់យុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការបង្រៀន |
| **លំដាប់លំដោយនៃមេរៀន** | 1. ចាប់ផ្តើមថ្នាក់ (20 នាទី)<br>✓ [សកម្មភាព] ពិនិត្យមើល GCED ក្នុងការធ្វើសកម្មភាព!<br>2. ខ្លឹមសារនៃការសិក្សា (80 នាទី)<br>✓ គោលការណ៍គរុកោសល្យនៃ GCED<br>✓ យុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការបង្រៀន<br>3. ការឆ្លុះបញ្ចាំង/សង្ខេប (20 នាទី)<br>✓ [សកម្មភាព] ការចែករំលែកការគិត និងគំនិត |
| **ឯកសារយោង** | APCEIU. Global Citizenship Education: A Guide for Policymakers. 2017. |

## ការចាប់ផ្តើមថ្នាក់

| | |
|---|---|
| **រយៈពេល** | ២០នាទី |
| **វត្ថុបំណង** | បំផុសគំនិតលើផ្នែកគរុកោសល្យ និងវិធីសាស្ត្របង្រៀន GCED |

**សកម្មភាព៖ Watch GCED in Action!**

**១. ការចាក់វីដេអូអំពីសិក្ខាសាលាបណ្តុះបណ្តាល ឬការបង្ហាញរូបភាពដែលបានថតទុកក្នុងអំឡុងពេលសិក្ខាសាលារបស់ APCEIU ស្តីពី GCED។**

| **គំរូ** | | |
|---|---|---|
| **វីដេអូ** | 15th Asia-Pacific Training Workshop on EIU | https://www.youtube.com/watch?v=Vq6Buvphsyk |
| | 16th Asia-Pacific Training Workshop on EIU | https://www.youtube.com/watch?v=u_t1vun67Ks |
| | 17th Asia-Pacific Training Workshop on EIU | https://www.youtube.com/watch?v=BddqpN4vZ00 |
| **រូបភាព** |    | |

នៅក្នុងរូបភាពខាងលើ សិក្ខាកាមមានចំណាប់អារម្មណ៍ទៅលើវិធីសាស្រ្តផ្សេងៗដែលគ្រូបង្រៀន និងអ្នកសម្របសម្រួល ដឹកនាំនិងគ្រប់គ្រងដំណើរការសិក្ខាសាលា។

## ក. តើអ្នកសម្របសម្រួល និងសិក្ខាកាមកំពុងធ្វើអ្វីនៅក្នុងវីដេអូឃ្លីប?

សិល្បៈ, ការសម្តែងជាតួ ...។ល។

art-making, role-playing, etc.

ប្រើប្រាស់ឧបករណ៍មើលស្តាប់ ដូចជា វីដេអូ, រូបថត, និងតន្ត្រី

having group discussions, brainstorming, thought-sharing, debates, etc.

ចម្លើយគំរូ

ការពិភាក្សាក្រុម, ការបង្កើតគំនិត, ការចែករំលែកគំនិត, ការជជែកដេញដោលគ្នា...។ល។

using audiovisual tools such as videos, photos, and music

ដឹកនាំបទពិសោធន៍ផ្ទាល់ ដូចជា ការធ្វើដំណើរទៅទីប្រជុំជន, ការធ្វើអន្តរកម្មដោយផ្ទាល់ជាមួយអ្នកស្រុក។ល។

Conducting hands-on experiences such as field trips, firsthand interactions with the locals,

## ខ. ការគិតអំពីតួនាទីរបស់គ្រូ/អ្នកសម្របសម្រួល និងអ្នកសិក្សា

តើយុទ្ធសាស្រ្ត និងវិធីសាស្រ្តបង្រៀនបែបណាត្រូវបានអនុវត្តក្នុងវីដេអូ? អ្នកអាចប្រើតារាងខាងក្រោមដើម្បីណែនាំការពិភាក្សាក្នុងចំណោមអ្នកចូលរួម។

| តួនាទី និងយុទ្ធសាស្រ្តដែលត្រូវបានប្រើ៖ | | |
|---|---|---|
| **គ្រូ/អ្នកសម្របសម្រួល** | **អ្នកសិក្សា** | **វិធីសាស្រ្ត និងយុទ្ធសាស្រ្ត** |
| | | |
| ឧ. | ឧ.<br>- ការចូលរួមយ៉ាងយកចិត្តទុកដាក់ជាមួយសិស្ស និង | ឧ.<br>- ការប្រើប្រាស់ឧបករណ៍ច្នៃប្រឌិត និងវិធីសាស្រ្តផ្សេង |

| | | |
|---|---|---|
| - ការដើរជុំវិញ ការសម្រប សម្រួល/ណែនាំអ្នកចូលរួម ពេញមួយសកម្មភាព។<br>- ការស្តាប់សិស្សដោយយក ចិត្តទុកដាក់ ដោយប្រើ ប្រាស់ទំនាក់ទំនងភ្នែក,<br>- ការសម្របសម្រួល សកម្មភាពជាមួយសិស្ស (ការសម្របសម្រួលរួមគ្នា)<br>- ការធ្វើការរួមគ្នាជាមួយ សិស្ស | អ្នកបង្ហាត់បង្រៀន/អ្នក សម្របសម្រួល។<br>- ការចូលរួមយ៉ាងសកម្ម និង បញ្ចេញមតិយោបល់របស់ ពួកគេដោយសេរី<br>- ការធ្វើការជាក្រុម ដោយ សហការគ្នាទៅវិញទៅមក<br>- ការជំរុញពួកគេអោយយក ចិត្តទុកដាក់ក្នុងការសិក្សា | ។ដូចជាការរាំ ហ្គេម និងការ បំផុសគំនិត<br>- ការប្រើប្រាស់កន្លែងដែល មានសុវត្ថិភាព ការចូលរួម និងបើកចំហសម្រាប់ការ ចែករំលែកគំនិត<br>- ការប្រើសេណារីយ៉ូ និង ស្ថានភាពជីវិតពិត<br>- ការចូលរួមក្នុងការសន្ទនា ជាមួយសិស្ស |

| | |
|---|---|
| **រយៈពេល** | ៣០នាទី |
| **វត្ថុបំណង** | - ទទួលបានការយល់ដឹងអំពីគោលការណ៍គរុកោសល្យរបស់ GCED។<br>- ណែនាំពីតួនាទីរបស់គ្រូបង្រៀនក្នុងការជំរុញបរិយាកាសប្រកបដោយសហ ប្រតិបត្តិការ, សន្តិភាព, និងប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន។<br>- ស្វែងយល់ពីវិធីទំនាក់ទំនង និងការពិភាក្សាដែលជួយបណ្តុះវប្បធម៌សន្តិភាព។ |

## គោលការណ៍គរុកោសល្យនៃភាពជាពលរដ្ឋសកល GCED

### អ្វីដែលត្រូវធ្វើ៖

**ប្រើឧបករណ៍ជំនួយដែលអាចមើលឃើញ (ឧ. ស្លាយ PowerPoint វីដេអូ រូបភាព និងដ្យាក្រាម) ដើម្បីជួយពន្យល់ពីគោលគំនិតដល់អ្នកសិក្សា។**

ការសម្រេចបាននូវគោលដៅរបស់ GCED តម្រូវឱ្យមានការប្រើប្រាស់វិធីសាស្រ្តផ្លាស់ប្តូរប្រែប្រួលបត់បែន និងវិធីសាស្ត្ររួម (a transformative and holistic approach) ក្នុងការបង្រៀន។ GCED ផ្តល់ឱ្យអ្នកសិក្សានូវអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ ដើម្បីបង្កើតអនាគតប្រកបដោយសន្តិភាព យុត្តិធម៌ និងនិរន្តរភាពសម្រាប់ទាំងអស់គ្នា។ ដើម្បីសម្រេចបានចំណុចនេះ បំណិនក្នុងការគិតត្រិះរិះពិចារណា ការសម្រេចចិត្ត និងការទទួលខុសត្រូវ ក៏គួរត្រូវបានយកមកបង្រៀនផងដែរ។ ដូច្នេះការ

បង្រៀន GCED ទាមទារឱ្យមានគរុកោសល្យ និងការផ្លាស់ប្តូរប្រែប្រួលនិងបត់បែន ដែលមិនត្រឹមតែពង្រីកចំណេះដឹងរបស់សិស្សអំពីកិច្ចការសកល និងបញ្ហាប្រឈមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអភិវឌ្ឍជំនាញ និងគុណតម្លៃដែលចាំបាច់ដើម្បីធ្វើឱ្យពិភពលោកក្លាយជាកន្លែងប្រសើរជាងមុន។ GCED មានគោលការណ៍គរុកោសល្យចំនួនប្រាំមួយ ដែលរួមមានការប្រែប្រួលពីការបង្រៀនសាមញ្ញធម្មតាមួយទៅជាការបង្រៀនដែលមានភាពប្រែប្រួល បត់បែន និងផ្លាស់ប្តូរ។

## គោលការណ៍គរុកោសល្យទី១៖ ការសន្ទនា និងការចូលរួម

GCED អាចដំណើរការបានល្អបំផុត នៅក្នុងបរិយាកាសដែលផ្តោតលើសិស្ស (សិស្សមជ្ឈមណ្ឌល) ដោយសិស្សនិងគ្រូ អាចពិភាក្សាបញ្ហា និងរៀនអ្វីៗជាច្រើនទៀតជាមួយគ្នាបាន។ ទំនាក់ទំនងរវាងគ្រូ និងសិស្សនៅក្នុងថ្នាក់រៀនភាគច្រើន គឺផ្តោតលើគ្រូមជ្ឈមណ្ឌល ដោយគេយល់ឃើញថាគ្រូបង្រៀនជាប្រភពនៃចំណេះដឹង ជាអ្នកបញ្ជូនចំណេះដឹងរបស់ពួកគេទៅឱ្យអ្នកសិក្សា ហើយសិស្សជាធម្មតាមិនត្រូវបានផ្តល់ឱកាសច្រើនក្នុងការពិភាក្សា និងចែករំលែកនូវអ្វីដែលពួកគេបានរៀននោះទេ។ ដើម្បីក្លាយជាពលរដ្ឋសកម្ម អ្នកសិក្សាមិនគួរនៅអសកម្មទៀតទេ (ឬគ្រាន់តែស្រូបយកចំណេះដឹងពីគ្រូប៉ុណ្ណោះទេ) ប៉ុន្តែត្រូវជំនួសមកវិញគឺជាអ្នកចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សា។ ដើម្បីសម្រេចបាននូវចំណុចនេះ គ្រូបង្រៀនគួរចូលរួមសន្ទនាជាមួយអ្នកសិក្សា និងលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងការសន្ទនាជាមួយគ្នាទៅវិញទៅមក។ ការសន្ទនាជំរុញឱ្យសិស្សចែករំលែកគំនិតរបស់ពួកគេ លើកសំណួរ ស្តាប់គ្នាទៅវិញទៅមក និងឆ្លុះបញ្ចាំងពីទស្សនៈថ្មីៗជាច្រើនដែលពួកគេបានរៀន។ ការលើកទឹកចិត្តសិស្សឱ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សា និងការសន្ទនាជាមួយគ្រូនិងសិស្ស ធ្វើឱ្យពួកគេទទួលបានឱកាសច្រើនក្នុងការធ្វើសកម្មភាពលើបញ្ហាជាច្រើនដែលពួកគេរៀននៅក្នុងថ្នាក់រៀន។

## កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

មេរៀននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងឱ្យសិក្ខាកាមបំផុសគំនិតជាមុនអំពីគរុកោសល្យ និងវិធីសាស្ត្រនៃការបង្រៀនផ្សេងៗគ្នា ចំពោះ GCED។ វាក៏ជាគំនិតល្អផងដែរក្នុងការភ្ជាប់មេរៀននេះជាមួយនឹងមេរៀនមុនៗលើខ្លឹមសារសិក្សា GCED ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃ "របៀប" នៅពេលបង្រៀន GCED ដល់អ្នកសិក្សា។

| | |
|---|---|
| **គ្រូមជ្ឈមណ្ឌល** គ្រូបង្រៀនគឺជាអ្នកជំនាញ ហើយ**សិស្សគឺជាអ្នករៀនអសកម្ម** | **សិស្សមជ្ឈមណ្ឌល** គ្រូបង្រៀន និងសិស្ស គឺជាដៃគូ៖ ជាអ្នកបង្កើតរួមគ្នា និងជាអ្នករៀនរួមគ្នា |




## គោលការណ៍គរុកោសល្យទី២៖ មុខវិជ្ជារួម និងអន្តរមុខវិជ្ជា

ការអប់រំគួរតែត្រូវបានរៀបចំឡើងឱ្យពាក់ព័ន្ធទៅនឹងជីវិតប្រចាំថ្ងៃរបស់អ្នកសិក្សា ដោយប្រើសេណារីយ៉ូ និងបញ្ហាក្នុងជីវិតពិត ជាឧទាហរណ៍នៅពេលបង្រៀនប្រធានបទជាក់លាក់។ អ្នកសិក្សាត្រូវដឹងអំពីរូបភាពធំ (ពោលគឺគោលគំនិតសំខាន់) ដែលមនុស្ស និងបរិស្ថានមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ដូច្នេះ GCED ទាមទារការរៀនសូត្រ ឬសិក្សាបញ្ហាពីជ្រុងផ្សេងៗគ្នាជាច្រើន (អន្តរកម្មសិក្សា) ដោយប្រើវិធីផ្សេងៗនៃការរៀន។ ជារួម វិធីដ៏ល្អមួយដើម្បីរៀន គឺតាមរយៈការចូលរួមរបស់សហគមន៍ឱ្យកាន់តែមានភាពទូលំទូលាយ – ការរៀនពីបញ្ហា និងប្រធានបទផ្សេងៗដែលហួសពីខ្លឹមសារគ្របដណ្ដប់នៅក្នុងថ្នាក់រៀន។ តាមរយៈការអញ្ជើញអ្នកសិក្សាឱ្យធ្វើអន្តរកម្ម និងពិភាក្សាជាមួយមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗគ្នានៅក្នុងសហគមន៍មូលដ្ឋាន ពួកគេត្រូវបានលើកទឹកចិត្តឱ្យស្វែងយល់ យល់ និងគោរពទស្សនៈចម្រុះ។ គ្រូដែលដើរតួនាទីជាអ្នកសម្របសម្រួល អាចបង្កើតវិធីផ្សេងៗឱ្យអ្នកសិក្សាយល់ពីរបៀបខុសគ្នានៃបញ្ហា ភាពទាក់ទងគ្នាទៅវិញទៅមកនៃរឿងរ៉ាវផ្សេងៗ និងពង្រីកទស្សនៈរបស់ពួកគេក្នុងការយល់ដឹងអំពីពិភពលោកដែលពួកគេរស់នៅ។




## គោលការណ៍គរុកោសល្យទី៣៖ ពហុម៉ូឌុល

គ្រូគួរចូលរួមជាមួយសិស្ស - ទាំងចិត្ត បេះដូង និងរាងកាយ - ដូច្នេះវាជាការសំខាន់ណាស់ក្នុងការប្រើយុទ្ធសាស្ត្រសិក្សាផ្សេងៗគ្នាដែលពាក់ព័ន្ធនឹងអារម្មណ៍ ដូចជា ការមើលឃើញ (sight) សំឡេង (sound) ក្លិន (smell) រសជាតិ (taste) និងការប៉ះ (touch) នៅពេលបង្រៀន។ ទម្រង់នៃការរៀនប្រកបដោយភាពច្នៃប្រឌិតទាំងនេះរួមមាន ការជជែកដេញដោល ល្ខោន ការក្លែងធ្វើ សិល្បៈ ការសម្តែងតួ និងការនិទានរឿង។ បច្ចេកទេសទាំងនេះ ជំរុញឱ្យសិស្សយល់ដឹងនូវអ្វីដែលពួកគេបានរៀន តាមរយៈការចូលរួមនៅក្នុងកម្រិតសិក្សាជាច្រើន - ការយល់ដឹង សង្គម - អារម្មណ៍ និងអាកប្បកិរិយា។



## គោលការណ៍គរុកោសល្យទី៤៖ ការបង្កើតតម្លៃ

គ្រូបង្រៀនមិនត្រឹមតែផ្តោតលើការបង្រៀនការពិត ចំណេះដឹង និងព័ត៌មានថ្មីៗដល់អ្នកសិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយពួកគេឱ្យអភិវឌ្ឍតម្លៃដូចជា ការយល់ចិត្ត យុត្តិធម៌ ការអាណិតអាសូរ ការគោរព និងការអហិង្សា។ ក្នុងនាមជាអ្នកសម្របសម្រួល គ្រូបង្រៀនក៏គួរតែអាចបង្រៀនសិស្សពីរបៀបពិនិត្យមើលតម្លៃ និងគោលការណ៍របស់ពួកគេ របៀបវាយតម្លៃការរំពឹងទុក និងសកម្មភាពរបស់ពួកគេ និងរបៀបបង្កើតគុណតម្លៃ និងទម្លាប់ល្អ។ អ្នកសិក្សាអាចប្រើប្រាស់ចំណេះដឹងដែលពួកគេបានរៀននៅក្នុងថ្នាក់សម្រាប់ជាប្រយោជន៍រួមតែប៉ុណ្ណោះ ប្រសិនបើពួកគេមានតម្លៃ អាកប្បកិរិយា និងផ្នត់គំនិតត្រឹមត្រូវដូចដែលបានផ្សព្វផ្សាយដោយ GCED។

**From**

**Knowledge and information only**



**To**

**Internalizing fundamental values such as justice, respect, and human dignity by learning about issues**



## គោលការណ៍អប់រំទី៥៖ សារៈសំខាន់នៃការពង្រឹងអំណាច/ឥទ្ធិពល

អ្នកសិក្សាមិនគួរគ្រាន់តែដឹងអំពីពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែក៏អាចឆ្លើយតបបានប្រកបដោយការត្រិះរិះពិចារណាចំពោះបញ្ហាប្រឈមក្នុងតំបន់ និងពិភពលោកតាមរយៈការធ្វើសកម្មភាពផងដែរ។ កាលណាពួកគេចូលរួមកាន់តែច្រើននៅក្នុងចលនា និងការខិតខំប្រឹងប្រែងដែលស្វែងរកការដោះស្រាយបញ្ហាដូចជាការប្រែប្រួលអាកាសធាតុ និងការជួញដូរមនុស្ស ពួកគេកាន់តែយល់ដឹងអំពីមូលហេតុដូចជាវិសមភាព និងអយុត្តិធម៌។ ចំណេះដឹងបន្ថែមអំពីបញ្ហាទាំងនេះគួរតែជំរុញអ្នកសិក្សាឱ្យក្លាយជាភ្នាក់ងារនៃការ

ផ្លាស់ប្ដូរជាវិជ្ជមាន ដោយប្រើប្រាស់ចំណេះដឹង ជំនាញ និងតម្លៃរបស់ពួកគេ ដើម្បីដើរតួនាទីយ៉ាងសកម្ម ក្នុងការផ្លាស់ប្ដូរសហគមន៍មូលដ្ឋាន និងពិភពលោករបស់ពួកគេ។

| From | To |
| --- | --- |
| ផ្ដោតលើការរៀនសូត្រ អំពីការពិត/ចំណេះដឹង (ការយល់ដឹង)<br>Focusing on learning about facts/knowledge (Cognitive) | ទទួលខុសត្រូវ និងធ្វើសកម្មភាពដើម្បីនាំមកនូវការផ្លាស់ប្ដូរ (ការយល់ដឹង សង្គម-អារម្មណ៍ និងអាកប្បកិរិយា)<br>Taking responsibility and action to bring about change (Cognitive, Socio-emotional, and Behavioral) |

## គោលការណ៍គរុកោសល្យទី៦៖
## អាចអនុវត្តបាន និងមានភាពពាក់ព័ន្ធគ្នា (ទាំងក្នុងស្រុក និងជាសកល)

GCED លើកកម្ពស់ការរៀនសូត្រដែលបណ្ដុះមនសិការកាន់តែច្រើនអំពីបញ្ហាជីវិតពិត។ វាផ្ដល់ឱ្យសិស្សនូវគំនិតដែលពាក់ព័ន្ធ និងវិធីដែលអាចអនុវត្តបាន ក្នុងការយល់ដឹងពីផលប៉ះពាល់នៅកម្រិតមូលដ្ឋានដែលអាចមានឥទ្ធិពលដល់កម្រិតសកល។ដើម្បីឱ្យអ្នកសិក្សាក្លាយជាភ្នាក់ងារនៃការផ្លាស់ប្ដូរប្រកបដោយប្រសិទ្ធភាពនាពេលអនាគត ខ្លឹមសារនៃការសិក្សាគួរតែផ្អែកលើបញ្ហាជីវិតពិត និងបទពិសោធន៍ផ្ទាល់។ ចំណេះដឹងពាក់ព័ន្ធ និងជំនាញអនុវត្តជាក់ស្ដែង ផ្ដល់ឱ្យអ្នកសិក្សាអនុវត្តនូវអ្វីដែលពួកគេបានរៀនក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

| From | To |
| --- | --- |
| **Textbook-based facts and information only** | **Including real-life issues, community-based learning, PBL (Project-based learning), etc.** |





## វិធីសាស្ត្រ និងយុទ្ធសាស្ត្រនៃការបង្រៀន

### អ្វីដែលត្រូវធ្វើ៖

**ប្រើជំនួយដែលអាចមើលឃើញ (ឧ. ស្លាយ PowerPoint វីដេអូ ឬរូបភាព) ដើម្បីជួយពន្យល់ពីគោលគំនិតដល់អ្នកចូលរួម។ ត្រូវបញ្ចូលរូបភាព និងដ្យាក្រាមក្នុងការពន្យល់អំពីយុទ្ធសាស្ត្រ។**

នៅក្នុងមេរៀនមុន យើងបានរៀនអំពីគោលការណ៍គរុកោសល្យរបស់ GCED។ គោលការណ៍ទាំងនេះបានណែនាំដល់អ្នកអប់រំក្នុងការអនុវត្តការបង្រៀន GCED ដើម្បីបំពេញបាននូវគោលដៅជាមូលដ្ឋាននៃ GCED ដែលជាគំនិតផ្តួចផ្តើមនៃការអប់រំផ្លាស់ប្តូរ។ គ្រូបង្រៀនអាចយោងទៅលើគោលការណ៍ទាំងនេះនៅពេលរៀបចំមេរៀន ហើយអនុវត្តវានៅក្នុងការបង្រៀនជាក់ស្តែង។

នៅក្នុងមេរៀននេះ យើងនឹងរៀនអំពីវិធីសាស្ត្រ និងយុទ្ធសាស្ត្រគរុកោសល្យដែលមានមូលដ្ឋានលើគោលការណ៍គរុកោសល្យរបស់ GCED។ វិធីសាស្ត្រ និងយុទ្ធសាស្ត្រទាំងនេះ ជំរុញដំណើរការសិក្សាដែលមានការចូលរួមកាន់តែច្រើនពីសិស្ស។ វិធីសាស្ត្រ និងយុទ្ធសាស្ត្រទាំងនេះ មានប្រយោជន៍មិនត្រឹមតែសម្រាប់ការបង្រៀនក្នុងថ្នាក់ប៉ុណ្ណោះទេ ថែមទាំងនៅក្នុងកន្លែងអប់រំផ្សេងទៀត ដូចជាសកម្មភាពក្រៅកម្មវិធីសិក្សាជាដើម។

វិធីសាស្ត្រដែលអ្នកនឹងរៀននៅក្នុងមេរៀននេះ គ្រាន់តែជាឧទាហរណ៍មួយចំនួននៃវិធីសាស្ត្រផ្សេងគ្នាជាច្រើនដែលមាននៅក្នុងដំណើរការនៃការសិក្សាប្រកបដោយការផ្លាស់ប្តូរ។ គ្រូអាចយោងទៅលើបញ្ជីវិធីសាស្ត្រក្នុងទំព័រក្រោយៗទៀត ហើយជ្រើសរើសវិធីដែលសមស្របបំផុតចំពោះការបង្រៀន ឬកែប្រែការបង្រៀនរបស់ពួកគេប្រសិនបើចាំបាច់។ វិធីសាស្ត្រទាំងនេះអាចត្រូវបានចាត់ទុកជាឯកសារយោងអំពីរបៀបបញ្ចូលតម្លៃ GCED ទៅក្នុងការបង្រៀន។

ដូចដែលបានរៀបរាប់ខាងលើ គ្រូបង្រៀនតែងតែផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើខ្លឹមសារនៃការសិក្សា ឬ 'អ្វីដែលត្រូវបង្រៀន ព្រមទាំងគិតពិចារណា និងធ្វើសកម្មភាពប្រកបដោយទំនួលខុសត្រូវ។ គ្រូបង្រៀនគួរចងចាំថាដំណើរការសិក្សារបស់សិស្សមានបីកម្រិត - ការយល់ដឹងសង្គម - អារម្មណ៍ និងអាកប្បកិរិយា - ហើយអ្នកសិក្សាម្នាក់ៗចាប់បានឬទទួលបាននូវព័ត៌មានថ្មីខុសៗគ្នា។ ជាឧទាហរណ៍ ខណៈពេលដែលអ្នកសិក្សាខ្លះរៀនយ៉ាងឆាប់រហ័សដោយការអានអត្ថបទ ឬមើលរូបភាព សិស្សផ្សេង

ទៀតរៀនបានល្អបំផុតនៅពេលពួកគេប្រើដៃ ឬរាងកាយទាំងមូលរបស់ពួកគេ។ និយាយឱ្យសាមញ្ញ វិធីសាស្ត្របង្រៀនអាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងបទពិសោធន៍សិក្សារបស់សិស្ស។

ដើម្បីឱ្យមានការផ្លាស់ប្តូរ វិធីសាស្ត្របង្រៀនគួរតែលើសពីការទន្ទេញចាំដដែលៗ និងការដោះស្រាយបញ្ហាសាមញ្ញ។ ផ្ទុយទៅវិញ ពួកគេគួរតែផ្តល់វេទិកា ឬកន្លែងសម្រាប់រៀន និងអនុវត្តពីរបៀបសហការជាមួយអ្នកដទៃ និងធ្វើសកម្មភាពដោយមានការសាមគ្គី សហការជាមួយមនុស្សនៅខាងក្រៅថ្នាក់។ អ្នកសិក្សាក៏គួរត្រូវបានបង្រៀនពីរបៀបដើម្បីឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេ ពិនិត្យមើលឡើងវិញនូវទស្សនៈរបស់ពួកគេ និងអនុវត្តគំនិតដែលបានរៀនថ្មីៗក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

**ការផ្លាស់ប្តូរគរុកោសល្យដែលត្រូវការជាចាំបាច់នៅក្នុងការបង្រៀន** GCED

| From | To |
|---|---|
| ការបង្រៀនដើម្បីណែនាំពីគោលការណ៍ផ្សេងៗ | ការបង្រៀនដើម្បីធ្វើការផ្លាស់ប្តូរ |
| អ្នកសិក្សាគឺជាអ្នកទទួលនូវចំណេះដឹង | អ្នកសិក្សាគឺទាំងពីរជាអ្នកទទួល និងជាអ្នបង្កើតនូវចំណេះដឹងបន្ថែម |
| គ្រូបង្រៀនគឺជាមនុស្សដែលមានអំណាចក្នុងការផ្តល់នូវចំណេះដឹងប៉ុណ្ណោះ | គ្រូបង្រៀនគឺទាំងពីរជាបុគ្គលដែលមានអំណាចក្នុងការផ្តល់នូវចំណេះដឹង និងជាអ្នកសហសិក្សា |
| មុខវិជ្ជាឯកទេសតែមួយគត់ | វិធីសាស្ត្រផ្សេងៗក្នុងការបង្រៀនអន្តរមុខវិជ្ជាដោយមានការសាកសួរ និងការស៊ើបសួរ |
| វិធីសាស្ត្រមធ្យមតែមួយគត់ | Multi-media/វិធីសាស្ត្រពហុសញ្ញាណ |
| វប្បធម៌នៃការប្រកួតប្រជែង និងភាពជាបុគ្គល | វប្បធម៌នៃការសហការ បំណិនត្រិះរិះពិចារណារួមគ្នា និងការធ្វើសេចក្តីសម្រេចចិត្តដោយបានជូនដំណឹងជាមុន |
| ឧបករណ៍ក្នុងការវាយតម្លៃដើម្បីវាស់ស្ទង់ការពិត | ឧបករណ៍វាយតម្លៃដើម្បីវាស់ស្ទង់នូវចំនួនអ្នកយល់ពីការពិត និងស្ថានភាពជីវិតជាក់ស្តែង |
| វិធីសាស្ត្រផ្អែកលើចំណេះដឹង | វិធីសាស្ត្រផ្អែកលើការយល់ដឹង និងការមិនយល់ដឹង |

## គ្រូបង្រៀនគឺជាអ្នកសម្របសម្រួល

ដើម្បីបង្រៀន GCED ដល់អ្នកសិក្សាប្រកបដោយប្រសិទ្ធភាព និងជំរុញតម្លៃស្នូលរបស់ GCED ចូលទៅក្នុងផ្នត់គំនិតពួកគេ គ្រូបង្រៀនក៏គួរមានឆន្ទៈក្នុងការធ្វើខ្លួនឱ្យក្លាយជាអ្នកសម្របសម្រួលផងដែរ។ អ្នកសម្របសម្រួល ជួយអមដំណើរ និងណែនាំអ្នកសិក្សាក្នុងការសាកសួរ និងដោះស្រាយបញ្ហា ជាជាងគ្រាន់តែបញ្ជូន ឬផ្តល់ព័ត៌មាន។ ក្នុងនាមជាអ្នកសម្របសម្រួល គ្រូបង្រៀនគួរតែរៀបចំមេរៀនមួយ (ឬគម្រោង) ដោយមានលំហាត់ដាក់តាមលំដាប់លំដោយ ហើយតាមរយៈនោះសិស្សអភិវឌ្ឍការយល់ដឹងរបស់ពួកគេជាបន្តបន្ទាប់លើប្រធានបទ ហើយទីបំផុតក្លាយជាអ្នកឯករាជ្យនៅក្នុងដំណើរការសិក្សា។ គ្រូបង្រៀនដែលជាអ្នកសម្របសម្រួល ត្រូវផ្តល់ឱ្យអ្នកសិក្សាមានសេរីភាពក្នុងការសាកសួរវិធីនៃការគិត និងការសន្មត់ពីកម្រិតនៃការយល់ដឹងពីសង្គម ដោយលើកទឹកចិត្តឱ្យពួកគេទទួលខុសត្រូវចំពោះដំណើរការសិក្សារបស់ពួកគេផ្ទាល់។ គ្រូបង្រៀនក៏ដើរតួជាអ្នកតភ្ជាប់ ដែលអាចតភ្ជាប់អ្នកសិក្សា ទៅនឹងពិភពខាងក្រៅផងដែរ។ ជាងនេះទៅទៀត គ្រូបង្រៀនជាអ្នកសម្របសម្រួលដើរតួនាទីសមភាពជាងមុន មានការនិយាយ និងសន្ទនាជាមួយសិស្ស ចែករំលែកគោលដៅ និងការជឿជាក់របស់ពួកគេ និងគាំទ្រពួកគេនៅក្នុងការសម្រេចចិត្ត ឬធ្វើសកម្មភាព។

## ការសិក្សាដែលមានការចូលរួម

ការរៀនដោយមានការចូលរួម គឺជាទម្រង់នៃការរៀនដែលផ្តោតលើដំណើរការ ដែលកើតឡើងនៅពេលដែលសិស្សធ្វើអន្តរកម្មនៅក្នុងការពិត/បរិស្ថានណាមួយ។ អ្នកសិក្សាត្រូវប្រឈមមុខនឹងបញ្ហាក្នុងជីវិតពិតដែលអាចភ្ជាប់ទៅនឹងចំណេះដឹង និងព័ត៌មានដែលពួកគេបានទទួលពីសៀវភៅសិក្សា ដែលធ្វើឱ្យខ្លឹមសារសិក្សាកាន់តែពាក់ព័ន្ធ។ ជាងនេះទៅទៀត ការសិក្សាដែលមានការចូលរួមនៅក្នុងថ្នាក់រៀនអាចពាក់ព័ន្ធនឹងទម្រង់ណាមួយនៃការវិភាគបញ្ហា ឬការដោះស្រាយបញ្ហា។ ដូច្នេះ ការប្រមូលទិន្នន័យ និងការវិភាគ ក៏ដូចជាទម្រង់ផ្សេងៗនៃការពិភាក្សាអាចត្រូវបានអនុវត្ត។ ការសិក្សាដែលមានការចូលរួម ក៏លើកទឹកចិត្តឱ្យមានការផ្សារភ្ជាប់គ្នារវាងការបង្រៀនក្នុងថ្នាក់ និងបទពិសោធន៍ក្រៅថ្នាក់ តាមរយៈគម្រោង ដំណើរកម្សាន្តទៅកាន់ទីកន្លែង និងទម្រង់ផ្សេងទៀតនៃបទពិសោធន៍ផ្ទាល់។ សរុបមក ការរៀនដោយមានការចូលរួមដើរតួជាវេទិកាដ៏មានប្រសិទ្ធភាពមួយសម្រាប់ការបញ្ចូលការសន្ទនា ការផ្លាស់ប្តូរគំនិត និងការអនុវត្តជាក់ស្តែង។ ការសិក្សានេះផ្តោតសំខាន់ទៅលើសិស្ស ដែលសកម្មភាពរួមមាន ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកដទៃ ការដោះស្រាយជាមួយនឹងឧបសគ្គនានា និងឱកាសដែលមិនអាចទាយទុកជាមុនបាន ដោយប្រើប្រាស់ចំណេះដឹងជាក់ស្តែងក្នុងការធ្វើសកម្មភាព។

**ឧទាហរណ៍**

**ការសិក្សាតាមបែបគម្រោង**

PBL (Project-based learning) អាចជាវិធីសាស្រ្តដ៏មានប្រសិទ្ធភាពមួយសម្រាប់ការបង្រៀន GCED ព្រោះវារួមបញ្ចូលការដឹង និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ គម្រោងក្លាយជាយាននៃការណែនាំ ដែលផ្តល់វេទិកាសម្រាប់សិស្សក្នុងការសហការ និងធ្វើការជាក្រុម។ សិស្សទទួលបាន និងអនុវត្តគំនិត និងជំនាញពីកម្មវិធីសិក្សាស្នូល ដើម្បីដោះស្រាយបញ្ហាក្នុងពិភពពិត តាមរយៈដំណើរការនៃការដោះស្រាយបញ្ហាស៊ើបអង្កេត និងការច្នៃប្រឌិតប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើតលទ្ធផលដែលបង្កើតផលវិជ្ជមាន។

ភារកិច្ច PBL គួរតែព្យាយាមបញ្ចូលក្នុងថ្នាក់រៀន (ចំណេះដឹងស្តីពីគោលបំណង) និងបទពិសោធន៍ក្រៅថ្នាក់ (បទពិសោធន៍ប្រធានបទ) ដើម្បីផ្តល់ឱ្យសិស្សនូវឱកាសទទួលបានបទពិសោធន៍ដោយផ្ទាល់ និងសាកសួរអំពីស្ថានភាព/បញ្ហានៅក្នុងជីវិតពិតជាក់ស្តែង។ ការកំណត់នេះអនុញ្ញាតឱ្យសិស្សវិនិច្ឆ័យដោយខ្លួនឯងថាតើពួកគេអាចអនុវត្តគោលគំនិត និងជំនាញដែលពួកគេបានរៀននៅក្នុងថ្នាក់រៀន និងស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ប្រសិនបើពួកគេមិនអាចធ្វើដូច្នេះបាន។




ដើម្បីធ្វើឱ្យថ្នាក់រៀនរបស់អ្នកក្លាយជាកន្លែងសម្រាប់ការផ្លាស់ប្តូរ 'ភាពច្នៃប្រឌិត' គួរតែជាបេះដូងនៃការបង្រៀន និងការរៀន។ ថ្នាក់រៀនអាចត្រូវបានផ្លាស់ប្តូរទៅជា 'សួនកុមារ' ឬ 'បន្ទប់ពិសោធន៍' សម្រាប់

សិស្សដើម្បីបញ្ចេញភាពច្នៃប្រឌិតរបស់ពួកគេ។ ការចូលរួមជាទាំងរូបកាយ ចិត្ត និងបេះដូង គឺត្រូវបាន ត្រូវបានបណ្តុះនៅក្នុងសិស្ស ក្នុងការសម្រេចបាននូវចំណេះដឹង ជំនាញ គុណតម្លៃ និងយុទ្ធសាស្ត្រដើម្បី អភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។ ការចូលរួមព្រមគ្នានៃផ្នែករាងកាយ ការវិភាគ និងអារម្មណ៍របស់ មនុស្ស ជួយសម្រួលដល់ការច្នៃប្រឌិត ដែលអនុញ្ញាតឱ្យអ្នកសិក្សាស្វែងយល់ និងយល់ពីពិភពលោក បានកាន់តែប្រសើរឡើង។ ជាសកល និងក្នុងតំបន់ បញ្ហាប្រឈមទាមទារដំណោះស្រាយប្រកបដោយ ភាពច្នៃប្រឌិត ដោយផ្អែកលើការវិភាគពីបុព្វហេតុដែលនាំឱ្យកើតមានឡើងនូវបញ្ហាទាំងនោះ។

## ហ្គេម និងការបង្រៀន

ហ្គេម និងសកម្មភាពដែលចូលរួម អាចជាឧបករណ៍ដ៏មានអានុភាពសម្រាប់ការសិក្សាដោយការចូលរួម ។ អ្នកសិក្សាត្រូវធ្វើការងារទៅតាមការណែនាំ តាមច្បាប់ និងតាមកិច្ចព្រមព្រៀងលក្ខណៈក្រុម ប៉ុន្តែក៏ត្រូវ មានតុល្យភាពជាមួយនឹងភាពសប្បាយ ឯកជនភាព និងភាពរីករាយផងដែរ។ ដោយសារពួកគេភ្ជាប់បេះ ដូង ចិត្ត និងរាងកាយក្នុងពេលតែមួយ នោះអ្នកសិក្សាអាចអភិវឌ្ឍជំនាញ គុណតម្លៃ និងអាកប្បកិរិយា ចាំបាច់ ដើម្បីរៀបចំពួកគេឱ្យត្រៀមខ្លួន និងបើកទូលាយក្នុងការទទួលបានធាតុចូល ឬចំណេះដឹងថ្មីៗ។

## មានហ្គេមចំនួនបីប្រភេទដែលអ្នកអាចពិចារណា៖

| Group dynamic Games<br>ហ្គេមលេងជាក្រុម៖ | Integrated arts-based Games<br>ហ្គេមដែលផ្អែកលើសិល្បៈរួមបញ្ចូលគ្នា៖ | Simulation Games<br>ហ្គេមក្លែងធ្វើ៖ |
|---|---|---|
| Icebreakers, energizers, team-building, etc. | Creative dramas, visual arts, creative sound & music, creative movement &dance, creative writing, etc. | Role play |
| អ្នកបំបែកទឹកកក អ្នកបង្កើតថាមពល ការកសាងក្រុម។ល។ | ល្ខោនច្នៃប្រឌិត សិល្បៈដែលមើលឃើញ សំឡេងច្នៃប្រឌិត និងតន្ត្រី ចលនាច្នៃប្រឌិត និងរបាំ ការសរសេរប្រកបដោយភាពច្នៃប្រឌិត។ល។ | ការសម្តែងតួ |

គ្រូបង្រៀនមានសេរីភាពក្នុងការជ្រើសរើសហ្គេមដែលសាកសមនឹងទម្រង់នៃការបង្រៀនរបស់ពួកគេ។ ជាឧទាហរណ៍ អ្នកអាចលេងហ្គេម Icebreaking ខ្លីមួយ ដើម្បីចាប់ផ្តើមថ្នាក់រៀន។ ប្រើសិល្បៈ ឬរឿងល្ខោនប្រកបដោយភាពច្នៃប្រឌិតសម្រាប់ការបំផុសគំនិតសកម្មភាព។

ហ្គេមគួរតែផ្អែកលើគោលបំណងសិក្សាជាក់លាក់ ទាំងការយល់ដឹងនិងការមិនយល់ដឹង និងលើស្ថានភាពជាក់លាក់ ឬលក្ខណៈនៃថ្នាក់។ ហ្គេមគួរតែមានបង្កប់នូវភាពសប្បាយរីករាយ និងគួរឱ្យរំភើបសម្រាប់សិស្ស ហើយចំណុចសិក្សាសំខាន់ៗ គួរតែត្រូវបានពិចារណាយ៉ាងប្រុងប្រយ័ត្នមុនពេលដំណើរការហ្គេម។ គ្រូបង្រៀនត្រូវចងចាំថាហ្គេមគួរតែត្រូវបានប្រើជាឧបករណ៍ដើម្បីជំរុញគុណតម្លៃ និងជំនាញការគិតពិចារណាក្នុងអ្នកសិក្សា។

| | |
|---|---|
| **រយៈពេល** | ២០នាទី |
| **វត្ថុបំណង** | - ដើម្បីសំយោគនូវអ្វីដែលពួកគេបានរៀន និងបទពិសោធន៍ក្នុងសម័យប្រជុំ។<br>- ដើម្បីឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ មតិកែលម្អ និងសំណួររបស់ពួកគេ។ |

| | |
|---|---|
| **សកម្មភាព៖** | **ការចែករំលែកគំនិត និងការគិតផ្សេងៗ** |

## ជំហាន៖

១. ឱ្យអ្នកចូលរួមអង្គុយជារង្វង់មួយមុនពេលចាប់ផ្តើមសកម្មភាព។

២. សង្ខេបខ្លឹមសារមេរៀន។ សង្កត់ធ្ងន់លើការពិតដែលថាប្រសិទ្ធភាពនៃការបង្រៀនខ្លឹមសារ GCED និងការជំរុញតម្លៃ GCED អាស្រ័យលើយុទ្ធសាស្ត្រ និងវិធីសាស្ត្រនៃការបង្រៀន។ ធ្វើឱ្យពួកគេរំលឹកឡើងវិញនូវសារៈសំខាន់ និងផលប៉ះពាល់នៃការចូលរួម និងការស្វែងរកដោយខ្លួនឯងនៅក្នុងថ្នាក់។

៣. ស្តាប់សំណួរ យោបល់ និងមតិកែលម្អដែលអ្នកចូលរួមអាចមាន លើខ្លឹមសារដែលពួកគេបានរៀនក្នុងមេរៀន រួមទាំងបទពិសោធន៍ និងការចាប់អារម្មណ៍របស់ពួកគេ។ ក៏សុំឱ្យពួកគេចែករំលែកយោបល់អំពីរបៀបដែលពួកគេអាចកែលម្អការអនុវត្តក្នុងថ្នាក់។

៤. បញ្ចប់មេរៀនដោយសំឡេងទះដៃ និងពាក្យលើកទឹកចិត្ត។

## កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

វាមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើឧទាហរណ៍ផ្សេងៗ ដែលបង្ហាញពីយុទ្ធសាស្ត្របង្រៀនខាងលើ ដើម្បីបង្កើនការយល់ដឹងរបស់អ្នកចូលរួមអំពីគោលគំនិត។ ត្រូវប្រាកដថាបញ្ចូលយុទ្ធសាស្ត្របង្រៀនទៅក្នុងមេរៀន ហើយបង្ហាញអ្នកចូលរួមពីរបៀបដែលសិក្ខាសាលាគួរតែត្រូវបានសម្របសម្រួល។

ជំពូកទី 5 នឹងផ្តល់ឱ្យអ្នកនូវឧទាហរណ៍ជាក់ស្តែងនៃថ្នាក់ GCED ដែលបានអនុវត្តនៅក្នុងថ្នាក់រៀនជុំវិញពិភពលោក! យើងនឹងឃើញពីរបៀបដែលវិធីសាស្ត្របង្រៀន និងវិធីសាស្ត្រផ្សេងគ្នាត្រូវបានដាក់បញ្ចូលទៅក្នុងថ្នាក់ទាំងនេះនៅក្នុងជំពូកបន្ទាប់។

នៅពេលផ្តល់មតិកែលម្អ សូមព្យាយាមផ្តោតលើសារៈសំខាន់នៃវប្បធម៌សន្ទនា ដែលជួយឱ្យដឹងពីតម្លៃនៃការគោរពគ្នាទៅវិញទៅមក។ ព្យាយាមធ្វើជាអ្នកគាំទ្រនៅពេលដែលអ្នកជួយសម្រួលដល់ការចែករំលែកការឆ្លុះបញ្ចាំងក្នុងចំណោមអ្នកចូលរួម!

# ជំពូកទី៥៖

# ការរៀបចំធ្វើសកម្មភាព

## ការរៀបចំធ្វើសកម្មភាព

| | |
|---|---|
| **ទិដ្ឋភាពទូទៅ** | ជំពូកនេះ មានគោលបំណងសង្ខេប និងរួមបញ្ចូលខ្លឹមសារដែលបានរៀននៅក្នុងជំពូកមុនៗ ដោយរកមើលករណីអំពីរបៀបដែលគោលគំនិត គោលការណ៍ គរុកោសល្យ និងយុទ្ធសាស្ត្របង្រៀនរបស់ GCED អាចត្រូវបានដាក់បញ្ចូលក្នុងការបង្រៀន។ អ្នកចូលរួមក៏នឹងមានភារកិច្ចបង្កើតផែនការសកម្មភាពដោយផ្អែកលើគំនិត និងមតិយោបល់ដែលពួកគេប្រមូលបានក្នុងអំឡុងពេលសិក្ខាសាលា។ |
| **មេរៀន** | ១. ករណីសិក្សា៖ ការអនុវត្តភាពជាពលរដ្ឋសកលគំរូ<br>២. ការអភិវឌ្ឍផែនការសកម្មភាព |
| **លទ្ធផលសិក្សា** | ១. ការយល់ដឹងទូទៅនៃការអនុវត្តភាពជាពលរដ្ឋសកលនៅកម្រិតផ្សេងៗគ្នា ដោយធ្វើការវិភាគលើការអនុវត្តគំរូ<br>២. បង្កើតផែនការសកម្មភាព ដើម្បីធ្វើជាមគ្គុទ្ទេសក៍សម្រាប់ការអនុវត្ត GCED នាពេលអនាគតនៅក្នុងបរិបទមូលដ្ឋានរបស់អ្នកចូលរួម |
| **លំដាប់លំដោយនៃមេរៀន** | ១. ចាប់ផ្តើមថ្នាក់/Warm-up (៣០ នាទី)<br>- សង្ខេបមេរៀនមុនៗ៖ ល្បែងសំណួរខ្លីៗ<br>២. ខ្លឹមសារ (១២០ នាទី)<br>- (ករណីសិក្សា)៖ ការបង្រៀនភាពជាពលរដ្ឋសកលនៅក្នុងថ្នាក់<br>- (ករណីសិក្សា)៖ សកម្មភាពភាពជាពលរដ្ឋសកល<br>- (សកម្មភាព)៖ គោលការណ៍ណែនាំសម្រាប់ធ្វើសកម្មភាព<br>- (សកម្មភាព)៖ ផែនការសកម្មភាពស្តីពីភាពជាពលរដ្ឋសកល<br>៣. ការឆ្លុះបញ្ចាំង/សង្ខេប (៣០នាទី)<br>- ការឆ្លុះបញ្ចាំងចុងក្រោយ |
